

# ឯកសារណែនាំសកម្មភាពស្តីពីក្លឹបបរិស្ថាន

រៀបរៀងដោយៈ អង្គការ ម្លប់បៃតង


អាស័យដ្ឋានផ្ទះលេខៈ ៣៧ បេ ផ្លូវលេខ ១១៣ សង្កាត់ បឹងកេងកង ២ ខ័ណ្ឌ ចំការមន

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Tel/Fax : 023 214 409
E-mail: mlup@online.com.kh
Website: www.mlup.org






# សេចក្តីថ្លែងអំណរគុណ

អង្គការ ឫប់បៃតង **សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលោក** លោកស្រីដែលបានលះបង់នូវកំលាំងកាយចិត្តជួយគាំទ្រ **ក្នុងការកែសម្រួលមេរៀនរួបបទស្តី**ពីឯកសារណែនាំនេះដល់

**លោក** Simon Jan Molendijk និង

**លោក** Fiontan O Loinsigh



# មាតិកា


ឯកសារណែនាំសកម្មភាពស្តីពីក្លឹបបរិស្ថាន ........ ៦

សេចក្តីណែនាំ ........ ៦

ហេតុអ្វីបានជាឯកសារណែនាំនេះត្រូវបានចងក្រងឡើង ........ ៦

វិធីប្រើប្រាស់ឯកសារណែនាំនេះ ........ ៦

តើក្លឹបបរិស្ថានជាអ្វី? ........ ៧

តើគោលបំណងរបស់ក្លឹបបរិស្ថានជាអ្វី? ហើយហេតុអ្វីបានជាត្រូវបង្កើតក្លឹបបរិស្ថាន? ........ ៧

អត្ថប្រយោជន៍នៃការបង្កើតក្លឹបបរិស្ថាន ........ ៧

ការបង្កើតក្លឹបបរិស្ថាន : បទបញ្ជាផ្ទៃក្នុង ការប្តេជ្ញា និង អត្តសញ្ញាណ ........ ៨

តើអ្នកត្រូវការអ្វីខ្លះសំរាប់ចាប់ផ្តើម? ........ ៩

ទំនាក់ទំនង និងសហការជាមួយស្ថាប័នអប់រំនានា ........ ៩

ការពិគ្រោះពិភាក្សាជាមួយការិយាល័យគ្រប់គ្រងរដ្ឋបាលសាលា ........ ៩

អ្នកសំរបសំរួលក្លឹបបរិស្ថាន និងការលើកកំពស់អ្នកគ្រូ ........ ១០

សមាជិកក្លឹប ........ ១១

ការអនុញ្ញាតិ និងការចូលរួមរបស់អនាព្យាបាល ........ ១១

ការកំណត់នូវតំរូវការ ........ ១១

បទបញ្ជាផ្ទៃក្នុង និងការសន្យារបស់ក្លឹបបរិស្ថាន ........ ១២

ពេលវេលាអនុវត្តសកម្មភាព ...... ១២
ឈ្មោះក្លឹប ...... ១២
រូបសញ្ញាសំគាល់ក្លឹប ...... ១២
បទចំរៀង និង កំណាព្យរបស់ក្លឹប ...... ១៣
ការបង្កើតការដឹកនាំក្លឹបបរិស្ថាន ...... ១៣
ដំណើរការក្លឹបបរិស្ថាន ...... ១៤
ការចូលរួម និងការបង្កើតភាពដឹកនាំរបស់សិស្ស ...... ១៤
ការរៀបចំកិច្ចប្រជុំក្លឹប ...... ១៤
ទីកន្លែងប្រជុំ ...... ១៥
ការបង្កើត ទស្សនៈវិស័យ ទិសដៅ គោលបំណង និង ផែនការ ...... ១៦
ការកំណត់ទិសដៅ និង គោលបំណងរបស់ក្លឹបបរិស្ថាន ...... ១៦
ការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ ...... ១៧
សមសភាពទាំងបី: កិច្ចប្រជុំក្លឹប សំរបសំរួលការសិក្សា និង សិស្សដឹកនាំសកម្មភាព ...... ១៧
ការសិក្សានៅខាងក្រៅថ្នាក់ ...... ១៨
ការចុះតាមសហគមន៍ ...... ១៨
ការបង្កើតទិវាផ្សេងៗ ...... ១៨
អ្នកមានបទពិសោធន៍ និងការស្នើសុំជំនួយ ...... ១៩
ការគាំទ្រសកម្មភាពដោយខ្លួនឯង/ការបង្កើតមូលនិធិ ...... ១៩
ការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ...... ១៩

ការធ្វើវិភាគទានពីសហគមន៍ និងស្ថាប័នផ្សេង ........ ១៩

ការលើកទឹកចិត្តសិស្ស ........ ២០

របាយការណ៍ទៅការិយាល័យអប់រំស្រុក (DoE) និង មន្ទីរអប់រំ យុវជន និងកីឡាខេត្ត (PoEYS) ........ ២០

សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្រៀន និង ការត្រួតពិនិត្យតាមដាន (ដែលគាំទ្រដោយមន្ត្រីការក្រៅផ្លូវការ) ........ ២០

គោលបំណងនៃសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្រៀន ........ ២០

ការបង្កើនការយល់ដឹងអំពីបរិស្ថាន ........ ២១

ការពង្រីកសមត្ថភាពបង្រៀន ........ ២១

ការចែករំលែកបទពិសោធន៍ ........ ២១

ការផ្តល់សំភារៈ និងកាលវិភាគកម្មវិធី ........ ២២

ការគាំទ្រគ្រូបង្រៀន ........ ២២

គ្រូបង្គោល និងគ្រូបណ្តុះបណ្តាល ........ ២២

ការបង្កើត និងការរៀបចំឯកសារបង្រៀន ........ ២២

វិធីសាស្ត្រនៃការចូលរួម ........ ២៣

ការជ្រើសរើសតាមលំនាំមេរៀនដែលមានស្រាប់ និងការបង្កើតមេរៀនថ្មីៗ ........ ២៣

ការរៀបចំសំភារៈ ........ ២៤

ការពិនិត្យតាមដាន និងការវាយតំលៃ ........ ២៤

ការរៀបចំតារាងត្រួតពិនិត្យ និងវាយតំលៃ ........ ២៥

អនុវត្តការត្រួតពិនិត្យ ការដោះស្រាយបញ្ហា និងការផ្តល់យោបល់ ........ ២៥

ការដោះស្រាយបញ្ហា និង គន្លឹះសំរាប់ដំណើរការក្លឹបអោយបានជោគជ័យ ........ ២៥

សេចក្តីសន្និដ្ឋាន ..... ២៧
និរន្តរភាព ..... ២៨
ឧបសម្ព័ន្ធ I: **សំនួរគន្លឹះដើម្បីកំណត់សាលារៀនដែលមានសុពលភាព** ..... ២៨
ឧបសម្ព័ន្ធ II: **គំរូពាក្យស្នើសុំទៅសំរាប់ក្រសួង អប់រំ យុវជន និង កីឡា** ..... ២៩
ឧបសម្ព័ន្ធ III: ពិពណ៌នាការងាររបស់អ្នកសំរបសំរួលក្លឹប ..... ៣០
ឧបសម្ព័ន្ធ IV: គំរូប្រកាសជ្រើសរើសសមាជិកក្លឹប ..... ៣១
ឧបសម្ព័ន្ធ V: គំរូលិខិតផ្ញើទៅឪពុកម្តាយ ..... ៣១
ឧបសម្ព័ន្ធ VI: ការកំនត់គំរូវការកម្មវិធី ..... ៣២
ឧបសម្ព័ន្ធ VII: គំរូទំរង់កំណត់ហេតុ ..... ៣៣
ឧបសម្ព័ន្ធ VIII: សាលាគំរូក្នុងផែនការមេរៀនបរិស្ថាន ..... ៣៣
ឧបសម្ព័ន្ធ IX: ផែនការសកម្មភាព ..... ៣៥
ឧបសម្ព័ន្ធ X: របាយការណ៍ប្រចាំត្រីមាសសំរាប់ការិយាល័យអប់រំស្រុក ..... ៣៧
ឧបសម្ព័ន្ធ XI: កម្មវិធីសំរាប់សិក្ខាសាលាបណ្តុះបណ្តាលគ្រូវគ្គ ១ ..... ៣៧
ឧបសម្ព័ន្ធ XII: បញ្ជីសំភារៈជ្រើសរើសដើម្បីគាំទ្រដល់ការរៀបចំឯកសារមេរៀន ..... ៣៨
ឧបសម្ព័ន្ធ XIII: តារាងវាយតំលៃសកម្មភាពក្លឹបបរិស្ថាន ..... ៣៩

# ឯកសារណែនាំស្តីពីសកម្មភាពក្លឹបបរិស្ថាន

## សេចក្តីណែនាំ

ហេតុអ្វីបានជាឯកសារណែនាំនេះត្រូវបានចងក្រងឡើង?

*ឯកសារណែនាំស្តីពីសកម្មភាពក្លឹបបរិស្ថាននេះ* **ត្រូវបានចងក្រងឡើង ដើម្បីចែករំលែក**បទពិសោធន៍របស់អង្គការម្លប់បៃតង ក្នុងការបង្កើត និងធ្វើ**ការសំរបសំរួល ដល់ក្លឹបបរិស្ថានកុមារ**នៅក្នុងប្រទេសកម្ពុជា និងដើម្បីលើកកំពស់ អោយកាន់តែទូលំទូលាយ **ក្នុងការអនុវត្តន៍ក្លឹបបរិស្ថាន**នេះ នៅតាមសាលារៀន និងសហគមន៍។ អង្គការម្លប់បៃតង **ជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា**ក្នុងស្រុកមួយ ដែលបាន និងកំពុងអនុវត្តការងារលើវិស័យ**អប់រំបរិស្ថាន អស់រយៈពេលជាង៥ឆ្នាំ**មកហើយ។ ចាប់តាំងពីឆ្នាំ១៩៩៨មក អង្គការបានអនុវត្តសកម្មភាពការងារ ជាមួយសាលារៀនរដ្ឋ ដូចជា បង្រៀនក្នុងលក្ខណៈជាភ្ញៀវ បណ្តុះបណ្តាលគ្រូបង្រៀន **ការដាំដុះកូនឈើ និងទស្សនៈកិច្ចសិក្សា**។

សំរាប់អង្គការម្លប់បៃតង ក្លឹបបរិស្ថានជាមធ្យោបាយមួយ **ដើម្បីបញ្ចូលភាពខ្លាំង** និងបទពិសោធន៍ ក្នុងការអប់រំបរិស្ថាន និងផ្តោតលើការខិតខំប្រឹងប្រែង ដើម្បីសំរេចនូវលទ្ធផលដ៏ជាក់លាក់ និងអាចវាស់វែងបាន នៅតាមសាលារៀន និងសហគមន៍នានា។ យើងបានកត់សំគាល់ថា ក្លឹបបរិស្ថាន បានធ្វើអោយមានការប្រសើរឡើង នូវបរិស្ថានយ៉ាងច្រើន ដូចជា: នៅតាមសាលារៀននានា ដែលពីមុន គេមើលទៅហាក់បីដូចជាគ្មានការយកចិត្តទុកដាក់ថែរក្សា តែឥឡូវនេះមាន បរិយាកាសប្រកបដោយជាសុខភាពល្អក្នុងការសិក្សា ដោយមានការបណ្តុះ និងការដាំកូនឈើ សួនឱសថធម្មជាតិ និងមានសួនច្បារ បដាបិទផ្សាយពត៌មាន ហើយសំខាន់ជាងនេះទៅទៀត សិស្សានុសិស្ស និងគ្រូបង្រៀនយកចិត្តទុកដាក់ ថែរក្សានូវធម្មជាតិ និងបរិស្ថានដែលស្ថិតនៅជុំវិញពួកគេ។

## វិធីប្រើប្រាស់ឯកសារណែនាំនេះ

ឯកសារណែនាំនេះ មានបំណងដើម្បីផ្តល់យោបល់ និងបទពិសោធន៍ខ្លះសំរាប់អ្នកដែលមានចំណាប់អារម្មណ៍ ក្នុងការបង្កើតក្លឹបបរិស្ថាននេះ ដូចជា គ្រូបង្រៀន មន្ត្រីអប់រំនានា ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ។



ដើម្បីបង្កើតនូវក្លឹបបរិស្ថាន ដំណើរការត្រូវធ្វើឡើងជាជំហានៗ ចាប់តាំងពីវិធីជ្រើស រើសអ្នកសំរបសំរួលក្លឹបបរិស្ថាន រហូតដល់ការសំរេចនូវឈ្មោះ និងផ្លាកសញ្ញាសំគាល់ក្លឹប។ ជាមួយគ្នានោះដែរក៏មានផ្នែកខ្លះនៃអត្ថបទនេះ បានជួយសំរួលដល់វិធីត្រួតពិនិត្យ និងតាមដាន សកម្មភាពក្លឹបបរិស្ថាន វិធីដោះស្រាយបញ្ហា និងវិធីបង្កើតមូលនិធិ ដើម្បីទ្រទ្រង់សកម្មភាពក្លឹប អោយមាននិរន្តរភាព។ យើងខ្ញុំសំណូមពរ អោយលោកអ្នកអាននូវឯកសារណែនាំនេះ ទាំងអស់ មុនពេលបង្កើតនូវក្លឹបបរិស្ថាន ហើយសូមលោកអ្នកពិនិត្យមើលនៅផ្នែកផ្សេងៗទៀត អំពីវិធី ប្រើប្រាស់ដ៏អិតច្បាស់លាស់។ រាល់យោបល់នានា ដែលមាននៅក្នុងឯកសារណែនាំនេះ គឺផ្អែក លើបទពិសោធន៍ការងាររបស់អង្គការម្លប់បៃតង ហើយនិងស្ថានភាពផ្សេងៗទៀត ដែលតំរូវ អោយមានការឆ្លើយតបខុសៗគ្នាផងដែរ។ ជាការពិត យើងអាចបង្កើតនូវក្លឹបបរិស្ថានមួយដែល ស្ថិតនៅក្រៅប្រព័ន្ធសាលារៀនបាន ក្នុងករណីនេះ លោកអ្នកអាចពិនិត្យឃើញ នូវផ្នែកណាមួយ នៃអត្ថបទនេះមានប្រយោជន៍ ហើយអាចដកស្រង់នូវពត៌មានដែលចាំបាច់សំរាប់ការបង្កើតក្លឹប បរិស្ថាននៅក្នុងសហគមន៍។

ឯកសារនេះ អាចត្រូវបានប្រើប្រាស់ ក្នុងការភ្ជាប់គ្នាជាមួយ និងឯកសារអប់រំបរិស្ថាន ផ្សេងៗទៀត ដូចជាសៀវភៅណែនាំអ្នកអប់រំបរិស្ថាន ការអប់រំបរិស្ថាន (UNDP/ETAP)សំរែកព្រៃឈើ និងឯកសារផ្សេងៗទៀត (សូមមើលឧបសម្ព័ន្ធ XII)។ អ្នករៀបចំ ក៏អាចប្រើប្រាស់សកម្មភាព នានារបស់ខ្លួន និងដែលបានស្នើឡើងដោយសមាជិកក្លឹប។ ម្យ៉ាងវិញទៀត ពីការបង្កើតគំនិតថ្មីៗ និងការលើកទឹកចិត្តដល់គំនិតថ្មីៗ ទាំងនោះ។

## តើក្លឹបបរិស្ថានជាអ្វី?

ក្លឹបបរិស្ថាន គឺជាសមាគម ឬក្រុមសិស្សស្ម័គ្រចិត្ត ដែលរួមគ្នាបង្កើតឡើង ហើយមានវត្ថុបំណងដើម្បីសិក្សា និងជួយកែលំអបរិស្ថាន។ ក្លឹបបរិស្ថានជាទូទៅ ត្រូវបានណែនាំ ឬសំរបសំរួលដោយគ្រូម្នាក់ ដែលជួយរៀបចំសិស្សសាលា និងផ្តល់ការណែនាំ ដំបូន្មាន អំពីដំណើរការក្លឹប និងការអនុវត្តសកម្មភាពការងារ។ រាល់កិច្ចប្រជុំ និងសកម្មភាពនានា ជាទូទៅ**ត្រូវបានអនុវត្តធ្វើ**ឡើងនៅក្រៅម៉ោងសិក្សា។

## តើគោលបំណងរបស់ក្លឹបបរិស្ថានជាអ្វី?ហើយហេតុអ្វីបានជាត្រូវបង្កើតក្លឹបបរិស្ថាន?

គោលបំណងដ៏សំខាន់របស់ក្លឹបបរិស្ថាន គឺដើម្បីបង្កើន**ការយល់ដឹងរបស់សិស្ស អំពី**



បរិស្ថាន និងដើម្បីកែលំអជំនាញផ្សេងៗ ដែលពួកគេចាំបាច់ត្រូវអនុវត្តខុសៗគ្នា នៅក្នុងបរិស្ថានរបស់ពួកគេ និងដើម្បីបង្កើតនូវការទទួលខុសត្រូវ ហើយធ្វើការថែទាំបរិស្ថាន ដែលនៅជុំវិញសាលារៀន និងក្នុងសហគមន៍។ ក្លឹបបរិស្ថាន បង្រៀនដល់សិស្សផ្សេងៗទៀត អំពីជំនាញដ៏សំខាន់ក្នុងជីវិត ដូចជា ការធ្វើផែនការ ការធ្វើការជាក្រុម ការសិក្សាស្រាវជ្រាវ ទំនាក់ទំនង ការបង្កើតមូលនិធិ និងការបង្កើតគំនិតថ្មីៗទៀត ដូចជា ការត្រិះរិះពិចារណាជាដើម។ រាល់ជំនាញទាំងនេះ មានសារៈសំខាន់ធំទូលំទូលាយ សំរាប់ពេលវេលាយូរអង្វែង សំរាប់សិស្សានុសិស្ស និងសហគមន៍នានា។

## អត្ថប្រយោជន៍នៃការបង្កើតក្លឹបបរិស្ថាន

១-បង្កើនការដឹកនាំសិស្ស ជំនាញសំរាប់ជីវិត ការថែរក្សាអំពីបរិស្ថាន និងសហគមន៍ ភាពទទួលខុសត្រូវ ការធ្វើការជាក្រុម និងចំណេះដឹង

**ក្លឹបផ្តល់ឱកាស ដល់សិស្សធ្វើការជាមួយក្រុមមិត្តភក្តិរបស់ពួកគេ** ដើម្បីធ្វើផែនការ និង អនុវត្ត**សកម្មភាពបរិស្ថាន សំរាប់ផលប្រយោជន៍ដល់សាលារៀន និងសហគមន៍របស់ពួកគេ។** ដំណើរការទាំងនេះ**តំរូវអោយសិស្សមានការសហការ** ស្តាប់គ្នាទៅវិញទៅមក បង្កើតគំនិត ផ្សេងៗ ធ្វើផែនការ ធ្វើការវិភាគ**នូវលទ្ធផលសំរេចបាន និងឧបសគ្គនានា** ហើយធ្វើ ទំនាក់ទំនង ជាមួយអ្នកចូលរួមនានា ដូចជាអ្នកគ្រប់**គ្រងការិយាល័យរដ្ឋបាលសាលា** និងអ្នកដឹកនាំសហគមន៍ ផ្សេងៗទៀត។ រាល់សិស្សទាំងអស់ នឹងយល់ដឹង**អំពីបរិស្ថានរបស់ពួកគេ** តាមរយៈមេរៀនបន្ថែម ដោយលោកគ្រូអ្នកគ្រូធ្វើការសំរបសំរួល និងតាមរយៈការធ្វើអង្កេត និងសំភាសន៍នៅតាម សហគមន៍។ ពួកគេនឹងយល់ដឹងអំពីវិធីសាស្ត្រ ដើម្បីអនុវត្តសកម្មភាព ដូចជា ការដាំដុះកូនឈើ និងការដាំរុក្ខជាតិធ្វើជាឱសថផងដែរ។

២-បង្កើនសមត្ថភាពគ្រូបង្រៀន

អ្នកសំរបសំរួលក្លឹប ជាអ្នកដែលជួយដំណើរការសិស្សក្លឹប ហើយអាចទទួលបាននូវផលប្រយោជន៍ផងដែរ។ ដោយផ្អែកលើធនធានរបស់សាលា រឺការគាំទ្រពីអង្គការនានា អាចមានឱកាសជាច្រើនសំរាប់ធ្វើការបណ្តុះបណ្តាល ឬទស្សនកិច្ចផ្លាស់ប្តូរ បទពិសោធន៍ អ្នកសំរបសំរួល។ គ្រូសម្របសម្រួលនឹងបានសិក្សាស្វែងយល់ ពីឯកសារសំភារៈបង្រៀន ផ្សេងៗ និងតាមរយៈ លទ្ធផលនៃការអង្កេត និងសំភាសន៍នានា។ ពួកគេនឹងទទួលបាននូវការ គោរពពីឪពុកម្តាយ របស់សិស្ស និងសហគមន៍ដែលមាន ការពេញចិត្តនឹងលទ្ធផលរបស់កូនៗពួក គេជំនាញដែលពួកគេ ទទួលបានព្រមទាំងការរីកចំរើនបរិស្ថាននៅក្នុងសាលា និងសហគមន៍ ។ ជាមួយគ្នានោះដែរ គ្រូបង្រៀន នឹងបង្កើននូវ ទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយសិស្សសាលាប្រកបដោយ បរិយាកាសរីករាយព្រមទាំងមានការយល់ដឹង កាន់តែប្រសើរឡើងថែមទៀត អំពីទស្សនៈ និង គំនិតផ្សេងៗ។



៣-ធ្វើអោយសាលារៀន និងភូមិមានសោភ័ណភាព ព្រមទាំងបង្កើតនូវបរិយាកាសសិក្សាប្រកបដោយផាសុខភាព

សាលារៀនជាច្រើននៅក្នុងប្រទេសកម្ពុជា បានបង្ហាញអោយឃើញ ពីការមិនយកចិត្តទុកដាក់។ នៅតាមទីធ្លាសាលារៀន រាយប៉ាយទៅដោយសំរាម បន្ទប់រៀនទទេ **និងដើមឈើ២-៣ដើម** តែប៉ុណ្ណោះ។ ជាក់ស្តែង ការងារទាំងនេះ ត្រូវការធនធានតិចតួចបំផុត **ដើម្បីធ្វើការកែលំអ**នូវមុខមាត់សាលារៀន ហើយការងារទាំងនេះ អាចសំរេចបានតាម**រយៈសកម្មភាពក្លឹបបរិស្ថាន** ដោយមានការចូលរួម និងសហការរវាងសាលារៀន នឹងសហគមន៍។ **ក្លឹបបរិស្ថានគឺជាក្រុមឈានមុខ** ដើម្បីធ្វើការកែលំអសោភ័ណភាពសាលារៀន ហើយអាចទទួលបាន**មកវិញ នូវលទ្ធផល និង**មោទនភាពក្នុងការថែទាំ ពីសំណាក់សិស្សសាលា និងសហគមន៍**ផ្សេង១ទៀត**។

៤-ពង្រឹងទំនាក់ទំនងរវាងសាលា និងសហគមន៍

កត្តាមួយដ៏សំខាន់ នៃសកម្មភាពក្លឹបបរិស្ថាន **គឺធ្វើការផ្សារភ្ជាប់ជាមួយសហគមន៍**។ ឪពុកម្តាយរបស់សិស្ស ដែលជាសមាជិករបស់ក្លឹបបរិស្ថាន **មានឱកាសយ៉ាងច្រើន ក្នុង**ការចូលរួមធ្វើសកម្មភាពជាមួយក្លឹប។ បន្ថែមពីនេះទៀត សិស្សបាន**ធ្វើការអង្កេត និងចុះទស្សនៈ**កិច្ចតាមភូមិរបស់ពួកគេ ដើម្បីពង្រីកចំណេះដឹងរបស់ខ្លួន អំពីស្ថានភាព**ក្នុងមូលដ្ឋាន និងអំពី**បញ្ហាបរិស្ថាន។ ជាមួយគ្នានោះដែរ ក៏មានឱកាសជាច្រើនសំរាប់សមាជិក**សហគមន៍** ដែលជាអ្នកមានបទពិសោធន៍ដ៏សំខាន់សំរាប់សិស្ស ដូចជា ផ្តល់នូវបទពិសោធន៍**អំពីរុក្ខជាតិ សំរាប់**ធ្វើជាឱសថធម្មជាតិ ឬការដាំដុះកូនឈើជាដើម។ សហគមន៍ក៏អាចត្រូវបាន**ស្នើសុំដោយក្លឹប** ដើម្បីចូលរួមនូវគំរោងកម្មវិធី ដូចជា ការធ្វើរបងសាលា និងការសាងសង់បង្គន់**អនាម័យ**។ ក្លឹបបរិស្ថានជាច្រើនអាចទទួលបាននូវ ផលប្រយោជន៍ ពីទំនាក់ទំនងជាមួយវត្តអារាមនានា ដែលនៅក្បែរ១សាលារៀន។ ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានការគោរព និងយល់ដឹងយ៉ាងខ្លាំងអំពីធម្មជាតិ ហើយក្នុងករណីជាច្រើន ព្រះសង្ឃមានឆន្ទៈក្នុងការគាំទ្រ និងសហការណ៍ជាមួយគំនិតផ្តួចផ្តើមរបស់ សិស្សផងដែរ។

៥-ការគាំទ្រវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល និងកម្មវិធីសាលាកុមារមេត្រី ដែលស្របទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា

វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល មានន័យថា សិស្សានុសិស្សស្ថិតនៅក្នុងមណ្ឌលនៃដំណើរការ**សិក្សាមួយ** បើប្រៀបធៀបទៅនឹងវិធីសាស្ត្រធម្មតា នៃវិធីសាស្ត្រគ្រូមជ្ឈមណ្ឌល ដែលសិស្សានុសិស្ស**ច្រើនតែ**ផ្តោតទៅលើគ្រូបង្រៀន។ នៅក្នុងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល **សិស្សអាច សិក្សាពីគ្នាទៅវិញទៅមក** "ក្រុមសិក្សា" និងតាមរយៈការសិក្សាស្វែងរកផ្ទាល់ខ្លួន តាមការ ស្រាវជ្រាវ និងការចូលរួម។ នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានសំរេចជ្រើសរើស និងជំរុញនូវ វិធីសាស្ត្រ**សិស្ស**មជ្ឈមណ្ឌលនេះ ទោះបីការអនុវត្តជាក់ស្តែងមានការ លំបាកក្នុងការផ្លាស់ប្តូរទំលាប់របស់គ្រូក៏ដោយ។ ការបង្កើតក្លឹបបរិស្ថាន និងសំភារៈសិក្សាត្រូវបានធ្វើឡើង ដើម្បីគាំទ្រដល់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលនេះ។ បន្ថែមពីនេះទៅទៀត គោលគំនិតនៃការបង្កើត "សាលាកុមារមេត្រី" ត្រូវបានផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសបរិយាកាសសិក្សា បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រសិទ្ធភាពនៃការសិក្សាផងដែរ។ ក្លឹបបរិស្ថានមានការគាំទ្រដល់ការសំអាតសាលារៀន និងការកែលំអបរិយាកាសសិក្សាទៀតផង។



**ការបង្កើតក្លឹបបរិស្ថានៈ បទបញ្ជាផ្ទៃក្នុង ការប្តេជ្ញា និងអត្តសញ្ញាណ**

*តើអ្នកត្រូវការអ្វីខ្លះសំរាប់ការចាប់ផ្តើម?*

មុនពេលចាប់ផ្តើមបង្កើតក្លឹបមួយ វាជាកត្តាសំខាន់បំផុត ដែលត្រូវធ្វើការយល់ដឹងអំពីស្ថានភាពក្នុងស្រុកជាមុនសិន។ សំខាន់ជាងនេះទៅទៀត លោកអ្នកត្រូវកំណត់សាលាណា ដែលមានការចាប់អារម្មណ៍ចង់បង្កើតក្លឹបនេះ។ សូមពិនិត្យមើលឧបសម្ព័ន្ធ១ សំរាប់បញ្ជីសំណួរគន្លឹះ ដើម្បីកំណត់សាលារៀន ដែលមានសុពលភាព។ ប្រសិនបើលោកអ្នកជាគ្រូបង្រៀន វាជាការសំខាន់ណាស់ ដែលលោកអ្នកអាចចូលជួបជាមួយការិយាល័យគ្រប់គ្រងរដ្ឋបាលសាលា ដើម្បីទទួលបាននូវការគាំទ្រពីសាលា។ ជាមួយគ្នានោះដែរ វាមានសារៈសំខាន់ណាស់ ក្នុងការស្វែងយល់ អំពីធនធានដែលមានសំរាប់លោកអ្នក។ ប្រសិនបើលោកអ្នកជាគ្រូបង្រៀន លោក អ្នកអាចស្នើសុំ ជំនួយហិរញ្ញវត្ថុសំរាប់ក្លឹបបរិស្ថាន ពីការិយាល័យគ្រប់គ្រងរដ្ឋបាលសាលាផងដែរ។ ក្លឹបបរិស្ថាន អាចដំណើរការជាមួយ នឹងធនធានតិចតួចបាន ដោយសារសំភារៈជាច្រើន មាននៅតាមសាលារៀនក្នុងស្រុកស្រាប់ ហើយទោះជាយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ បើបានដឹងមុនថា មានថវិកាខ្លះដើម្បីធ្វើសកម្មភាពដូចជា ការចុះទស្សនៈកិច្ចសិក្សាតាមមូលដ្ឋាន ការធ្វើអោយសាលារៀនមានពណ៌បៃតង (ធ្វើអោយសាលាមានសោភ័ណភាព តាមរយៈការដាំដុះកូនឈើ និងសួនច្បារ។ល។) ព្រមទាំងការបង្កើតកម្មវិធីយល់ដឹងផ្សេងៗ។ ម្យ៉ាងវិញទៀត ក្លឹបរបស់លោក អ្នកអាចមានផែនការសំរាប់បង្កើតមូលនិធិ ដោយការទទួចសុំសំរាប់ការបរិច្ចាគ (វិភាគទាន)។

**ចំនាក់ចំនង និងសហការជាមួយស្ថាប័នអប់រំនានា**

ជាការចាប់ផ្តើម យើងសូមផ្តល់អនុសាសន៍ថា គួរមានការអនុម័តយល់ព្រមពីអាជ្ញាធរអប់រំពាក់ព័ន្ធនានាជាមុន។ ដើម្បីអនុវត្តនូវកម្មវិធីទូលំទូលាយ ទាក់ទងទៅនឹងសាលារៀនច្រើននោះ ការអនុម័តយល់ព្រម គួរត្រូវបានការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត រីឯកម្មវិធីតូចៗអាចអនុវត្តសកម្មភាពការងារបាន ដោយធ្វើការផ្ទាល់ជាមួយការិយាល័យអប់រំខេត្ត ឬស្រុក។ ដើម្បីទទួលបាននូវការអនុម័តយល់ព្រមនេះ ពាក្យស្នើសុំនៃគំរោងកម្មវិធីមួយ គួរត្រូវបានដាក់ស្នើយ៉ាងតិចបីខែ មុនពេលការចាប់ផ្តើម អនុវត្តផែនការកម្មវិធី។ សូមមើលឧបសម្ព័ន្ធ ២ សំរាប់គំរូពាក្យស្នើសុំ។ នៅពេលដំណើរការកម្មវិធី អ្នកសំរបសំរួលក្លឹបបរិស្ថាន ត្រូវស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីរក្សាទំនាក់ទំនង ជាមួយអាជ្ញាធរអប់រំ និងផ្តល់ជូនពត៌មាន អំពីសកម្មភាពក្លឹបបរិស្ថាន។

មានមធ្យោបាយជាច្រើន ក្នុងការអនុវត្តកិច្ចការនេះ ដូចជា:

- រៀបចំពេលវេលាចុះទស្សនៈកិច្ច តាមសាលាដើម្បីអោយមន្ត្រីទាំងនោះ បាន ឃើញអំពីសកម្មភាពក្លឹប
- ផ្ញើរបាយការណ៍ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាប្រចាំដើម្បីរក្សាការផ្តល់ពត៌មានដល់ពួកគេ។
- ស្នើសុំការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីគាំទ្រសកម្មភាពនានារបស់ក្លឹប ដោយស្នើសុំអោយមន្ទីរចំលែកនូវថវិកាខ្លះៗ។
- ស្នើសុំអោយមន្ត្រីអប់រំ ផ្តល់សេចក្តីថ្លែងការណ៍ សំរាប់ពិធីផ្សេងៗរបស់ក្លឹប បរិស្ថាន។

**ការពិគ្រោះពិភាក្សាជាមួយការិយាល័យគ្រប់គ្រងរដ្ឋបាលសាលា**



ការគាំទ្រ ពីការិយាល័យគ្រប់គ្រងរដ្ឋបាលសាលា និងនាយកសាលា សំរាប់សកម្មភាពរោរា របស់ក្លឹប ជាកត្តាមួយសំខាន់បំផុត។ តាមរយៈបទពិសោធន៍របស់យើង យើងបានកត់សំគាល់ថា ភាគច្រើននៃក្លឹប ដែលទទួលបានជោគជ័យ តែងតែមានការចូលរួមពីនាយកសាលា ឬនាយករង ដែលជាអ្នកសំរបសំរួលក្លឹបដ៏សំខាន់ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីខ្លះ បុគ្គលទាំងនេះមិន អាចមានពេលវេលា

គ្រប់គ្រាន់ ដើម្បីបរិច្ចាគសំរាប់សកម្មភាពក្លឹបឡើយ ដោយពួកគេមានការងារទទួលខុសត្រូវជាច្រើនទៀត ។ ក្នុងករណីណោក៏ដោយ ដាច់ខាតត្រូវតែជំរាបជូននាយកសាលា អំពីកម្មវិធីនានា ដែលនឹងត្រូវអនុវត្ត ក្នុងសាលារៀន ។

**អ្នកសំរបសំរួលក្លឹបបរិស្ថាន និងការលើកកំពស់អ្នកគ្រូ**

ដោយសិស្សសាលាក្មេងៗ មិនអាចមានសមត្ថភាព **ដើម្បីរៀបចំ និងដឹកនាំក្លឹបដោយខ្លួនឯងបាន** វាជាការចាំបាច់អោយមានគ្រូបង្រៀនណែនាំ **ដើម្បីធ្វើការបង្កើត និងគ្រប់គ្រងក្លឹប ។ នៅ**ក្នុងឯកសារណែនាំនេះ យើងហៅបុគ្គលនេះ ជាអ្នកសំរបសំរួល**ក្លឹបបរិស្ថាន ដោយសារតួនាទី របស់**បុគ្គលនេះ មិនមែនដូចគ្រូបង្រៀនទូទៅទេ ប៉ុន្តែភាគច្រើនជា**អ្នកសំរបសំរួលតែប៉ុណ្ណោះ ។ រាល់គ្រូ**បង្រៀននានា ដែលមានចំណាប់អារម្មណ៍ទៅនឹងបរិស្ថាន **អាចដឹកនាំបង្កើតក្លឹបនេះបាន ។ ហើយ**អាចជានាយកសាលា នាយករង គ្រូបង្រៀន រឺបណ្ណារក្ស ។ **ជាគោលគំនិត ប្រសិនបើអ្នកទាំងនេះ**រស់នៅជិតសាលារៀន វាមានការងាយស្រួល សំរាប់ពួក**គាត់ធ្វើការរៀបចំការប្រជុំក្លឹបបរិស្ថាន ។** គាត់គួរតែមានឧត្តមគតិស្ម័គ្រចិត្ត និងមានការចាប់អារម្មណ៍**ខ្លាំងទៅលើបរិស្ថាន និងការដឹកនាំ**សកម្មភាពក្លឹប ។ សូមមើលការពណ៌នា អំពីតួនាទីការងារ**របស់អ្នកសំរបសំរួលក្លឹប ក្នុងឧបសម្ព័ន្ធ**៣ ដែលអាចជួយដល់ការកំណត់ជ្រើសរើស បេក្ខជនអោយបាន**ត្រឹមត្រូវ ។**

ប្រសិនបើគំនិតផ្តួចផ្តើម ដើម្បីបង្កើតក្លឹបនេះ ចេញពីអង្គការ**ក្រៅរដ្ឋាភិបាល** ឬអ្នកមកពីក្រៅណាមួយ ការជ្រើសរើសអាចចាប់ផ្តើម ដោយធ្វើការជំរាបជូន **រាល់បុគ្គលិកទាំងអស់ក្នុង**សាលា អំពីកម្មវិធីទាំងឡាយតាមរយៈការប្រជុំគ្រូបង្រៀន ឬតាមរយៈ**លិខិតណែនាំ ។** បុគ្គលិកទាំងនេះរួមមាន លោកគ្រូ អ្នកគ្រូ បណ្ណារក្ស និងបុគ្គលិករដ្ឋបាល ។ **ដោយសារតែសកម្មភាព**ក្លឹបបរិស្ថាន តំរូវអោយមានកិច្ចសហការជាមួយនឹងលោកគ្រូ អ្នកគ្រូ បុគ្គលិក **និងសិស្សដែលមក**ពីសាលារៀនផ្សេងៗទៀត ដូចនេះវាជាកត្តាមួយដ៏ប្រសើរ សំរាប់ធ្វើការជំរាបជូនដំណឹងដល់អ្នកទាំងនោះ អំពីក្លឹបនេះពីដំបូងមក ។

ជាមួយគ្នានោះដែរ វាជាកត្តាមួយដ៏សំខាន់ដើម្បីជំរុញអ្នកគ្រូ អោយធ្វើការសំរបសំរួលក្លឹប ។ ដោយការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពជាច្រើន តែងតែធ្វើឡើងសំរាប់លោកគ្រូ ហើយស្ត្រីជាច្រើនមានឱកាសតិចតួចបំផុតសំរាប់ការចូលរួម ។ យើងមានការកត់សំគាល់ឃើញថា អ្នកគ្រូជាច្រើន តែងតែមានមានគំនិតថ្មីៗជាមួយសិស្ស ហើយពួកគេព្យាយាមធ្វើការ យ៉ាងសកម្មដូចជាលោកគ្រូៗដែរ ។ ជាមួយគ្នានោះដែរ សក្តានុពលដ៏សំខាន់របស់ស្ត្រី ត្រូវបានច្រានចោល ដោយមានមនុស្សជាច្រើនយល់ឃើញថា ស្ត្រីមានការងារផ្ទះធ្វើជាច្រើន ឬដែលនិយាយដោយមិនសមរម្យថា ស្ត្រីពុំមានសមត្ថភាពធ្វើការទាំងនេះឡើយ ។ ស្ត្រីអាចនឹងមានការអៀនខ្មាស់ច្រើន ហើយខ្លាចមិនហ៊ានតាំងចិត្ត ឬចាប់អារម្មណ៍ក្នុងការសំរបសំរួលក្លឹបបរិស្ថាននេះឡើយ ។ ដូចនេះ ហើយ វាជាការចាំបាច់ ដើម្បីជំរុញអោយអ្នកគ្រូៗដាក់ឈ្មោះមុខគេ ។

ចំពោះអង្គការម្លប់បៃតង យើងបានអនុញ្ញាតិអោយសាលា ធ្វើការជ្រើសរើសអ្នកសំរបសំរួលក្លឹបបរិស្ថាន ដោយខ្លួនគេនៅពេលប្រជុំបុគ្គលិកប្រចាំខែ ។ ទោះជាយ៉ាងណា យើងនឹងមិន ផ្តល់ជាអនុសាសន៍ទេ ដោយលទ្ធផលកន្លងមកឃើញថា លោកគ្រូបង្រៀនចាស់ៗភាគច្រើនត្រូវ បានអនុគ្រោះ ហើយសារៈសំខាន់នៃការជ្រើសរើសអ្នកគ្រូ មិនត្រូវបានទទួលស្គាល់ឡើយ ។ បញ្ហានេះអាចដោះស្រាយបានដោយសារការបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យជ្រើសរើស (ផ្អែកទៅលើ ការពណ៌នាអំពីតួនាទីការងារ





ក្នុងឧបសម្ព័ន្ធ៣) ហើយព្រមទាំងស្នើសុំគ្រូ ដែលមានការចាប់ អារម្មណ៍អោយសរសេរ លិខិតចំណាប់អារម្មណ៍ ឬការបញ្ចេញទស្សនៈ ។ ក្នុងករណីសាលារៀន ដែលមានបណ្ណាល័យ បណ្ណារក្សគឺជាអ្នកសំរបសំរួលក្លឹបបរិស្ថានមួយដ៏ល្អ ដោយសារគាត់មាន ការទទួលខុសត្រូវរួចជាស្រេចទៅហើយ សំរាប់ការរៀបចំបង្កើតគំនិតសកម្មភាពសិក្សា ជាមួយ សិស្សនៅក្រៅម៉ោងសិក្សា ។ នៅពេលដែលត្រូវបានជ្រើសរើសរួចហើយអ្នកសំរបសំរួលក្លឹបបរិស្ថានត្រូវទទួលខុសត្រូវ

នូវការសំរបសំរួលរៀបចំបង្កើត និងដំណើរការក្លឹប ។ ទោះយ៉ាងនេះក្តី លោកគ្រូ អ្នកគ្រូដទៃទៀត គួរត្រូវបានអញ្ជើញ និងជួយជំរុញ នៅពេលចាប់ផ្តើមដំបូងសំរាប់ កិច្ចសហការ និងចូលរួមនូវរាល់សកម្មភាពនានារបស់ក្លឹប ។

**សមាជិកក្លឹប**

គ្រប់ក្លឹបនិមួយៗ **ត្រូវមានសមាជិកសិស្សពី ២៥-៣៥នាក់ ។ ចំនួននេះ គឺល្មមល្អ** សំរាប់ការអនុវត្តន៍សកម្មភាព **ដែលអាចទទួលបាននូវលទ្ធផលជាវិជ្ជមាន ហើយងាយស្រួល ដែលអាច**ងាយស្រួលគ្រប់គ្រងបាន **សំរាប់អ្នកសំរបសំរួល ។ កត្តាមួយដ៏សំខាន់ ក្នុងការជ្រើសរើសសិស្ស គឺពួកគេមានចំណាប់អារម្មណ៍ និងឆន្ទៈដើម្បីចូលរួមរាល់សកម្មភាពរបស់ក្លឹប ។ សមាជិក ក្លឹបគួរតែ**ជាសិស្សថ្នាក់ទី៤ ទី៥ និងទី៦ ។ នៅក្នុងកំរិតនេះ កុមារមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបង្កើតសកម្មភាពដោយខ្លួនឯង ហើយកុមារទាំងអស់អាចអាន និងសរសេរបាន ។ ដោយការទទួលយក សិស្សមានកំរិតខុសៗគ្នានេះហើយ ធ្វើអោយមានការផ្លាស់ប្តូរពីកំរិតមួយ ទៅកំរិតមួយមានការងាយស្រួល ពីព្រោះសិស្សដែលរៀន ថ្នាក់ទាបជាង និងអាចស្រូបយកនូវបទពិសោធន៍ផ្សេងៗពីក្លឹប ដើម្បីបន្តទៅឆ្នាំ បន្ទាប់ទៀត ។



អ្នកសំរបសំរួលក្លឹបបរិស្ថាន អាចចាប់ផ្តើមធ្វើការណែនាំនូវគោលគំនិត របស់ក្លឹបបរិស្ថាន នៅពេលជួបជុំគ្នាពេលព្រឹក ដោយរួមមានទាំងពត៌មានស្តីពី គោលបំណងទូទៅ ការកំណត់ពេលវេលា និងការអនុញ្ញាតពី ឪពុកម្តាយ ។ លោកលោកស្រីអាចបង្កើតសេចក្តីប្រកាស នៅតាមសាលារៀន អំពីកម្មវិធី (សូមមើល ឧបសម្ព័ន្ធ៤ សំរាប់គំរូលិខិតប្រកាស) ហើយសួរដល់សិស្សដែលមានចំណាប់អារម្មណ៍ ចុះឈ្មោះជាអ្នកស្ម័គ្រចិត្ត ។ បើសិនចំនួន សិស្សច្រើនជាង៣៥នាក់បានចុះឈ្មោះ នោះលោកគ្រូ អ្នកគ្រូ អាចដាក់ការងារតូចមួយ ដើម្បីអោយពួកគេធ្វើការវិនិច្ឆ័យលើចំណាប់អារម្មណ៍ និងការសន្យារបស់គេ ។ ដូចជាគ្រប់ សិស្សទាំងអស់ ដែលបង្ហាញពីការចាប់អារម្មណ៍ ក្នុងការចូល រួមក្នុងក្លឹប នឹងត្រូវបាន សុំអោយធ្វើការ អង្កេតពីប្រភេទដើមឈើ **ដែលមាននៅក្នុងសហគមន៍ របស់គេ ហើយនាំមកវិញ** នូវលទ្ធផលជូនលោកគ្រូ អ្នកគ្រូ ។ ចេញពីលទ្ធផល**នេះលោកគ្រូ អ្នកគ្រូ អាចធ្វើការពិចារណា ទៅលើការប្តេជ្ញាចិត្តរបស់ពួកគេបាន ។** មួបបៃតងពិនិត្យ**ឃើញថា វាជាកត្តា មួយដ៏សំខាន់ ក្នុងការរក្សាទុកកន្លែងខ្លះនៅក្នុងក្លឹបសំរាប់កុមារី** ហើយយើងជំរុញ**លោកគ្រូ អ្នកគ្រូ អោយមាននូវការទទួលយកយ៉ាងតិច ៥០ភាគរយនៃ** សមាជិកក្លឹបជាកុមារី ។ **មូលហេតុដែលធ្វើ ដូច្នេះគឺដើម្បីអោយបាននូវឱកាសស្មើភាពគ្នារបស់កុមារីក្នុងការចូលរួម** និងសិក្សា**អំពីបរិស្ថាន ។**

**ដើម្បីបញ្ជាក់ពីសមាជិកភាពរបស់ក្លឹប លោកគ្រូ អ្នកគ្រូត្រូវធ្វើលិខិតជូនឪពុក** ម្តាយ សិស្ស **ដើម្បីសុំការអនុញ្ញាត ។**

**ការអនុញ្ញាត និងការចូលរួមរបស់អាណាព្យាបាល**

វាជាការចាំបាច់ សំរាប់រាល់ឪពុក ម្តាយរបស់សិស្សដែលមានចំណាប់អារម្មណ៍ ត្រូវបានជំរាបជូនអំពីសកម្មភាពក្លឹប សារៈប្រយោជន៍សំរាប់សិស្ស និងការប្តេជ្ញារបស់សិស្សជាចាំបាច់ ។ មធ្យោបាយមួយដើម្បីអនុវត្តការងារនេះ គឺធ្វើលិខិតជូនឪពុក ម្តាយសិស្ស ដោយមានភ្ជាប់ជាមួយ ទំរង់ចុះឈ្មោះសំរាប់អោយគាត់បំពេញ (សូមមើល ឧបសម្ព័ន្ធ៥ គំរូលិខិត) ។ រាល់ទំរង់ចុះឈ្មោះ ទាំងអស់ ក្រោយពីបានចុះហត្ថលេខា ហើយត្រូវរក្សាទុកនៅក្នុងឯកសារសំភារៈក្លឹបបរិស្ថាន ។ ជាងនេះទៅទៀត ត្រូវរៀបចំកិច្ចប្រជុំជាមួយឪពុក ម្តាយសិស្ស ដើម្បីបញ្ជាក់អោយបានច្បាស់អំពី គោលបំណង និងទិសដៅរបស់ក្លឹប ។ បើសិនជាកំរិតការអាននៅក្នុងមូលដ្ឋានភូមិ មានកំរិតទាប ត្រូវធ្វើការហៅប្រជុំ ដោយមានធ្វើជាលិខិតអញ្ជើញផងដែរ ។ ឪពុក ម្តាយសិស្សគួរមានការយល់ដឹង អំពីសារៈសំខាន់សំរាប់កូនរបស់ខ្លួន ក្នុងការចូលរួមប្រជុំក្លឹបអោយទៀងទាត់ ។ ក្នុងករណីខ្លះ យើង ពិនិត្យឃើញថា ឪពុក ម្តាយសិស្សបានតំរូវអោយកូនរបស់ខ្លួនជួយធ្វើស្រែចំការ នៅតាមរដូវកាល មួយចំនួន ហើយដែលពេលនោះសិស្សក្លឹបភាគច្រើន តែងតែអវត្តមាន ។ ដូច្នេះហើយ វាមានសារៈ សំខាន់ណាស់ ក្នុងការជំរាបជូនឪពុក ម្តាយសិស្ស មុនពេលធ្វើកិច្ចសន្យាក្នុងការអនុញ្ញាតអោយកូនចូលរួមក្លឹប ។ ការប្រជុំសមាជិកលើកដំបូង អាចជាចំណុចចាប់ផ្តើមដ៏ល្អមួយក្នុងការជំរុញអោយ មានការចូលរួម និងការគាំទ្រពីឪពុក ម្តាយសិស្ស ពេញមួយឆ្នាំ ។

**ការកំណត់តំរូវការ**

គោលបំណងនៃការកំណត់តំរូវការ គឺផ្តោតទៅលើសេចក្តីត្រូវការរបស់សាលា បញ្ហានានា ក៏ដូចជាតំរូវការសំរាប់អនុវត្តន៍កម្មវិធីផងដែរ ។ នៅពេលតំរូវការទាំងនោះ ត្រូវបានកំណត់បានយ៉ាងត្រឹមត្រូវ វានឹងមានការងាយស្រួល សំរាប់ដំណើរការកម្មវិធី ហើយសាលា និងសិស្សក៏នឹងទទួល បាននូវផលប្រយោជន៍ជាច្រើន ពីកម្មវិធីនេះ ។ ការកំណត់តំរូវការ អាចត្រូវបានអនុវត្តធ្វើឡើង ដោយលោកគ្រូ អ្នកគ្រូ ឬដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែវាមានសារៈសំខាន់ណាស់ បើមានការចូលរួមដ៏ទូលំទូលាយ ពីអ្នកពាក់ព័ន្ធដទៃទៀតដូចជា លោកគ្រូ អ្នកគ្រូ ការិយាល័យរដ្ឋបាល សមាជិកសហគមន៍ ព្រះសង្ឃ គណៈកម្មការវត្ត និងសិស្សានុសិស្ស ។

ការកំណត់តំរូវការ អាចត្រូវបានអនុវត្តធ្វើឡើងម្តងទៀត ដោយសិស្សផ្ទាល់ ហើយដែលមានលក្ខណៈសាមញ្ញជាងមុន និងដោយផ្តោតសំខាន់ទៅលើបញ្ហាបរិស្ថាន ។ ដំណើរការនេះ អាចធ្វើអោយសិស្សមានការយល់ដឹងច្រើន អំពីបញ្ហានានា ដែលពួកគេជួបប្រទះ និងតំរូវការធនធានផ្សេងៗ ដែលពួកគេត្រូវការប្រើប្រាស់ ។ សូមអាន ឧបសម្ព័ន្ធ៦: គំរូទំរង់កំណត់តំរូវការ ។

### បទបញ្ជាផ្ទៃក្នុង និងការសន្យារបស់ក្លឹប



ក្នុងការប្រជុំលើកដំបូង សមាជិកក្លឹបបរិស្ថាន អាចធ្វើការពិភាក្សា និងបង្កើតតួនាទីក្លឹប ដែលពួកគេទាំងអស់គ្នាត្រូវអនុវត្ត ។ ជាងនេះទៅទៀត សិស្សត្រូវមានការសន្យាថា គ្រប់សមាជិកទាំងអស់ ត្រូវអនុវត្ត និងប្រកាន់ខ្ជាប់ ។ ការសន្យា រួមមានបញ្ហានានា ដែលពាក់ព័ន្ធ ទៅនឹងបរិស្ថាន ជីវិតរស់នៅផ្ទាល់របស់សិស្ស និងសកម្មភាពនានា ដែលអាចសំរេចបានជាក់ស្តែង ។ ជាតួយ៉ាង គ្រប់សមាជិកក្លឹបម្នាក់ត្រូវប្តេជ្ញា:

- ខ្ញុំនឹងខិតខំអស់ពីសមត្ថភាពរបស់ខ្ញុំ ដើម្បីកែលំអ នូវបរិស្ថានជុំវិញផ្ទះរបស់ខ្ញុំ សាលារៀនខ្ញុំ និងសហគមន៍របស់ ខ្ញុំ។ សំរាប់ការប្តេជ្ញានេះ ខ្ញុំនឹងដាំ ព្រមទាំងថែរក្សាដើមឈើមួយដើម ក្នុងមួយឆ្នាំ ។
- ខ្ញុំនឹងមិនញ៉ាំសាច់សត្វព្រៃ ។
- ខ្ញុំនឹងមិនខ្ជះខ្ជាយក្រដាស ។
- ខ្ញុំនឹងមិនពង្រាយសំរាម ។
- ហើយខ្ញុំនឹងសិក្សាបន្ថែមទៀត អំពីបរិស្ថាន ។

### ពេលវេលាអនុវត្តសកម្មភាព

វាជាការចាំបាច់ ក្នុងការកំណត់ពេលវេលាក្រៅម៉ោងសិក្សា យ៉ាងតិច២ម៉ោងក្នុងមួយ សប្តាហ៍ សំរាប់កិច្ចការរបស់ក្លឹបបរិស្ថាន។ ពេលវេលាខ្លះ នឹងត្រូវចំណាយ សំរាប់ការប្រជុំទូទៅស្តីពី ប្រធានបទដូចជាការធ្វើផែនការ និងការធ្វើរបាយការណ៍ ។ ពេលវេលាខ្លះទៀត នឹងត្រូវចំណាយ លើការបណ្តុះបណ្តាលសិស្សស្តីពីបរិស្ថាន និងការពង្រឹងចំណេះដឹងរបស់ពួកគេ ព្រមទាំងការពង្រឹង សមត្ថភាពផ្សេងៗជាច្រើនទៀត ។ ហើយពេលវេលាដែលនៅសល់ នឹងត្រូវចំណាយដើម្បីធ្វើគំរោង និងអនុវត្តសកម្មភាពដែលបានធ្វើផែនការរួចហើយ ។ សកម្មភាពខ្លះ ក៏អាចនឹងតំរូវអោយសិស្សធ្វើ នៅក្រៅម៉ោងសាលាផងដែរ ។ តាមបទពិសោធន៍របស់យើង ក្លឹបរបស់សាលាបឋមសិក្សា ភាគច្រើន បានបង្កើតពេលវេលាសំរាប់ប្រជុំក្លឹបរបស់គេនៅថ្ងៃព្រហស្បតិ៍ ដោយថ្ងៃនោះជាថ្ងៃប្រជុំបច្ចេកទេស សំរាប់លោកគ្រូ អ្នកគ្រូ ហើយមានពេលទំនេរច្រើនពីការបង្រៀនផង ដូច្នេះពុំមានអ្វីប៉ះពាល់ដល់ ការបង្រៀនតាមកម្មវិធីនោះឡើយ ។ ចំពោះកំរងអនុវិទ្យាល័យវិញ ត្រូវធ្វើការប្រជុំរបស់គេដោយ យោងទៅតាមកាលវិភាគសិក្សា ។ ឧទាហរណ៍ បើសិនសិស្សមានកម្មវិធីសិក្សា នៅពេលព្រឹកគេនឹង ធ្វើការប្រជុំនៅពេលល្ងាច ឬផ្ទុយទៅវិញ ។

### ឈ្មោះក្លឹប

សិស្សនឹងទទួលបានអត្តសញ្ញាណពិសេសមួយ បើសិនជាក្លឹបរបស់គេ ត្រូវបានកំណត់ អត្តសញ្ញាណបួយ ។ ជាការពិត ក្លឹបត្រូវតែមានឈ្មោះមួយសំគាល់ ហើយឈ្មោះនេះគួរតែត្រូវបាន ជ្រើសរើសដោយសិស្សខ្លួនឯងនៅពេលប្រជុំលើកដំបូង ។

### រូបសញ្ញាសំគាល់ក្លឹប

អត្តសញ្ញាណរបស់ក្លឹប នឹងកាន់តែប្រសើរឡើង បើសិនមានរូបសញ្ញាសំគាល់មួយ ។ រូប សញ្ញានេះ អាចដាក់នៅលើសំភារៈរបស់ក្លឹប ដូចជា លិខិត ធុងសំរាម និងបដាពិតមាននានា ដែល បានធ្វើឡើងដោយសមាជិកក្លឹប ។ សមាជិកក្លឹប ក៏អាចមានផងដែរ នូវប័ណ្ណសំគាល់ ឬខ្សែពាក់ឡេវ

ដែលគេអាចពាក់ ទៅសាលារៀននៅថ្ងៃប្រជុំក្លឹប ។

**បទចំរៀង និងកំណាព្យរបស់ក្លឹប**

សមាជិកក្លឹប អាចតាក់តែងបទចំរៀង ហើយច្រៀងសំរាប់ប្រចាំក្រុមរបស់គេ ឬតែងជាកំណាព្យ ។ បទចំរៀង ឬកំណាព្យនេះ អាចត្រូវបានយកមកច្រៀង នៅពេលចាប់ផ្តើមប្រជុំក្លឹប ឬសកម្មភាពផ្សេងៗ និងនៅពេលមានពិធីសំខាន់ៗនានា ។

**ការបង្កើតការដឹកនាំក្លឹបបរិស្ថាន**

<u>អ្នកដឹកនាំក្លឹប</u>

អ្នកសំរបសំរួលក្លឹបបរិស្ថាន ផ្តល់នូវការណែនាំ សំរាប់ការធ្វើសកម្មភាពផ្សេងៗរបស់ក្លឹប ។ ក្លឹបភាគច្រើន បានបង្ហាញពីតំរូវការ អោយមានអ្នកដឹកនាំក្លឹប ជាសិស្សចំនួន៤នាក់ ដែលនឹងទទួលខុសត្រូវ នូវរាល់កិច្ចការពាក់ព័ន្ធទៅនឹងដំណើរការក្លឹប ។

<u>ការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំក្លឹប</u>

ជាទូទៅ អ្នកដឹកនាំក្លឹប ត្រូវបានបោះឆ្នោតជ្រើសរើស ដោយសមាជិកក្លឹប ។ ដំបូង គ្រូបង្រៀន ត្រូវបញ្ជាក់អំពីតួនាទីនិងការទទួលខុសត្រូវ សំរាប់អ្នកដឹកនាំក្លឹបនីមួយៗ ហើយពន្យល់ពីការបោះឆ្នោតជ្រើសរើស ។ គ្រូសម្របសម្រួល ត្រូវរៀបចំ ធ្វើការតែងតាំងគ្រប់បេក្ខជនសិស្ស (អ្នកស្ម័គ្រចិត្ត) ដោយសរសេរឈ្មោះ នៅលើក្តារខៀន ។ បន្ទាប់មក គ្រូសម្របសម្រួល នឹងសុំអោយសមាជិកក្លឹបទាំងអស់ សរសេរឈ្មោះបេក្ខជនបួននាក់ ដែលពួកគេគាំទ្រអោយធ្វើជាអ្នកដឹកនាំក្លឹប នៅលើក្រដាសតូចមួយ ។ ដើម្បីអោយមានលក្ខណៈត្រឹមត្រូវថែមទៀត ការបោះឆ្នោតជ្រើសរើស គួរធ្វើឡើងជាសំងាត់ ដូច្នេះសិស្ស អាចធ្វើការសំរេចចិត្តដោយឯករាជ្យ ។ សិស្សបួននាក់ដែលទទួលសំលេងច្រើនជាងគេ នឹងក្លាយជា អ្នកដឹកនាំក្លឹប ។ អ្នកដឹកនាំក្លឹប ជាសិស្សដែលបានទទួលសំលេងគាំទ្រច្រើនជាងគេ ហើយអ្នកផ្សេងៗទៀត ទទួលសំលេងតាមលំដាប់ជាបន្តបន្ទាប់ ។ ដើម្បីផ្តល់ឱកាសដល់កុមារ ក្នុងការទទួលខុសត្រូវបន្ថែមទៀតនោះ អ្នកដឹកនាំក្លឹបគួរធ្វើការផ្លាស់ប្តូរ សំរាប់រយៈពេល ៦ ខែ ឬមួយឆ្នាំសិក្សារបស់សាលា ។

អ្នកដឹកនាំក្លឹបអាចមានដូចតទៅ:

<u>ប្រធានក្លឹប</u>

ប្រធានក្លឹប ត្រូវបង្កើតរបៀបវារៈជាមួយលេខាធិការ កោះហៅការប្រជុំ ទំនាក់ទំនង ជាមួយគ្រូ ការិយាល័យរដ្ឋបាលសាលា ។ល។ តំណាងអោយសមាជិកក្លឹបទាំងអស់ ប្រធានក្លឹបត្រូវ ទទួលខុសត្រូវដឹកនាំរៀបចំកម្មវិធីផ្សេងៗ ធ្វើផែនការ និងគ្រប់គ្រង គំរោងសកម្មភាពផ្សេងៗ ។

<u>លេខាធិការ</u>

លេខាធិការត្រូវរក្សាកំណត់ហេតុប្រជុំ (រួមទាំងបញ្ជីវត្តមាន) ផ្ញើរកំណត់ហេតុទៅអ្នក ពាក់ព័ន្ធ ដូចជា នាយកសាលា និង ឪពុក ម្តាយសិស្ស រក្សាទុកនូវឯកសារវត្តមានរបស់សមាជិក រៀបចំរបាយការណ៍សកម្មភាព នៅរាល់ពេលចប់កម្មវិធីសិក្សានីមួយៗ និងធ្វើរបាយការណ៍បញ្ចប់ នៅដំណាច់ឆ្នាំសិក្សា ។

<u>ហិរញ្ញិក</u>

ហិរញ្ញិកត្រូវប្រមូល និងគ្រប់គ្រងថវិការរបស់ក្លឹប រក្សាទុកបញ្ជីគណនេយ្យនៃថវិកា ដែលបានទទួល និងចំណាយ ។ នេះជាបទពិសោធន៍មួយដ៏ល្អ សំរាប់សិស្សធ្វើការគ្រប់គ្រងមូលនិធិតូចៗដោយខ្លួនឯង ប៉ុន្តែអ្នកសំរបសំរួលក្លឹប ត្រូវផ្តល់ជាគំនិតខ្លះៗ ។ ខាងក្រោមនេះ គឺជាគំរូអំពីការ គ្រប់គ្រងប្រព័ន្ធបញ្ជីគណនេយ្យ: តារាងចំណូល និងចំណាយ:

ឈ្មោះក្លឹប: ...............................

សាលា: ....................................

| កាលបរិច្ឆេទ | បរិយាយ | ចំណូល | ចំណាយ | តុល្យភាព |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

<u>អ្នកគ្រប់គ្រងសំភារៈ</u>

ជាអ្នកទទួលខុសត្រូវសុវត្ថិភាពសំភារៈ បរិក្ខារ សៀវភៅ ។ល។ របស់ក្លឹប ។ ជាទូទៅ នាយកសាលា នឹងផ្តល់កន្លែងតូចមួយ នៅក្នុងការិយាល័យរដ្ឋបាល ឬបណ្ណាល័យ ជាកន្លែងដែលក្លឹបអាចរក្សាដោយសុវត្ថិភាព នូវសំភារៈបរិក្ខាររបស់ពួកគេ ។

**ដំណើរការក្លឹបបរិស្ថាន**

ការសិក្សាតាមបទពិសោធន៍

ការចាប់ផ្តើមដំណើរការដំបូង មានឱកាសជាច្រើន សំរាប់ក្លឹបបរិស្ថានអនុវត្តប្រកបដោយប្រសិទ្ធិភាព **តែមានសកម្មភាពខ្លះ ក៏បរាជ័យដែរ។ វាជាកត្តាមួយដ៏សំខាន់ ដែលមិនត្រូវធ្វើ**អោយសិស្សមានការបាក់ទឹកចិត្ត **ហើយត្រូវធ្វើការសិក្សានូវបទពិសោធន៍ទាំង វិជ្ជមាន និង** អវិជ្ជមាន។ ចូរកុំខ្លាចក្នុងការអនុវត្តសាកល្បង **និងព្យាយាមបង្កើតនូវគំនិតថ្មីៗ។**

*ចូរចងចាំនូវ:*

ពេលអ្នកឮ អ្នកនឹងភ្លេច

ពេលអ្នកឃើញ អ្នកនឹងចាំ

ពេលអ្នកធ្វើ អ្នកនឹងយល់"។

## ការចូលរួម និងការបង្កើតភាពជឹកនាំរបស់សិស្ស

វាជាកត្តាមួយមានតំលៃបំផុត **ដើម្បីជំរុញការគិតចំប្រើងប្រែងព្យាយាម និងធានាអោយ**បាននូវក្លឹបបរិស្ថាន ដែលមានសមត្ថភាពដំណើរការ ដោយ**សិស្សខ្លួនឯង។ វាជាចំណុចមួយដ៏សំខាន់**ផងដែរថា គ្រូសំរបសំរួល មិនត្រូវគ្របសង្កត់ការប្រជុំ **ដោយធ្វើការដឹកនាំ និងធ្វើសេចក្តីសំរេចលើ**សកម្មភាពដែលកំពុងត្រូវអនុវត្តឡើយ។ ការប្រជុំ **មិនគ្រាន់តែជាមធ្យោបាយមួយ សំរាប់ទំនាក់**ទំនងប៉ុណ្ណោះទេ តែជាឱកាសមួយ **សំរាប់អោយពួកគេធ្វើការ ផ្លាស់ប្តូរគំនិតយោបល់ក្នុងចំណោម**សិស្សគ្នាគេទាំងនោះ។ គ្រប់សមាជិកទាំងអស់ ត្រូវជំរុញអោយ**មានការបញ្ចេញមតិយោបល់។** ការ បង្កើតកិច្ចប្រជុំតាមមធ្យោបាយនេះ វាអាចមាន**ការយឺតយ៉ាវ ហើយលំបាកច្រើន** ក្នុងការធ្វើសេចក្តី សំរេចនានា (ជាពិសេសនៅពេលចាប់ផ្តើមដំបូង) ប៉ុន្តែ **ដំណើរការនេះ**នឹងមានការអភិវឌ្ឍកែលំអនូវសមត្ថភាពរបស់សិស្សធ្វើការពិចារណាដោយខ្លួនឯង **ហើយនឹងក្លាយ**ជាអ្នកធ្វើសេចក្តីសំរេចមួយ ប្រកបដោយប្រសិទ្ធភាព។ ខុសពីការបង្រៀនធម្មតា តួនាទីរបស់អ្នកសំរបសំរួលមិនដូចជាតួនាទីរបស់គ្រូបង្រៀនឡើយ គ្រាន់តែធ្វើជាអ្នកសំរបសំរួលមួយរូបប៉ុណ្ណោះ។ នេះមានន័យថាក្នុងពេលប្រជុំ រឺធ្វើសកម្មភាពនានា អ្នកសំរបសំរួល មិនត្រូវធ្វើការ ដឹកនាំ ឬផ្តល់មេរៀនដល់សិស្សទាំងនោះទេ តែត្រូវជួយសំរបសំរួលដល់កុមារ អោយដំណើរការ កម្មវិធីប្រកបដោយជោគជ័យ។ គ្រូត្រូវអង្គុយ មើលពីក្រោយយ៉ាងស្ងៀមស្ងាត់ ហើយទុកអោយ សិស្សបង្កើតនូវរបៀបវារៈ ដឹកនាំការពិភាក្សា និង ធ្វើសេចក្តីសំរេចដោយខ្លួនគេ។ គ្រូត្រូវមាន វត្តមាននៅទីនោះកន្លែង ដើម្បីសំរួលដល់សិស្សធ្វើអ្វីមួយ អោយបានសំរេច ត្រូវរំលឹកដល់ពួកគេ ពីកិច្ចសន្យា និងនីតិវិធីផ្សេងៗ ហើយជួយដោះស្រាយពួកគេ បើសិនគំនិតទាំងនោះ មានការភ័ន្តច្រឡំ រឺមាន ទំនាស់អ្វីមួយកើតឡើង ត្រូវផ្តល់យោបល់ និងជួយធ្វើ សេចក្តីសន្និដ្ឋាន។ បទ្ទសាស្រ្ត ការចូលរួមថ្មីនេះ អាចមានផលលំបាកក្នុងការសម្របតាមសំរាប់គ្រូ បង្រៀនមួយចំនួន ប៉ុន្តែវាជា កត្តាមួយដ៏សំខាន់ ក្នុងការបង្កើតនូវសមត្ថភាពសិស្ស ដើម្បីធ្វើការ ពិចារណាដោយខ្លួនគេផ្ទាល់។ បរិយាកាសក្នុងការចូលរួម ដំណើរការ ប្រកបដោយលទ្ធផលជាក់ស្តែង ផ្តល់អោយកុមារមាន ការយល់ដឹង អំពីការគ្រប់គ្រងលើបញ្ហា នានា នៅក្នុងជីវិតរបស់គេ។ ហើយគេ អាចកសាងនូវ ជំនាញដ៏សំខាន់ ព្រមទាំងបទពិសោធន៍ជាច្រើន ដែលអាចប្រើប្រាស់បាននូវរាល់កត្តា សំខាន់ៗ នៃជីវិតដូចជា ការបង្កើតគំនិតថ្មីៗ ការពិចារណា ការពិភាក្សា ការធ្វើវិភាគ ទំនាក់ទំនង ការធ្វើការជាក្រុមការពិគ្រោះចរចា ការកំណត់បញ្ហានានា និងការដោះស្រាយរាល់បញ្ហា។ សំខាន់ជាងនេះទៀត ពួកគេសិក្សាពីការធ្វើផែនការ និងអនុវត្ត សកម្មភាព។

ការរៀបចំកិច្ចប្រជុំក្លឹប

មានជំហានសំខាន់ខ្លះៗ ដែលត្រូវធ្វើការពិចារណា ក្នុងការរៀបចំដំណើរការប្រជុំក្លឹប។ គ្រូសម្របសម្រួល អាចជួយរៀបចំនូវជំហានទាំងនេះ ប៉ុន្តែសិស្សត្រូវទទួលខុសត្រូវ ក្នុងដំណើរការនៃកិច្ចប្រជុំនេះ។

- ការធ្វើកាលវិភាគប្រជុំ (សារៈសំខាន់នៃវត្តមាន និងមកទាន់ពេលវេលា)

ដើម្បីធានាអោយបាន នូវរាល់សមាជិកក្លឹបទាំងអស់ អាចចូលរួមប្រជុំ ពួកគេត្រូវធ្វើ កាលវិភាគជាមុនហើយនៅពេលដែលសមស្របសំរាប់សមាជិកទាំងអស់។ មុនពេលចាប់ផ្តើមការប្រជុំ លេខាធិការត្រូវចុះបញ្ជីវត្តមាន។ ប្រសិនបើសិស្សណាមួយមានបញ្ហាមកយឺត ឬអវត្តមាន ក្រុមត្រូវសំរេចធ្វើការពិន័យដូចជា ការព្រមាន និងការបញ្ឈរជើង។ អ្នកសំរបសំរួល គួរពន្យល់អំពី ផលលំបាក នៃដំណើរការប្រជុំប្រកបដោយប្រសិទ្ធិភាពបើសិនសមាជិកក្រុមមិនមកប្រជុំឬមកយឺតយ៉ាវ

ពីព្រោះការចូលរួមយោបល់ របស់រាល់សមាជិកទាំងអស់ ពោលសារៈសំខាន់ណាស់ ហើយបើមានសមាជិកណាមកយឺតយ៉ាវ ឬអវត្តមាន នោះ គេមិនមិនបានដឹងនូវរាល់ពត៌មានដែលបានចែករំលែក នៅក្នុងអង្គប្រជុំឡើយ ។

- **ការបង្កើតរបៀបវារៈ** ( អ្វីជាទិសដៅ និងគោលបំណងនៃការប្រជុំ? )

**ដើម្បីធ្វើអោយកិច្ចប្រជុំមានអត្ថន័យ និងប្រកបដោយបរិយាកាសរីករាយ** វាជាការចាំបាច់ត្រូវតែបង្កើតរបៀបវារៈ ។ បើមិនដូច្នេះទេ ការពិភាក្សានឹងប្រព្រឹត្តិទៅដោយគ្មានបែបបទ ឬសេចក្តីសន្និដ្ឋានណាមួយច្បាស់លាស់បានឡើយ ។ ការប្រជុំជាឱកាសមួយដើម្បី:

- បញ្ជាក់ការសន្យាឡើងវិញដល់សមាជិកក្លឹប ដោយអាននូវការសន្យារបស់គេ ។
- រាយការណ៍អំពីសកម្មភាពដែលកំពុងអនុវត្ត ។
- ធ្វើផែនការសំរាប់កម្មវិធីផ្សេងៗ និងសកម្មភាពអនាគត ។
- សិក្សាពីអ្វីៗដែលថ្មីពាក់ព័ន្ធទៅនឹងបរិស្ថាន ។
- បង្ហាញនូវភាពប៉ិនប្រសព្វ ។
- បង្កើតភាពរីករាយ និងមានសារៈប្រយោជន៍ ។

- ការធ្វើកំណត់ហេតុ

វាមានសារៈសំខាន់ណាស់ ដើម្បីថែរក្សាទុកជាឯកសារនូវរាល់ហេតុការណ៍ ដែលបានកើតឡើងក្នុងអង្គប្រជុំ ដូច្នេះក្រុមអាចធ្វើការតាមដាន រាល់បញ្ហានានាពីអង្គប្រជុំ និងសំរាប់កិច្ចប្រជុំលើកក្រោយទៀត ។ ជាទូទៅ លេខាធិការជាអ្នកទទួលខុសត្រូវ ក្នុងការធ្វើកំណត់ហេតុ ប៉ុន្តែតួនាទីនេះ ក៏អាចធ្វើការផ្លាស់ប្តូរបានផងដែរ ក្នុងចំណោមសមាជិកទាំងអស់ ធ្វើដូចនេះពួកគេនឹងទទួលបានបទពិសោធន៍ការងារគ្រប់ៗគ្នា ។ សូមអាន ឧបសម្ព័ន្ធ៧ គំរូទំរង់កំណត់ហេតុ ។

- **ការសំរបសំរួលសិស្ស** ( របៀបផ្តល់ឱកាសដល់សមាជិកគ្រប់រូបចូលរួមមតិ)

វាជាកត្តាមួយដ៏សំខាន់ ដើម្បីព្យាយាមជំរុញ និងធានាអោយបានថា វាមិនមែនមានតែអ្នកសំរបសំរួល និងអ្នកដឹកនាំក្លឹបតែប៉ុណ្ណោះទេ ដែលអាចសំរេចអ្វីៗនូវក្នុងអង្គប្រជុំនោះ ។ ជាគោលគំនិត គួរអោយសមាជិកផ្សេងៗ រៀនធ្វើផែនការប្រជុំម្នាក់ម្តងៗ បើពួកគេចង់ធ្វើ ឬក៏ចែកជាក្រុមដើម្បីធ្វើការពិភាក្សានូវរាល់បញ្ហាផ្សេងៗ ។



- ការបិទអង្គប្រជុំ

ជាចំណុចមួយដ៏សំខាន់ផងដែរ **ដើម្បីរៀបចំកម្មវិធីប្រជុំ និងការបិទអង្គប្រជុំតាមពេលវេលា**កំណត់ ។ តាមបទពិសោធន៍របស់យើង **រាល់កិច្ចប្រជុំទាំងអស់តែងតែបញ្ចប់** ក្នុងរយៈពេលប្រហែល ១ម៉ោង ។ **រាល់មេរៀននានាស្តីពីបរិស្ថានអាចបញ្ចប់ក្នុងរយៈពេល២-៣ម៉ោង** ហើយការអនុវត្តសកម្មភាពផ្សេងៗទៀតប្រហែល**កន្លះថ្ងៃ ។ នៅពេលបិទអង្គប្រជុំ** ឬបញ្ចប់សកម្មភាពការងារផ្សេងៗ **គួរតែរំលឹកដល់សិស្សទាំងអស់ពីកាលបរិច្ឆេទ** និងពេលវេលាសំរាប់ប្រជុំលើកក្រោយ ។ ពត៌មាននេះ **និងត្រូវបិតនៅលើបដាប្រកាសពត៌មានដើម្បីរំលឹកផងដែរ ។**

## ទីកន្លែងប្រជុំ

**រាល់កិច្ចប្រជុំ**ទាំងអស់គួរត្រូវបានធ្វើឡើងនៅតែកន្លែងមួយ ដូច្នេះមិនមានការភ័ន្តច្រឡំ ។ **ទីកន្លែងគួរ**មានការងាយស្រួលអង្គុយសំរាប់សមាជិកទាំងអស់ ។ បើសិនជាអាចធ្វើទៅបានការអង្គុយ**ប្រជុំគួរត្រូវ**បានរៀបចំដើម្បីអោយសមាជិកទាំងអស់ អាចអង្គុយទល់មុខគ្នាទៅវិញទៅមក ។ ឧទាហរណ៍ **សិស្សអាចអង្គុយ**ជុំវិញតុ ឬលើកៅអីជារង្វង់មូល ឬនៅក្រោមដើមឈើ ។ ការរៀបចំនេះ**សំរួលដល់**ការទំនាក់ទំនងជាចំហរ ហើយមានលក្ខណៈ ខុសគ្នា ពីសកម្មភាពក្លឹប និងការសិក្សាមេរៀនក្នុងថ្នាក់ធម្មតា ។ ហើយត្រូវមានកន្លែង គ្រប់គ្រាន់ ដើម្បីដាក់តាំង ឬបង្ហាញសំភារៈឯកសារ ។

## ការបង្កើតទស្សនវិស័យ ទិសដៅ គោលបំណង និងផែនការ គំនិតនៃការ បង្កើត "សាលាគំរូ ឬភូមិគំរូ"

នៅពេលចាប់ផ្តើមកម្មវិធី វាជាកត្តាមួយដ៏សំខាន់ សំរាប់សិស្សធ្វើការ បង្កើតទស្សនៈសំរាប់សាលា ឬសហគមន៍ របស់ពួកគេ។ ទស្សនៈវិស័យនេះនឹងជួយណែនាំដល់ពួកគេ **ដើម្បីឆ្ពោះ**ទៅរកទិសដៅរួមមួយ។ អ្នកសំរបសំរួល អាចជួយសំរួលកុមារ **ដើម្បីបង្កើតរូបភាពមួយនៃសាលា** ឬសហគមន៍ដែលពួកគេចង់សិក្សា និងរស់នៅ។ គាត់អាច អោយ**សិស្សទាំងនោះ បិទភ្នែករបស់គេ** ហើយធ្វើការ ស្រមើរស្រមៃអំពីសាលារៀន ឬសហគមន៍**មួយដ៏ប្រណិតទៅថ្ងៃអនាគត។** ដើម្បីជួយដល់ពួកគេ លោកគ្រូ អ្នកគ្រូអាចសួរនូវសំណួរមួយចំនួន **ដូចខាងក្រោម:**

- តើសិស្សទាំងអស់គ្នា ចង់ឃើញសាលារៀនរបស់ពួកគេមាន**ដើមឈើដុះស្រស់ស្អាតរឺទេ?**
- តើមានដើមឈើប្រភេទអ្វីខ្លះ?
- តើពួកគេចង់ដាំដើមឈើទាំងនេះនៅត្រង់ណា?
- តើពួកគេចង់ឃើញសួនផ្កាស្រស់ស្អាត **រឺសួនបន្លែរឺទេ?**
- តើមានស្រះចិញ្ចឹមត្រីរឺទេ?
- តើមានគំនរសំរាមនៅក្នុងទីធ្លាសាលាទេ ទៅអនាគត?
- តើសាលាមានរបង ឬទ្វាររបៀបធម្មជាតិដែររឺទេ?
- តើខាងក្នុងថ្នាក់រៀនមើលទៅមានសភាពដូចម្តេច?
- **តើមានគំនិតអ្វីខ្លះទៀតដើម្បីធ្វើអោយសាលារៀនមានភាពស្រស់បំព្រង?**



ទស្សនៈវិស័យរបស់កុមារ អាចមានលក្ខណៈទូលំទូលាយ ឬធំធេងបំផុត។ ជាឧទាហរណ៍ ពួកគេប្រហែលអាចគិតអំពីសាលា ដែលមានពោរពេញដោយដើមឈើ និងសត្វនានា ទោះបីមានទីធ្លាតូច ឬខ្វះទឹកដើម្បីដាំដុះដើមឈើ អោយមាននិរន្តភាពក៏ដោយ។ ក្នុងករណីណាក៏ដោយ អ្នកសំរបសំរួល ក្លឹបបរិស្ថាន ត្រូវបង្ហាញពីការ គោរពនូវទស្សនៈទាំងនេះ ហើយត្រូវជំរុញលើកទឹកចិត្តដល់ពួកគេ ដើម្បីអោយពួកគេបង្ហាញ ពីការបង្កើតនូវទស្សនៈវិស័យ ទៅអនាគត។ ត្រូវប្រាប់ ពួកគេថាគ្មានការកំណត់ពេលវេលាណាមួយទើបទស្សនៈវិស័យនេះ នឹងត្រូវបានសំរេចនោះទេ ហេតុនេះការពិចារណា សំរាប់គំរោងរយៈពេលវែង ក៏ជាកត្តាមួយអាច ទទួលយកបាន ដែរ។ សូមមើលឧបសម្ព័ន្ធ ៧ មេរៀនផែនការសកម្មភាពលំអិត។

## ការកំណត់ទិសដៅ និងគោលបំណងរបស់ក្លឹបបរិស្ថាន

នៅពេលដែលគំរោងត្រូវបានបង្កើត ជំហានបន្ទាប់គឺត្រូវកំណត់ទិសដៅរបស់ក្លឹប។ សិស្សទាំងអស់ចាំបាច់ត្រូវធ្វើការចូលរួមនូវដំណើរការនេះ។ ជំហានដំបូងអ្នកសម្របសំរួលក្លឹបបរិស្ថានត្រូវធ្វើការពិចារណារកគំនិតថ្មីៗមួយសមាជិកសិស្សអំពីបញ្ហាបរិស្ថាននៅក្នុងសាលារៀនរបស់ពួកគេ ឬនៅក្នុងភូមិទាំងមូល ។បន្ទាប់មកត្រូវធ្វើបញ្ជីដំណោះស្រាយដែរអាចធ្វើទៅបានសំរាប់បញ្ហាបរិស្ថានទាំងនោះ។ គំនិតមួយគួរត្រូវបានចាប់ផ្តើមឡើងជាមួយនឹងសំណួរដូចជា "តើយើង សង្ឃឹមថាយើងនិងសំរេចបានអ្វីខ្លះនៅដំណាច់ឆ្នាំនេះ? "ទិសដៅ និងគោលបំណង ដែលបានជ្រើសរើសរួចហើយត្រូវធ្វើការបង្ហាញដោយសិស្សគ្រប់ៗគ្នា។ ឧទាហរណ៍នៅក្នុងឆ្នាំខ្លះការជ្រើសរើសនេះ ត្រូវដាក់បញ្ចូលអោយមានដំណោះស្រាយ ដូចជាបញ្ហា អនាម័យសំរាមនៅក្នុងសាលារៀន ការធ្វើអោយជីសាលាមានពណ៌បៃតង ឬក៏ត្រូវធ្វើ ជាការសិល្បៈ បរិស្ថានដូចជា ការរៀបចំសួនផ្កា ។ល។

សិស្សទាំងអស់ត្រូវធ្វើការពិភាក្សាអំពីលទ្ធភាព និងសេចក្តីសំរេចរួមនូវទិសដៅណាមួយដែលមានការចាប់អារម្មណ៍ខ្លាំងសំរាប់ពួកគេ។ ទោះជាយ៉ាងណា វាមានសារៈសំខាន់ណាស់សំរាប់អ្នកសំរបសំរួលធ្វើការណែនាំអំពីការពិភាក្សាក្នុងការកំណត់បញ្ហាដែលអាចឈានទៅរកការកំណត់នូវលទ្ធភាពដើម្បីអនុវត្តគំរោងកម្មវិធីដូចជា ពេលវេលា សមត្ថភាពសិស្សក្នុងការបំពេញការងារ ដែលពាក់ព័ន្ធ ឬថវិការ ធនធានមនុស្ស និងសំភារៈផ្សេងៗដែល ត្រូវសំរាប់អនុវត្តសកម្មភាព។



នេះជាឧទាហរណ៍អំពីទិសដៅដែលបានជ្រើសរើសដោយសាលាមួយ:

ទិសដៅ: នៅដំណាច់ឆ្នាំនេះ សមាជិកក្រុមសង្ឃឹមថានឹង:

-ធ្វើការកែលំអបញ្ហាសំរាមក្នុងសាលា ដោយ**ធ្វើការអប់រំសមាជិក**ក្រុមនិងសិស្សផ្សេងៗទៀត អំពីបញ្ហាការព**ង្រាយសំរាម**

-ធ្វើបរិស្ថានសាលាមានការប្រសើរឡើង **ដោយធ្វើការដាំដុះ**និងថែរក្សាដើមឈើ ១៥០ដើម

- ធ្វើការផ្សព្វផ្សាយការយល់**ដឹងអំពីបរិស្ថានក្នុងសហគមន៍**តាមរយៈមធ្យោបាយជាច្រើនដូចជា ចំរៀង កំណាព្យ **ភាគកំប្លែងខ្លីៗ** និងការតាំងពិពណ៌របស់ក្រុម

## ការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ

ក្រោយពីទិសដៅមួយត្រូវបានបង្កើត ផែនការ**សកម្មភាពក៏ត្រូវបានធ្វើ ដើម្បីសំរេចផែន**ការ។ កត្តានេះគួរត្រូវបានធ្វើឡើងដោយមានការកំណត់នូ**វរាល់ជំហានពីមួយៗ ដែលអាចធ្វើទៅ**បានដើម្បីជួយអោយសំរេចបាននូវទិសដៅទាំងនោះ។ **សិស្សទាំងអស់ត្រូវការជំនួយទំនុបបំរុងពីគ្រូ**ក្នុងការធ្វើផែនការការងារ ដែលនឹងត្រូវអនុវត្តតាម**ដំណាក់កាលនីមួយៗ និងកំណត់បញ្ជាក់ថា**អ្នកណាត្រូវទទួលការងារអ្វី ហើយនៅពេលណា។ **សូមមើលឧបសម្ព័ន្ធ ៩ គំរូសំរាប់ការធ្វើ**ផែនការសកម្មភាពប្រចាំលំអិត។

## សមាសភាពបី: កិច្ចប្រជុំក្លឹបសំរបសំរួលការសិក្សា និង សិស្សដឹកនាំសកម្មភាព

សកម្មភាពក្លឹបបរិស្ថាន អាចត្រូវបាន បែងចែកជាសមាសភាគបី យ៉ាងទូលំទូលាយគឺ: ការប្រជុំសិស្សក្លឹប សំរបសំរួលការសិក្សា និងសិស្សដឹកនាំសកម្មភាព។ ការប្រជុំក្លឹបជាសកម្មភាពមួយដ៏សំខាន់បំផុត របស់ក្លឹបបរិស្ថាន ពីព្រោះពួកគេ ជាក្រុមមួយដែលធ្វើការទំនាក់ទំនងជាសមាជិកក្រុម ហើយពួកគេផ្តល់ឱកាសដើម្បីធ្វើការកំណត់នូវបញ្ហានានា រួចហើយធ្វើគំរោងផែនការ ទិសដៅ គោលបំណង និងសកម្មភាព ហើយវិភាគនូវរាល់លទ្ធផល និងស្នាដៃនានាដែលសំរេចបាន។

**សមាសភាពទីពីរ** គឺសំរបសំរួលការសិក្សា ដែលជាឱកាសមួយសំរាប់សិស្សនានាសិក្សាបន្ថែម ទៀតអំពី**បរិស្ថាន**តាមរយៈមេរៀនដែលផ្តល់ដោយអ្នកសំរបសំរួលក្លឹបបរិស្ថាន។ មានធនធានជាច្រើនសំរាប់**លោកគ្រូ** អ្នកគ្រូជួយធ្វើផែនការ និង អនុវត្តសកម្មភាពសិក្សា ដែលមានការចាប់អារម្មណ៍ដោយ**សមាជិកក្រុម** (សូមមើល ឧបសម្ព័ន្ធ ១២ សំរាប់បញ្ជីសំភារៈឯកសារ)។ **វិធីសំរបសំរួលការសិក្សានេះ**មានលក្ខណៈខុសពីការបង្រៀន នៅក្នុងថ្នាក់ធម្មតា។ ក្នុងការសំរបសំរួលសិក្សា សិស្សត្រូវចូលរួមសកម្មភាពសិក្សាខាងក្រៅ ល្បែងកំសាន្ត និង ការធ្វើលំហាត់ដកស្រង់បទពិសោធន៍ ផ្សេងៗទៀត។ វិញ្ញាណនៃ ការរកឃើញ និង ការបង្កើតគំនិតថ្មីៗនេះត្រូវបានបណ្តុះ ហើយសិស្សជាច្រើនមានចំណាប់អារម្មណ៍ទៅ និងបរិស្ថាននៅក្នុងសហគមន៍របស់ពួកគេ។

សមាសភាពទីបី គឺសិស្សដឹកនាំសកម្មភាព ជាសកម្មភាពដែលសិស្សខ្លួនឯងសំរេចអនុវត្តដើម្បីធ្វើការកែលំអរបរិស្ថាន ក្នុងភូមិរបស់គេ។ ក្នុងពេលប្រជុំក្លឹប ពួកគេនិងសំរេចលើសកម្មភាពទាំងនេះហើយធ្វើផែនការសំរាប់អនុវត្ត។



ការបែងចែកនូវសមាសភាពទាំងនេះ អាចបត់បែនទៅបានដោយផ្អែកលើតំរូវការចាំបាច់ និងសមត្ថភាពរបស់សិស្សនិងគ្រូ ទោះជាយ៉ាងណា វាជាកត្តាមួយដ៏សំខាន់សំរាប់ការដាក់បញ្ចូលសមាសភាពនីមួយៗទៅក្នុងដំណើរការក្រុម។

## ការសិក្សានៅខាងក្រៅថ្នាក់

វាជាកត្តាមួយដ៏សំខាន់សំរាប់សិស្ស និងគ្រូ ក្នុងការចេញក្រៅថ្នាក់សិក្សា ដើម្បីពិនិត្យមើលនូវបរិយាកាសជុំវិញ។ ដើម្បីសិក្សាពីបរិយាកាស ពួកគេគប្បីសិក្សាអំពីបរិស្ថាន។ ក្រៅពីការសិក្សាក្នុងថ្នាក់ សមាជិកក្លឹបបរិស្ថានក៏បានអនុវត្តសកម្មភាពសិក្សាខាងក្រៅដូចជា ការផលិតជីកំប៉ុស ការផ្សាំកូនឈើ បណ្ដុះគ្រាប់ពូជ ការដាំដុះ និងការថែរក្សាដើមឈើ ការធ្វើសួន (មានសួនផ្កាសួនបន្លែ និង ការដាំរុក្ខជាតិធ្វើថ្នាំធម្មជាតិ) និងធ្វើការកែលំអបរិស្ថាននៅក្នុងសាលារៀនរបស់ពួកគេ។ នេះគឺជាបរិយាកាសសិក្សាថ្មីមួយសំរាប់សិស្ស ហើយមានការរីកចំរើនយ៉ាងខ្លាំង។

## ការទស្សនៈសិក្សានៅតាមតំបន់ផ្សេងៗ

ការសិក្សានៅខាងក្រៅថ្នាក់ ជាកត្តាមួយដ៏សំខាន់ សំរាប់សកម្មភាពរបស់ក្លឹបបរិស្ថាន ហើយអ្វីដែលត្រូវចុះធ្វើទស្សនៈកិច្ចសិក្សា គឺផ្អែកទាំងស្រុងលើគំរោងកម្មវិធី ដែលក្លឹបបានអនុវត្ត និង ធនធាននានាដែលក្លឹបមាន។ ឧទាហរណ៍ ក្លឹបបានធ្វើគំរោងកម្មវិធីជីកំប៉ុស ដូច្នេះការចុះធ្វើទស្សនៈកិច្ចគួរទៅមើលទីកន្លែងផលិត ឬស្ថាប័នផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនិងការផលិតជីធម្មជាតិ។ ជាការពិត ក្លឹបត្រូវចុះទៅពិនិត្យមើលទីកន្លែងទាំងនោះដែលស្ថិត នៅជុំវិញតំបន់របស់ពួកគេ។ ការចុះសិក្សាទាំងនេះ មិនចាំបាច់បង្កើតជាទំរង់បោះជំរុំ ឬការចេញក្រៅទៅតំបន់ក្នុងព្រៃឆ្ងាយៗ ឬឡើងភ្នំនោះទេ។ ភាគច្រើនអាជ្ញាធរមូលដ្ឋាន អាចផ្ដល់ឱកាស ជាច្រើនសំរាប់ធ្វើការអង្កេត និងសិក្សាស្រាវជ្រាវ។ នៅជិតតំបន់ភ្នំ មីមទាប ឬតំបន់ព្រៃរបោះជាទីកន្លែងដែលអំណោយផល ល្អសំរាប់អោយក្លឹបធ្វើសកម្មភាពសិក្សា។

## ការចុះតាមសហគមន៍

នៅពេលដែលសិស្សបានចូលរួមនៅក្នុងសកម្មភាពក្រុមនិងបង្ហាញពីលទ្ធផល ដែលទទួលបាននោះ ពួកគេមានចិត្តរីករាយប្រាប់ដល់អ្នកដទៃៗទៀតពីអ្វី ដែលគេបានធ្វើ។ ការចែករំលែកនេះមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ ថែមទាំងជំរុញលើកទឹកចិត្ត និងផ្សព្វផ្សាយពីការខិតខំប្រឹងប្រែងរបស់ពួកគេដល់អ្នកដទៃៗទៀត អោយចូលរួមក្នុងពង្រឹងបរិស្ថានធម្មជាតិថែមទៀតផង។ ដើម្បីសម្រួលការងាររបស់សមាជិកក្រុម គួរត្រូវបានណែនាំពីការប្រើប្រាស់បរិយាកាសពេលវេលា ដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈរបស់ពួកគេផងដែរ។ ពួកគេអាចអញ្ជើញអ្នកផ្សេងៗទៀត អោយមើល និងស្ដាប់ពីការងាររបស់ពួកគេតាមរយៈការបង្ហាញដូចជា ការពិពណ៌ ការចុះទៅមើលកន្លែងដាំដុះ ។ល។ ពួកគេអាចធ្វើដូចនេះជាប្រចាំ នៅសាលារៀន ដូចជាដាក់បង្ហាញឬការសំដែង ប្រចាំឆ្នាំ ឬនៅពេលមានកម្មវិធីពិសេសៗ ដែលត្រូវបានធ្វើនៅក្នុងសាលារៀន។ សហគមន៍ក៏ជាធនធានមួយដ៏សំខាន់សំរាប់សមាជិកក្រុម ហើយរាល់គំនិតយោបល់ និងពត៌មាន ត្រឡប់ពីសហគមន៍ទាក់ទងទៅនិងក្រុមត្រូវបានទទួលស្វាគមន៍ ដោយរីករាយ។

## ការបង្កើតទិវាផ្សេងៗ

បន្ថែមទៅនិងសកម្មភាពប្រចាំសប្ដាហ៍ រាល់ក្រុមនីមួយៗអាចរៀបចំទិវាផ្សេងៗ។ ទិវា



នេះអាចរៀបចំធ្វើឡើងដោយភ្ជាប់ទៅនិងថ្ងៃសំខាន់ៗដូចជា ទិវាបរិស្ថានពិភពលោក(៥មិថុនា) ទិវាព្រៃឈើពិភពលោក ឬ ថ្ងៃបើកវិសម្មការថ្មី។ ក្នុងថ្ងៃពិសេសៗទាំងនេះ **មានការរោយស្រួល ដើម្បីអោយសិស្សផ្សេងៗទៀតបានចូលរួមផងដែរ ព្រមទាំងមានសហគមន៍ជាអ្នកចូលរួម ឬជា** អ្នកសង្កេតការណ៍។ **សកម្មភាពនានាដែលត្រូវអនុវត្តរួមមាន ការបង្កើតការតាំងពិពណ៌ បញ្ចាំងវីដេអូ** និងរូបភាពស្លាយ **ការរៀបចំសិល្បៈ ប្រលងប្រជែងសំនួរ ល្បែងកំសាន្ត ការប្រលងតែងកួបទ** កំណាព្យ ឬចំរៀង **ដែលទាក់ទងទៅនិងប្រធានបទបរិស្ថាន។**

## អ្នកមានបទពិសោធន៍ និងការស្នើសុំជំនួយ

ការអញ្ជើញអ្នកមានបទពិសោធន៍ **ដើម្បីធ្វើការពិភាក្សាជាមួយសិស្ស** និងជួយដល់ការពង្រីក ចំណេះដឹង ពត៌មាន **និងនាំមកនូវគំនិតថ្មីៗ និងនាំមកនូវគំនិតទស្សនៈថ្មីៗ។ ត្រូវការអ្នកមានបទពិសោធន៍មិន** ចាំបាច់សំរាប់អ្នកដែលមានចំណេះដឹង**ការសិក្សាខ្ពស់ ឬអ្នកជំនាញការនោះទេ**។ ជាទូទៅសំរាប់អ្នកដែលមានបទពិសោធន៍ធ្វើ**ការតាមសហគមន៍(ឧ. ការធ្វើសួនបន្លែ** និងការដាំដុះរុក្ខជាតិឱសថ ។ល។) ដែលមានបទពិសោធន៍ខ្ពស់ **និងយូរឆ្នាំ។ អ្នកមានបទពិសោធន៍** អាចជាអ្នកជំនាញមកពីមហាវិទ្យាល័យ ក្រុមបុគ្គលិកបរិស្ថាន **អង្គការក្រៅរដ្ឋាភិបាល** ក៏ដូចជាមនុស្សចាស់ៗក្នុងភូមិដែលមានបទពិសោធន៍ផងដែរ។ **សូមកុំភ្លេចជំរាបជូនសម្ភេប** ដល់អ្នកមានបទពិសោធន៍ទាំងនោះជាមុននូវសកម្មភាពគោលបំណង **ក៏ដូចជាកំរិតនៃការយល់ដឹងរបស់សិស្សផងដែរ**។ ជួនកាលការពិភាក្សាមានលក្ខណៈបច្ចេកទេសខ្លាំងពេក ឬមានកំរិតខ្ពស់ពេក អាចធ្វើអោយសិស្សមានការពិបាកយល់។ **ជំរុញអោយសិស្សក្រេបយកនូវចំណេះដឹងនៅពេលមាន** អ្នកជំនាញមកជួបដោយបញ្ចាក់ពីចំងល់ផ្សេងៗ **លើកជាសំនួរ បង្កើតការពិភាក្សា** ។ល។ សិស្សអាចកត់ត្រានូវចំណុចសំខាន់ៗ ដែលបកស្រាយដោយអ្នកធ្វើអត្ថាធិប្បាយ រួចហើយដាក់បញ្ចូលឯកសារកត់ត្រាទាំងនេះជាមួយពត៌មានដែលបានបង្ហាញ នៅពេលក្រោយ។

## ការគាំទ្រសកម្មភាពដោយខ្លួនឯង និង ការបង្កើត មូលនិធិ

**ដើម្បីអនុវត្តដំណើរការតំរោងកម្មវិធីក្លឹប ចាំបាច់ត្រូវមានថវិកាខ្លះៗ ដើម្បីធ្វើការទ្រទ្រង់ ដោយខ្លួនឯង។** ក្នុងករណីខ្លះក្លឹបអាចទទួលបានថវិកាពី ការិយាល័យគ្រប់គ្រងរដ្ឋបាលសាលាឬតាមរយៈ**អង្គការក្រៅរដ្ឋាភិបាល**។ ទោះជាយ៉ាងណាថវិកានេះមិន ចាំបាច់មាននិរន្តភាពទេ។ **ក្លឹបអាចទ្រទ្រង់ដោយខ្លួនឯង**បានតាមមធ្យោបាយជាច្រើន។ ឧទាហរណ៍ ក្លឹបអាចបង្កើតថវិកាតាមរយៈការលក់សំភារៈ**ធម្មតាៗ** ដែលធ្វើដោយដៃដូចជា ម៉ាសមុខដែលធ្វើពីក្រដាសចាស់ៗ កញ្ច្រែង-ល្អី ដែលធ្វើពីស្លឹកត្នោត ការបណ្តុះកូនឈើ ដែលធ្វើដោយក្លឹប ការដាំផ្សិត ការដាំបន្លែ ដែលជា សួនបន្លែរបស់ក្លឹប ព្រមទាំងការលក់ជីកំប៉ុស្ត និងក្រដាសចាស់ៗ។

## ការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល



ការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលដល់កម្មភាពក្លឹបបរិស្ថានត្រូវបានយកមកពិចារណា ថាជាការផ្តល់ប្រាក់លើកទឹកចិត្តបន្ថែម ប៉ុន្តែវាពុំចាំបាច់ឡើយ។ សិស្ស និងគ្រូបង្រៀនទាំងអស់គ្នា មានលទ្ធភាពក្នុងការដោះស្រាយ អំពីបញ្ហាបរិស្ថានតាមសាលា រៀនដោយពួកគេផ្ទាល់។ សកម្មភាពជាច្រើនដូចជា ការបោសសំអាតទីធ្លាសាលា ការរៀបចំដាំកូនឈើ បណ្តុះគ្រាប់ពូជដែលតំរូវអោយមានគំនិត ផ្តួចផ្តើម និងការព្យាយាម តែប៉ុណ្ណោះ។ ក្នុងករណី ណាក៏ដោយការទ្រទ្រង់ដោយខ្លួនឯងជាគោលបំណងតែមួយគត់ សំរាប់ក្លឹបបរិស្ថាន **ដោយសារការគាំទ្រពីអង្គការក្រៅ**រដ្ឋាភិបាលតែងតែមានការកំណត់។ នៅពេលដែលក្លឹបអាចសិក្សាយល់ដឹង **ពីវិធីដើម្បីគាំទ្រសកម្មភាព**របស់បាន កាន់តែឆាប់ ពួកគេនិងមាននិរន្តភាពក៏កាន់តែឆាប់ដែរ។ **ជាមួយគ្នានោះដែរ** ដោយមានការគាំទ្រសកម្មភាព របស់ខ្លួនផ្ទាល់សមាជិកក្លឹបមានអារម្មណ៍កាន់តែខ្លាំងឡើងៗ ដែលបានធ្វើជាម្ចាស់ និងមានមោទនភាពសំរាប់ការងាររបស់គេ។

## ការធ្វើវិភាគទានពីសហគមន៍ និងស្ថាប័នផ្សេងៗទៀត

វាមានតំលៃខ្លាំងណាស់ ប្រសិនបើមានស្ថាប័នក្នុងស្រុក ឬសមាជិកសហគមន៍ណាមួយ ១៩

ដែលអាចជួយគាំទ្រដល់សកម្មភាពក្លឹប ជាថវិកាក្តី និងជាសំភារៈក្តី។ ឧទាហរណ៍ មន្ទីរកសិកម្មតែងតែផ្តល់ជាពូជឈើសំរាប់សាលារៀន។ ហើយមានសប្បុរសជនខ្លះបានទទួលខុសត្រូវនូវសកម្មភាពមួយចំនួនដូចជា **ធ្វើរបង ជួសជុលជញ្ជាំង** និងផ្តល់ជាសំភារៈដូចជាធុងទឹក ។ល។ អ្នកទទួលខុសត្រូវទាំងនោះក៏**មានចិត្តសប្បាយរីករាយ** នៅពេលឃើញឈ្មោះ និងការបរិច្ចាករបស់គេឆ្លាក់ជាប់នៅកន្លែងណាមួយ។ **អ្នកចូលរួមផ្សេងៗទៀត**មានដូចជា ឪពុកម្តាយរបស់សិស្សក្លឹប ឬសហគមន៍បានត្រៀមរួចជាស្រេចដើម្បីបរិច្ចាក **រឺអោយខ្ចីសំភារៈ** ឬសៀវភៅផ្សេងៗ ឬទទួលខុសត្រូវនូវកម្មវិធីអ្វីមួយ។ **ក្នុងករណីខ្លះ** **នាយកសាលា** ឬគណៈកម្មការអាចារ្យវត្តអាចដឹងនូវម្ចាស់ជំនួយដែលបានធ្វើ**ការគាំទ្រសកម្មភាព**សហគមន៍កន្លងមក ហើយលោកលោកស្រីម្ចាស់ជំនួយទាំងនោះ**នឹងអាចផ្តល់ជាការណែនាំដល់ក្លឹប**។ គណៈកម្មការអាចារ្យវត្តអាចបរិច្ចាកថវិកាខ្លះ ឬអាចជួយផ្សព្វផ្សាយព**ត៌មានផ្សេងៗពីតំរូវការរបស់ក្លឹបនៅ**ថ្ងៃសីល (**ថ្ងៃពិសិដ្ឋរបស់ព្រះពុទ្ធសាសនា**) និងពេលមានបុណ្យ**ទាននៅវត្តផ្សេងៗទៀត**។ ជាមួយគ្នានោះដែរ **វាមានសារៈសំខាន់ណាស់ក្នុង**ការទំនាក់ទំនងជាមួយ**ការិយាល័យអង្គការ** UNICEF ប្រចាំខេត្ត **ដោយសារអង្គការនេះមាន**សកម្មភាពគាំទ្រទៅលើ**ក្លឹបបរិស្ថានមួយចំនួននៅក្នុ**ងស្រុកគោលដៅរបស់គេ។



### ការលើកទឹកចិត្តសិស្ស

បើសិនលោកគ្រូ អ្នកគ្រូចង់អោយដំណើរការ**ក្លឹបបានជោគជ័យនោះ ចូរលោកអ្នកចងចាំ**នូវចំណុច មួយៈ គឺការលើកទឹកចិត្តដល់សិស្ស។ ការលើកទឹកចិត្ត**នឹងអាចកើតមានឡើង ដោយ**ការផ្តល់ឱកាសដល់សិស្សទាំងនោះធ្វើផែនការ និងធ្វើសេចក្តីសំរេចចិត្តដោយខ្លួនឯង។ លោកគ្រូ អ្នកគ្រូជានិច្ចជាកាល ត្រូវតែជំរុញលើកទឹកចិត្តនូវរាល់គំនិតយោបល់របស់សិស្ស ហើយធ្វើការកោតសរសើរចំពោះការងាររបស់ពួកគេ **និងសមិទ្ធិផលនានាដែលទទួលបាន**។ លោកគ្រូ អ្នកគ្រូគួរផ្តួចផ្តើមគំនិតតូចមួយដើម្បីលើកទឹកចិត្តសិស្សដូចជា **លិខិតសរសើរពីនាយកសាលា ការដឹកនាំក្រុមតូចៗ**ដើរកំសាន្តខាងក្រៅឬក៏ផ្ញើរលិខិតទៅឪពុកម្តាយសិស្សដែលពាក់ព័ន្ធទៅនិង **សកម្មភាព ក្លឹប** និងការកោតសរសើរចំពោះការចូលរួមរបស់សិស្ស។

### **របាយការណ៍ទៅការិយាល័យអប់រំស្រុក** (DoE) **និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត** (PoEYS)



**យើងសូមផ្តល់អនុសាសន៍ថា** ត្រូវធ្វើការទំនាក់ទំនងអោយបានល្អ ជាមួយការិយាល័យ**អប់រំ យុវជន និងកីឡាស្រុក និងខេត្ត។ ដើម្បីអនុវត្តនូវវិធានការដូចនេះ** របាយការណ៍សកម្មភាព**របស់ក្លឹប គួរត្រូវបានផ្ញើរទៅការិយាល័យ**អប់រំ យុវជន និងកីឡាស្រុកនិងខេត្តយ៉ាងហោចណាស់**បីខែម្តង សូមមើលឧបសម្ព័ន្ធ ១០ គំរូសំរាប់របាយការណ៍**។ ដូចដែលបានជំរាបជូនរួចមកហើយ**ថា បើសិនអាចធ្វើទៅបាន**គួរអញ្ជើញមន្ត្រីស្រុក ឬខេត្តចុះធ្វើទស្សនៈ និងចូលរួមនៅក្នុងអង្គប្រជុំ ឬសកម្មភាព ផ្សេងៗរបស់ក្លឹបបរិស្ថាន។

**សិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្រៀននិងការត្រួតពិនិត្យតាមដានផ្នែកគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល)**

## គោលបំណងនៃសិក្ខាសាលាបណ្តុះបណ្តាលគ្រូ

ដើម្បីគ្រប់គ្រង ក្លឹបបរិស្ថានអោយបានជោគជ័យ លោកគ្រូអ្នកគ្រូទាំងអស់ និងបុគ្គលមួយចំនួន ដែលពាក់ព័ន្ធនិងការទទួលខុសត្រូវសកម្មភាពនេះ ត្រូវមានការយល់ដឹង អំពីបញ្ហាបរិស្ថាន នីតិវិធី សកម្មភាពក្នុងការបង្រៀន និងការគ្រប់គ្រងសកម្មភាពក្លឹប។ សិក្ខាសាលាសំរាប់គ្រូបង្រៀន ផ្តល់នូវជំនាញសំខាន់ៗដូចជា ការធ្វើផែនការសំរាប់សកម្មភាពក្លឹប ការពិនិត្យ និងវាយតំលៃ ដោយខ្លួនឯង និងការផ្លាស់ប្តូរទៅវិញទៅមកនិវត្តភាពសំរាប់ក្លឹបបរិស្ថាន។ សិក្ខាសាលនឹងផ្តល់ឱកាសដល់គ្រូដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។ ក្នុងការងាររបស់អង្គការ ម្លប់បៃតង ការធ្វើសិក្ខាសាលាបណ្តុះបណ្តាលគ្រូ ត្រូវអនុវត្តធ្វើឡើងជារៀងរាល់បីខែម្តង ហើយរាល់សិក្ខាសាលានីមួយៗមានរយៈពេលបីថ្ងៃ។ ការណែនាំខាងក្រោម មានលក្ខណៈទូលំទូលាយ ហើយផ្អែកលើបទពិសោធន៍ ពីការសិក្ខាសាលាបណ្តុះបណ្តាលគ្រូ ដែលបានធ្វើឡើងដោយអង្គការម្លប់បៃតង។ រាល់ស្ថាប័ន ឬអង្គការនានា គួរតែអោយមានការជួយគាំទ្រក្នុងការរៀបចំបន្ថែមទៀតនូវសិក្ខាសាលាបណ្តុះបណ្តាលគ្រូ។ ម្លប់បៃតង អាចផ្តល់ជាសំភារៈផ្សេងៗ (សូមមើលឧបសម្ព័ន្ធ ១២ សំរាប់បញ្ជី) តាមរយៈមណ្ឌលធនធាន ក៏ដូចជាសេវាបណ្តុះបណ្តាលនានា។

## ការបង្កើនចំណេះដឹងអំពីបរិស្ថាន

វាជាកត្តាមួយដ៏សំខាន់ដែលអ្នកសំរបសំរួលក្លឹបបរិស្ថាន ត្រូវមានចំណេះដឹងអំពីបរិស្ថាន ក៏ដូចជា ការយល់ដឹងអំពីបញ្ហាបរិស្ថានទាំងនៅក្នុងស្រុក និងនៅក្នុងពិភពលោក។ សិក្ខាសាលាបណ្តុះ បណ្តាលត្រូវផ្តល់អោយអ្នកចូលរួមមានការយល់ដឹងអំពីបរិស្ថានទូទៅ ដែលមានប្រធានបទស្តីពី បរិស្ថានវិទ្យា ប្រព័ន្ធបរិស្ថាន និងសារៈប្រយោជន៍អំពីព្រៃឈើ និងសត្វព្រៃ ក៏ដូចជាបញ្ហាបរិស្ថានពិភពលោក និងតំបន់ ដូចជាការគំរាមពិភពលោក បញ្ហាទឹក បញ្ហាអភិរក្ស បញ្ហាកាកសំណល់សំរាម និងបញ្ហាផ្សេងៗជាច្រើនទៀត។ បញ្ហាបរិស្ថានខ្លះមានផលប៉ះពាល់នៅនិងទីកន្លែង ឬតំបន់នោះផ្ទាល់តែប៉ុណ្ណោះ ហើយបើសិនជាមានករណីដូចនេះ ចាំបាច់ត្រូវធ្វើការបញ្ជាក់ពីបញ្ហាអោយបានច្បាស់លាស់។

## ការពង្រឹងសមត្ថភាពបង្រៀន

សិក្ខាសាលាមានគោលបំណង ដើម្បីធ្វើការពង្រឹងសមត្ថភាពបង្រៀន របស់អ្នកចូលរួមនានា។ ការពង្រឹងសមត្ថភាពសំរាប់ជំនាញបង្រៀន និងការសំរបសំរួល គួរត្រូវបានដាក់បញ្ចូលទៅក្នុងផែនការសិក្ខាសាលា និងវិធីសាស្ត្របង្រៀន។ វិធីសាស្ត្រនៃការបង្រៀនជាច្រើន គួរត្រូវបានប្រើប្រាស់នៅក្នុងសិក្ខាសាលានេះ ដើម្បីធ្វើការបង្ហាញអំពីវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។ គំរូឯកសារមេរៀនបង្រៀនគួរសង្ខេបអោយបានខ្លីហើយមានខ្លឹមសារច្បាស់លាស់។ អ្នកបណ្តុះបណ្តាលត្រូវផ្តល់ជាគំរូនូវ វិធីនៃការបង្រៀនអោយបានត្រឹមត្រូវ តាមរយៈអាកប្បកិរិយាផ្ទាល់របស់គេ និង របៀបបង្រៀនផ្សេងៗ។ រាល់សំភារៈបណ្តុះបណ្តាល និងគំរូឯកសារមេរៀនលំអិតអាចស្នើសុំពីអង្គការ ម្លប់បៃតង។

វិធីសាស្ត្របង្រៀនគួរពិចារណាមានៈ

- ក្រុមពិភាក្សា
- ការវាយតំលៃតាមរយៈដៃគូ មិត្តភ័ក្តិ
- ចុះទស្សនៈកិច្ចសិក្សា
- ការសំដែងសកម្មភាពដោយផ្ទាល់
- ការពិចារណារកគំនិតថ្មីៗ
- ការអង្កេត
- សង្កេតការណ៍
- ល្បែងកំសាន្តនានា

## ការចែករំលែកបទពិសោធន៍

ក្រោយពីគ្រូបានបង្កើតក្លឹបបរិស្ថានហើយនោះ រាល់ការចាប់ផ្តើម នៃសិក្ខាសាលាបណ្តុះបណ្តាលនីមួយៗ អាចមានឱកាសដ៏ល្អសំរាប់លោកគ្រូ អ្នកគ្រូទាំងអស់ ត្រូវធ្វើរបាយការណ៍សង្ខេប

ជំរាបជូនដល់អ្នកចូលរួមទាំងអស់អំពីសកម្មភាពរីកចំរើនរបស់សិស្សក្លឹប ដោយផ្តោតលើលទ្ធផលសំរេចបាន និងមេរៀនដែលបានសិក្សាកន្លងមកពីបទពិសោធន៍ផ្ទាល់របស់ពួកគេ។ បន្ថែម ពីលើនេះទៀត ក្នុងពេលធ្វើក្រុមពិភាក្សា រាល់អ្នកចូលរួមទាំងអស់ **អាចមានឱកាសលើកជាសំណួរ** និងផ្តល់ជាគំនិតយោបល់សំរាប់គ្នាទៅវិញទៅមក។

## ការផ្តល់សំភារៈ និងកាលវិភាគកម្មវិធី

យើងសូមផ្តល់អនុសាសន៍ថា ការរៀបចំសិក្សាសាលាបណ្តុះបណ្តាល**គួរត្រូវបានអនុវត្តធ្វើ**រៀងរាល់បីខែម្តង។ មុនពេលចាប់ផ្តើមនូវរាល់សិក្ខាសាលា**នីមួយៗ កាលវិភាគមួយចាំបាច់**ត្រូវតែរៀបចំអោយបានច្បាស់លាស់ និងយកចិត្តទុកដាក់បំផុត។ **រាល់អ្នកបង្រៀនទាំងអស់ត្រូវ**ផ្តល់នូវការទទួលខុសត្រូវច្បាស់លាស់ ដូច្នេះគេអាចរៀបចំអោយ**បានត្រឹមត្រូវសំរាប់ខ្លួនគេក្នុងការ**ផ្តល់មេរៀនដល់សិក្ខាកាម។ សូមមើល ឧបសម្ព័ន្ធ ១១ **គំរូសំរាប់កម្មវិធីសិក្ខាសាលា**។

## ទីកន្លែង

ប្រសិនបើអាចធ្វើទៅបាន ទីតាំងសំរាប់ធ្វើសិក្ខាសាលាបណ្តុះបណ្តាលគួរត្រូវបានផ្លាស់ប្តូរ ឬប្តូរក្នុង ចំណោមសាលារៀនដែលចូលរួមក្នុងគំរោង ដូច្នេះសាលាទាំងអស់អាចផ្លាស់ប្តូរបទពិសោធន៍ពីគ្នា ទៅវិញទៅមក។ លោកគ្រូអ្នកគ្រូដែលចុះមកទស្សនៈកិច្ចនិងមានឱកាសបានឃើញនូវស្នាដៃនានា របស់ក្លឹបបរិស្ថានដូចជា កន្លែងដាំកូនឈើ សួនបន្លែ និងទីធ្លាសាលាមានភាពស្រស់ស្អាត។

## ការគាំទ្រគ្រូបង្រៀន

ការគាំទ្រសំរាប់គ្រូបង្រៀនផ្អែកទៅនិងថវិកាដែលមានទោះបីយ៉ាងណាក៏មានកំរៃតិចតួចដែរនិង ត្រូវផ្តល់ជូនជាចាំបាច់ដូចជា មធ្យោបាយធ្វើដំណើរ និងអាហារពេលថ្ងៃសំរាប់អ្នកចូលរួម។ កត្តានេះ សូមផ្តល់ជាយោបល់ថា ដើម្បីរក្សាការគាំទ្រនេះត្រូវផ្អែកលើ តំលៃចំណាយពិតប្រាកដដោយ ការផ្តល់អោយជាប្រាក់សោហ៊ុយ អាចធ្វើអោយខូចដល់ប្រាក់លើកទឹកចិត្ត។

## គ្រូបង្គោល និង គ្រូបណ្តុះបណ្តាល

**គ្រូបង្គោល ត្រូវមានចំណេះដឹង** និងបទពិសោធន៍អំពីបរិស្ថាន ក៏ដូចជាជំនាញក្នុងការ**បង្រៀន។ មុនពេលចាប់ផ្តើមធ្វើសិក្ខាសាលាបណ្តុះបណ្តាល** គ្រូបង្គោលត្រូវរៀបចំរាល់ឯកសារសំភារៈ**បណ្តុះបណ្តាលទាំងអស់។ គ្រូបង្គោលចាំបាច់ត្រូវ**មានសត្តមភាពក្នុងការសំរបសំរួលសិក្ខាសាលា **ធ្វើការដឹកនាំសិក្ខាកាម កំណត់នូវគោលបំណងនៃ**ប្រធានបទនីមួយៗយល់ដឹងច្បាស់លាស់អំពីពត៌មានថ្មីៗ **ណែនាំអំពីវិធីសាស្រ្តបង្រៀនថ្មីៗ និងនិតិវិធីការអនុវត្ត**ន៍សកម្មភាព វាយតំលៃ ការសិក្សារបស់សិស្ស **ហើយការអនុវត្តន៍**ការពង្រីកសកម្មភាពផ្សេងៗ។ ចំពោះករណីរបស់យើង ក្នុងការបណ្តុះបណ្តាលនីមួយៗ **យើងមានគ្រូបង្រៀនម្នាក់** ហើយបុគ្គលិក២-៣នាក់ទៀតជា អ្នកជំនួយការ ឬអ្នកមានបទពិសោធន៍។ ពួកគេធ្វើការជាមួយគ្នាជាក្រុម។

ការបង្កើត និងការរៀបចំឯកសារបង្រៀន

ឯកសារបង្រៀនអាចបែងចែកជាច្រើនផ្នែក ដែលត្រូវបង្រៀនសំរាប់មេរៀនខុសៗគ្នា ក្នុងពេលឆ្នាំសិក្សាដោយផ្អែកលើពេលវេលាដែលមាន។ កម្មវិធីបែបនេះហាក់បីដូចជាតំរូវអោយការបង្រៀនខ្លះមានរយៈពេលវែងនៅពេលចាប់ផ្តើមដំបូង ប៉ុន្តែលោកគ្រូអ្នកគ្រូមានលទ្ធភាពស្រូបយកនូវចំណេះដឹងនិងឯកសារថ្មីៗទាំងនេះក្នុងរយៈពេលដ៏ខ្លីបាន។ ប្រធានបទបណ្តុះបណ្តាលត្រូវត្រូវរៀនចំដោយសមញ្ញងាយស្រួល ហើយច្បាស់លាស់។ ឯកសារខ្លះអាចត្រូវបានផ្លាស់ប្តូរ ដោយផ្អែកលើស្ថានភាពតំបន់នានា។ ក្នុងករណីអង្គការម្លប់បៃតង យើងបានបែកចែកឯកសារបង្រៀន សំរាប់ឆ្នាំដំបូងជា ៤ ប្រភេទដូចខាងក្រោម:

១- ការបង្កើតក្លឹប: នៅក្នុងប្រធានបទនេះ លោកគ្រូអ្នកគ្រូត្រូវបានផ្តល់ការណែនាំអំពី វិធីបង្កើតក្លឹប។ ឯកសារនេះអាចផ្តល់ជាមូលដ្ឋានសំរាប់ការបណ្តុះបណ្តាលនេះ។

២- ការគ្រប់គ្រងកាកសំណល់នៅក្នុងសាលា:

ប្រធានបទនេះពាក់ព័ន្ធទៅនិងការបែងចែកប្រភេទ

កាកសំណល់ជាពីរ - កាកសំណល់ដែលងាយរលួយ និងកាកសំណល់ដែលមិនរលួយ ហើយ អំពីវិធីកំទិច ឬដុតចោលកាកសំណល់នីមួយៗអោយត្រឹមត្រូវ ។ បន្ថែមពីនេះទៀតអ្នកចូលរួមអាចយល់ដឹងពីការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការយកសំរាមមកកែច្នៃឡើងវិញ ។

៣- សាលាបៃតងៈ ប្រធានបទនេះ ផ្តោតលើសោភ័ណភាពសាលារៀនតាមរយៈការរៀបចំដាំដុះគ្រាប់ពូជ ការដាំដុះកូនឈើ និងការធ្វើសួនច្បារ (សួនផ្កា បន្លែ និងសួនឱសថធម្មជាតិ) ។

៤- ការប្រមូលពត៌មានអំពីបរិស្ថាន និងការផ្សព្វផ្សាយៈ នៅក្នុងផ្នែកនេះ អ្នកចូលរួមសិក្សាអំពីបញ្ហាបរិស្ថានផ្សេងៗ នៅក្នុងតំបន់រស់នៅរបស់គេ និងនៅក្នុងប្រទេសកម្ពុជា ។ ពួកគេសិក្សាពី មធ្យោបាយប្រមូលពត៌មាននានាដូចជា តាមរយៈបុគ្គលដែលមានបទពិសោធន៍ ប្រព័ន្ធផ្សព្វផ្សាយដូចជា វិទ្យុ ទូរទស្សន៍ និងកាសែតនានាជាច្រើន ។ បន្ថែមពីនេះទៀត ពួកគេសិក្សាពីការផ្សព្វផ្សាយសំរាប់សិស្សផ្សេងៗទៀត និងសហគមន៍ អំពីការបង្កើតការទំនាក់ទំនងគាំទ្រ ទៅវិញទៅមករវាងសាលា និងសហគមន៍ ។

## វិធីសាស្ត្រនៃការចូលរួម

ដោយអ្នកចូលរួមជាច្រើននៅក្នុងសិក្ខាសាលា ជាមនុស្សមានបទពិសោធន៍ និងចេះដឹងអំពីបរិបទ នៃបញ្ហាបរិស្ថាននៅក្នុងតំបន់របស់គេ រាល់គំនិតទស្សនៈ ជាកត្តាដ៏សំខាន់សំរាប់ជាធនធានអនុវត្តការងារ ។ ដូច្នេះនៅក្នុងការចូលរួមធ្វើសិក្ខាសាលា និងសកម្មភាពនានាដែលពាក់ព័ន្ធគួរត្រូវបានយកមកប្រើប្រាស់ ។ ហើយអ្នកដែលទទួលបាននូវសារៈប្រយោជន៍ គឺអ្នកចូលរួមដោយផ្ទាល់ ។

គោលបំណងនៃការបណ្តុះបណ្តាល គឺផ្តោតទៅលើការផ្តល់ពួកគេនូវចំណេះដឹងជំនាញ និងការផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ ដើម្បីឆ្ពោះទៅរកការពង្រឹងកែលំអរនូវបរិស្ថាន ទាំងនៅក្នុងនិងក្រៅ សាលារៀន ព្រមទាំងធ្វើការគាំទ្រដល់ពួកគេអោយបង្រៀន និងណែនាំសមាជិកក្រុមប្រកបដោយ ប្រសិទ្ធភាព ។ ដូច្នេះអ្នកចូលរួមទាំងអស់ មានតួនាទីយ៉ាងសកម្ម ទាំងនៅក្នុងក្រុមការងារ **និងការងារផ្ទាល់ខ្លួន** ។ ពួកគេនិងអាចត្រូវបានសុំអោយចូលរួមធ្វើការជាក្រុមដើម្បីផ្លាស់ ប្តូរទស្សនៈ **និងបទពិសោធន៍** ហើយអនុវត្តជាក់ស្តែងនូវសកម្មភាពផ្សេងៗ ដែលពួកគេចាំបាច់ **ត្រូវសហការជាមួយសិស្សនានា** ដូចជា ល្បែងប្រាជ្ញា និងល្បែងកំសាន្តផ្សេងៗទៀត ។

ក្នុងពេលដែលលោកគ្រូ អ្នកគ្រូ យល់ដឹងនូវវោហាសាស្ត្រ នៃការបង្រៀនសិស្សមជ្ឈមណ្ឌល **វាជាកត្តាមួយដ៏សំខាន់**ដើម្បីបញ្ចោក់ឡើងវិញអំពីយុទ្ធសាស្ត្រនេះក្នុងសិក្ខាសាលា ។ នេះជាចំណុចមួយដែលអាចជំរុញអោយអ្នកចូលរួមបញ្ចេញគំនិតផ្ទាល់ខ្លួន ក្នុងការដោះស្រាយបញ្ហា និងវាយតំលៃនូវលទ្ធផលទាំងនោះ ។

## ការជ្រើសរើសតាមលំនាំមេរៀនដែលមានស្រាប់និងការបង្កើតមេរៀនថ្មីៗ

ការបង្រៀននៅក្នុងថ្នាក់ធម្មតា លោកគ្រូអ្នកគ្រូគួរអោយធ្វើការអនុវត្តន៍យ៉ាងត្រឹមត្រូវទៅតាម ឯកសារមេរៀនថ្នាក់ជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីការសិក្សារបស់ក្លឹបបរិស្ថាន អ្នកសំរបសំរួលមានភាពបត់បែន និងសេរីភាពយ៉ាងល្អប្រសើរ ដើម្បីបង្កើតគំនិតថ្មីៗ និងជំនាញក្នុងការបង្រៀន ។ គាត់អាចបង្ហាញនូវឯកសារ អំពីបរិយាកាសអប់រំដែលរៀបចំដោយអង្គការម្លប់បៃតង និងអង្គការផ្សេងៗទៀត ដើម្បីប្រមូលគំនិត និងបង្កើនចំណេះដឹង ។ មេរៀនទាំងនេះត្រូវបានអនុវត្តយ៉ាងជិតស្និទ្ធ ហើយអ្នកសំរបសំរួលក្លឹបអាចជ្រើសរើសយកលំនាំឯកសារទាំងនោះណាមួយ **បើសិនគាត់យល់**ឃើញថាមានលក្ខណៈសមស្រប ។

នៅក្នុងឯកសារមេរៀនថ្នាក់ជាតិ មានមេរៀនខ្លះ ពាក់ព័ន្ធទៅនិង**បរិស្ថាន**ដែលបានដាក់ចូលនៅក្នុងមុខវិជ្ជាជាច្រើន ជាពិសេសនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រធម្មជាតិ ។ **វាជាកត្តាមួយដ៏សំខាន់សំរាប់**អ្នកចូលរួមបង្ហាញពីការទាក់ទងទៅនិងឯកសារមេរៀនថ្នាក់ជាតិ **ហើយរំលឹកដល់ សិស្សអំពីសំភារៈថ្មីៗ**នេះ មានការពាក់ព័ន្ធទៅនិងអ្វីដែលពួកគេកំពុងសិក្សនៅក្នុងថ្នាក់ធម្ម**តាដែរ** ។ នៅក្នុងសៀវភៅណែនាំអំពីសកម្មភាពអប់រំបរិស្ថាន ទំព័រយោងខ្លះមានសារៈសំខាន់ណាស់ ដោយបង្ហាញពីការ

ទាក់ទងទៅ និងសកម្មភាពនៅតាមទីកន្លែងដូចមានចែងក្នុងឯកសារមេរៀនថ្នាក់ជាតិផងដែរ។ នេះជាកត្តាមួយយ៉ាងសំខាន់សំរាប់អ្នកចូលរួមទាំងអស់ ធ្វើការកែលំអរនូវមេរៀនថ្មីៗ ផងដែរ។ មេរៀនគួរចងក្រងអោយមានប្រសិទ្ធិភាពសំរាប់សិស្សសិក្សា និងដើម្បីពង្រីងបរិស្ថានផ្ទាល់របស់ពួកគេ។ ទោះបីក្រោយពីបញ្ចប់សិក្ខាសាលាហើយក៏ដោយ អ្នកសំរបសំរួលអាចបង្កើតនូវផែនការមេរៀនរបស់គេថែមទៀត ដើម្បីអោយស្របទៅនឹងទិសដៅ និងគោលបំណងនៃផែនការប្រចាំឆ្នាំ។ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលត្រូវបាននាំចូល យ៉ាងពេញទំហឹង ដើម្បីអនុវត្តផែនការនេះ អ្នកសំរបសំរួលគួរកំណត់នូវគោលបំណងសិក្សា ពេលវេលា ក្រុមចំណុច និងទីកន្លែងសំរាប់ធ្វើសកម្មភាព។ គំរូសាមញ្ញមួយនៃផែនការមេរៀនបានបង្ហាញដូចខាងក្រោម:

ប្រធានបទ:....................................

គោលបំណងការសិក្សា: -ចំណេះដឹង ជំនាញ ឥរិយាបថ (ធ្វើជាសកម្មភាព)

រយៈពេល: ..........................

ក្រុមគោលដៅ/កិរិត:

ទីកន្លែង: ក្នុងថ្នាក់/ខាងក្រៅ

វិធីធ្វើសកម្មភាព:

| អនុ-ប្រធានបទ | និតិវិធី | ពេលវេលា | សំភារ: |
|---|---|---|---|
| | | | |
| | | | |

ការវាយតំលៃ និងការបន្តសកម្មភាព

ការរៀបចំសំភារ:

រាល់សំភារ:សំរាប់មេរៀន ឬសិក្ខាសាលាត្រូវបានគេហៅថា ឯកសារជំនួយការសិក្សា។ ឯកសារទាំងនេះរួមទាំងឯកសារផ្សេងៗទៀតដែលអាចជួយដល់អ្នកចូលរួមដើម្បីសិក្សា។ ឯកសារទាំងនេះអាចជាទំរង់រូបភាព ឬ ជាវីដេអូ។ ដើម្បីជាជំនួយ គ្រូបង្រៀនត្រូវពិចារណាដោយបាន ហ្មត់ចត់អំពីសំភារៈដែលគេត្រូវការ និងវិធីទុកដាក់សំភារៈទាំងនោះ នៅពេលគេត្រូវការប្រើវា។ ឯកសារជំនួយការសិក្សាប្រកបដោយប្រសិទ្ធិភាព គឺមានអក្សរកាត់ខាងដើមដូចជា (MAGIC):

M: Meaningful :ដែលពោរពេញដោយអត្ថន័យ

A: Attractive : ដែលទាក់ទាញអារម្មណ៍

G: Graphic : ដែលមានលក្ខណៈជារូបភាព

I: Interesting: ដែលគួរអោយចាប់អារម្មណ៍

C: Cost considering: មានតំលៃសមស្រប

រាល់ឯកសារទាំងអស់នេះ ត្រូវរៀបចំអោយត្រឹមត្រូវជាមុន។ នៅពេលអនុវត្តការបណ្តុះបណ្តាលសំភារៈទាំងនេះ ត្រូវរៀបចំតាមលំដាប់លំដោយទៅសកម្មភាពការងារ ដូចនេះពួកគេនឹងមានការងាយស្រួលរកវា។

## ការពិនិត្យតាមដាន និងការវាយតំលៃ

រាល់គំរោងនីមួយៗមានទិសដៅរយៈពេលវែង ហើយបានកំណត់នូវគោលបំណងដ៏ច្បាស់លាស់ និងលទ្ធផលដែលបានរំពឹងទុកទៅតាមការកំណត់ពេលវេលាមួយជាក់លាក់។ការត្រួតពិនិត្យ តាមដានជាដំណើរការមួយនៃការតាមដាន និងការពិនិត្យដោយយកចិត្តទុកដាក់នូវស្ថានភាព នៃគំរោងកម្មវិធីមួយដើម្បីពិនិត្យមើលថា តើមានការប្រែប្រួល ឬ ជឿនលឿនរីកចំរើនដល់ណាហើយ។ គោលបំណងនៃការត្រួតពិនិត្យតាមដាន និង វាយតំលៃ គឺដើម្បីបង្ហាញនិងគាំទ្រដល់ ដំណើរការកម្មវិធីក្នុងការសំរេចនូវលទ្ធផលដែលរំពឹងទុកហើយដើម្បីឆ្លើយតបទៅនិងគោលបំណងនានា ដែលបានកំណត់។ លទ្ធផលនានាដែលទទួលបានពីការត្រួតពិនិត្យវាយតំលៃជាមូលដ្ឋានមួយ សំរាប់ធ្វើការពិចារណាផ្លាស់ប្តូរ ឬការរីកចំរើនជឿនលឿនទៅតាមការកំណត់ ដើម្បីអោយដឹងថាតើពួកគេមានសារៈប្រយោជន៍ឬមានតំលៃយ៉ាងណា? ដើម្បីអោយដឹងពីកត្តានេះនិទស្សន៍មួយត្រូវបានបង្កើតឡើងជាមុននៅពេល

ធ្វើគំរោងរង្វង់ផែនក។

ទិសដៅនៃការត្រួតពិនិត្យ និងការវាយតំលៃដាច់ខាតត្រូវតែកំណត់។ ដំណើរការនៃការត្រួតពិនិត្យធ្វើទៅតាមប្រព័ន្ធទិន្ន័យ និងប្រមូលពតិមានដោយប្រើនូវនិតិវិធីសាមញ្ញ និងឧបករណ៍ងាយស្រួលច្បាស់លាស់។ របាយការណ៍នៃការត្រួតពិនិត្យ និងការវាយតំលៃជាលទ្ធផលមួយបង្ហាញពីដំណើរការត្រួតពិនិត្យ និងវាយតំលៃ។ ផ្នែកមួយដែលមានសារៈសំខាន់នៃរបាយការណ៍មានដូចជា ការវិភាគស្ថានភាពនៃគំរោងកម្មវិធី ដោយផ្អែកលើទិទស្សន៍ដែលបានប្រមូល និងការធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

*ការរៀបចំតារាងត្រួតពិនិត្យ និងការវាយតំលៃ*

មានសកម្មភាពសំខាន់ៗជាច្រើន សំរាប់ក្លឹបបរិស្ថានអនុវត្ត រួមមានបរិយាកាសអប់រំសំរាប់សមាជិកក្រុម ការអនុវត្តន៍ជាក់ស្តែងនូវការពង្រឹងបរិស្ថានសាលារៀន។ ដូចនេះគោលបំណងបីធំៗ នៃ ការត្រួតពិនិត្យតាមដាន និងការវាយតំលៃដែលចាំបាច់ត្រូវធ្វើការពិចារណា។ នេះមានន័យថា យើងត្រូវបង្កើតតារាងនិង ឧបករណ៍សំរាប់ធ្វើការត្រួតពិនិត្យនិងវាយតំលៃបីដោយឡែកពីគ្នា: គំរូប្រព័ន្ធនៃការត្រួតពិនិត្យ និងវាយតំលៃសំរាប់ក្លឹប ត្រូវបានបង្ហាញក្នុង ឧបសម្ព័ន្ធ ១៣។

## អនុវត្តការត្រួតពិនិត្យ ការដោះស្រាយបញ្ហា និងការផ្តល់យោបល់

ក្នុងការអនុវត្តន៍ការត្រួតពិនិត្យលោកអ្នកត្រូវធ្វើការប្រមូលពតិមានដែលពាក់ព័ន្ធអោយបានគ្រប់គ្រាន់។ ហើយលោកអ្នក ចាំបាច់ត្រូវមានតារាង និងឧបករណ៍ត្រួតពិនិត្យ និងវាយតំលៃអោយបានគ្រប់គ្រាន់ផងដែរ តារាង និងឧបករណ៍ទាំងនោះ មានលក្ខណៈសមរម្យ ទៅនិងនិតិវិធីដែលអ្នកយកមកប្រើប្រាស់។ ទីកន្លែង ពេលវេលា កាលបរិច្ឆេទ សំរាប់រយៈពេលការត្រួតពិនិត្យ និងសកម្មភាពនានា ដែលលោកអ្នកត្រូវត្រួតពិនិត្យ ត្រូវធ្វើការកំណត់អោយច្បាស់លាស់។ បើសិន លោកអ្នកត្រួតពិនិត្យអ្នកណាម្នាក់ ឧទាហរណ៍ អ្នកសំរបសំរួលក្នុងពេលធ្វើការបណ្តុះបណ្តាល លោកអ្នកគួរជួយអោយគាត់មានអារម្មណ៍ល្អ ជ្រះថ្លាក្នុងចិត្ត។ មនុស្សដែលមានអារម្មណ៍ល្អជ្រះថ្លាក្នុងចិត្ត និងធ្វើការជាធម្មតា ហើយអ្នកដែលត្រូវសំភាសន៍មានអារម្មណ៍ល្អជ្រះថ្លា តែងតែផ្តល់ចំលើយងាយស្រួល ជាងអ្នកដែលត្រូវសំភាសន៍ណា ដែលមានអារម្មណ៍តានតឹងក្នុងចិត្ត។ មធ្យោបាយ ដែលអ្នកត្រូវធ្វើចរិតឬកពារ ព្រមទាំងវិធីសាស្រ្តនិយាយ និងទឹកមុខដែលអាចធ្វើអោយអ្នក ដែលត្រូវធ្វើសំភាសន៍មាន អារម្មណ៍ជ្រះថ្លាថែមទៀត។

**ក្នុងពេលធ្វើការត្រួតពិនិត្យ** ជាពិសេសនៅពេលកំពុងសំភាសន៍ លោកអ្នកត្រូវតែកត់ត្រា **នូវរាល់ទិន្ន័យដែលអាចទុកចិត្តបានដូចជា ពតិមាន** ឯកសារនានា ឬចំលើយផ្សេងៗ ដែលអ្នក បានឃើញ **ឬទទួល ហើយលោកអ្នកមិនត្រូវផ្លាស់ប្តូរវាទៅតាមការចង់បានរបស់អ្នកឡើយ។** លោកអ្នកត្រូវតែ **ជៀសវៀងនូវសំណួរខាងក្រោយ ឬដើមសំណួរ។** ឧ. "**អ្នកបានអានព្រឹត្តបត្ត ទាំងអស់ តើមែនរឺទេ? ហើយអ្នកត្រូវជៀសវៀងផងដែរ នូវការវាយតំលៃមុន។** ក្នុងការសួរជា សំណួរ វាមានសារៈសំខាន់ណាស់ **សំរាប់ធ្វើអោយអ្នកដែលត្រូវសំភាសន៍មិនមានអារម្មណ៍ថា**
**ទទួលនូវការគំរាមកំហែងតាមរយៈសំណួររបស់អ្នកឡើយ។** ដើម្បីជៀសវាងបញ្ហានេះ លោកអ្នក ត្រូវ :

- មិនត្រូវអានសំណួរទៅអ្នក ដែលត្រូវសំភាសន៍ទេ
- លោកអ្នកត្រូវមើលទៅមុខគាត់ នៅពេលសួរសំណួរ
- នៅពេលគាត់ផ្តល់ចំលើយ លោកអ្នកត្រូវធ្វើហាក់ដូចជាមានចំណាប់អារម្មណ៍ណាស់
- មិនត្រូវបង្ហាញការមិនពេញចិត្តនូវចំលើយនានារបស់គាត់ឡើយ ឧទាហរណ៍: ដោយការគ្រវីក្បាល ឬចងចិញ្ចើម។

ផ្តើមចេញពីទិន្ន័យពតិមាន ឬទិទស្សន៍ដែលអ្នកទទួលបាន ជួនកាលអ្នកអាចវិភាគ និងធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងឆាប់ ហើយអ្នកអាចផ្តល់ជាពតិមានត្រឡប់ ឬយោបល់ដល់គាត់វិញភ្លាមៗដែរ ក្នុងលក្ខណៈសុភាពរាបសារដើម្បីដោះស្រាយបញ្ហា។ ប៉ុន្តែជួនកាលអ្នកក៏មិនអាចធ្វើទៅបាន ឬអ្នកមិនត្រូវធ្វើភ្លាមៗនោះទេ។ ក្នុងករណីនេះ អ្នកត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីប្រមូលនូវរាល់ទិទស្សន៍ទាំងអស់។ ជួនកាលអ្នកត្រូវធ្វើការពិចារណាអំពីកត្តាផ្សេងៗ ពីខាង ក្រៅទៀតផង។ បន្ទាប់អ្នកធ្វើការវិភាគទៅលើស្ថានភាពដោយប្រើប្រាស់ទិទស្សន៍ ដែលអ្នកមាន បន្ទាប់មកទៀតអ្នកត្រូវធ្វើសេចក្តីសន្និដ្ឋាន និងសរសេរអនុសាសន៍។ ជាចុងក្រោយ អ្នកត្រូវ សរសេររបាយការណ៍។

## ការដោះស្រាយបញ្ហា និងគន្លឹះសំរាប់ដំណើរការក្លឹបអោយបានជោគជ័យ

ជាទូទៅគេតែងតែជួបប្រទះនូវបញ្ហាខ្លះៗ និងការខិតខំប្រឹងប្រែងក្នុងការដំណើរការក្លឹបបរិស្ថាន។ ខាងក្រោមជាបញ្ជីបញ្ហានានាដែលបានជួបប្រទះដោយអង្គការ ម្លប់បៃតង ក៏ដូចជាគំនិតខ្លះៗដើម្បី ដោះស្រាយបញ្ហាទាំងនេះ ។ បើសិនជាអ្នកបានចូលរួមមុនពេលបញ្ហាទាំងនេះកើតមាន នោះមានន័យថា អ្នកអាចដោះស្រាយបញ្ហានានាបានពាក់កណ្តាលរួចជាស្រេចទៅហើយ ។

● ***អ្នកសំរបសំរួលក្លឹបបរិស្ថាន មានចំនោទលើកទៅសកម្មភាពនានារបស់ក្លឹប តែមិនជឿនូវសមត្ថភាពរបស់សិស្សដែលអាចដឹកនាំធ្វើសកម្មភាពដោយខ្លួនឯងបាន***

**នេះជាការខិតខំប្រឹងប្រែងមួយដ៏ធំសម្បើម** ពីព្រោះអ្នកសំរបសំរួលក្លឹបបរិស្ថាន ភាគ**ច្រើនមានលក្ខណៈយល់ដឹង ពីបរិយាកាសនៃវិធីសាស្ត្រគ្រូមជ្ឈមណ្ឌល** ហើយពួកគេមានបទ**ពិសោធន៍របៀបបង្រៀនថ្មីៗ** ដែលមាន លក្ខណៈខុសប្លែកពីអ្វីដែលពួកគេធ្លាប់ធ្លាប់បានបង្រៀន ។ **បន្ថែមពីនេះ សិស្សអាចមានការយឺតយ៉ាវ**ក្នុងការយកលំនាំតាមវិធីសាស្ត្របង្រៀនថ្មីៗនេះ ដោយ**វិធីសាស្ត្រនេះជារបៀបថ្មីបំផុតសំរាប់ពួកគេ** ហើយពួកគេកម្រនឹងត្រូវបានសួរ អោយធ្វើការគិតពិចារណាដោយខ្លួនឯងបែបនេះណាស់ ។ កត្តានៃដំណើរការក្លឹបនេះតំរូវអោយមានការជំរុញឡើងវិញអោយស្របទៅនិងការគាំទ្រតាមរយៈសិក្ខាសាលាបណ្តុះបណ្តាល និងការវាយតំលៃ ។ នេះជាកត្តាមួយដែលត្រូវដាក់ចូលផងដែរនូវនិទស្សន៍ សំរាប់ផ្នែកនេះនៅក្នុងគំរោងការវាយតំលៃ ដូចជា ពិនិត្យមើលសមត្ថភាព ការដឹកនាំរបស់សិស្សឬចំណេះដឹងទាក់ទងនិងជំនាញក្នុងការរៀបចំកិច្ចប្រជុំផ្សេងៗ។



● **ការបណ្តុះគ្រាប់ពូជ នៅតាមសាលាជាច្រើន បានស្លាប់ដោយការខ្វះជំនាញដាំដុះ** និងការ**ថែរក្សាមធ្យោបាយជាច្រើនដើម្បីពង្រឹងការដាំដុះគ្រាប់ពូជដូចជា:**

- ត្រូវដឹងច្បាស់ថា គ្រាប់ពូជមានគុណភាពល្អ
- ត្រូវដឹងច្បាស់ថា គ្រាប់ពូជ និងស្ថានភាពដីមានលក្ខណៈស្របគ្នា
- ប្រមូលពត៌មាននានា អំពីការដាំដុះគ្រាប់ពូជបែបនេះពីអ្នកមានបទពិសោធន៍ ជាមួយអង្គការក្រៅរដ្ឋាភិបាល ឬសហគមន៍។ សាកសួរអំពីបញ្ហា និងមធ្យោបាយបាញ់ថ្នាំសំលាប់សត្វល្អិតដែលស៊ីគ្រាប់ពូជ ស៊ីគ្រាប់ពូជ(បើមាន) ។
- ធានាអោយមានទឹកគ្រប់គ្រាន់ សំរាប់ការដាំដុះពេញមួយឆ្នាំ
- ការពារកុំអោយមានគោ ឬសត្វពាហនៈ ផ្សេងៗចូល (ដោយធ្វើរបងការពារ)
- ប្រើប្រាស់ជីធម្មជាតិ ដើម្បីបង្កើនការដាំដុះ
- ដាំដុះអោយបានល្អមុនពេលរដូវក្តៅ ដើម្បីកាពារពីភាពរាំងស្ងួត
- ស្រោចទឹកជាប្រចាំ
- បង្កើតវិធីច្បាស់លាស់ ដើម្បីថែរទាំគ្រាប់ពូជ មុនពេលយកមកដាំដុះ

● សកម្មភាពបោសសំអាតអនាម័យ មានរយៈពេលខ្លី បន្ទាប់មកទីធ្លាសាលារៀនត្រូវគេពង្រាយពង្រាយសំរាមវិញ យ៉ាងលឿនការបោសសំអាតអនាម័យសាលារៀន មានលក្ខណៈងាយស្រួលបំផុត ប៉ុន្តែអ្វីដែលជាការលំបាក គឺការផ្លាស់ប្តូរទំលាប់ និងអាកប្បកិរិយារបស់លោកគ្រូ អ្នកគ្រូ និងសិស្សនៅតាមសាលារៀន ដើម្បីរក្សាអនាម័យសាលាអោយបានល្អ។ ដើម្បីពង្រឹងនូវសកម្មភាពនេះ អង្គការម្លប់បៃតង បានអនុវត្តនូវយុទ្ធសាស្ត្រ:

- ផ្តល់ធុងសំរាម/អនាម័យដល់សាលាអោយបានគ្រប់គ្រាន់
- ណែនាំសិស្សអំពីគ្រោះថ្នាក់ដល់សុខភាព ពីការបោះចោលសំរាមមិនត្រឹមត្រូវ (ជាពិសេសសំរាមដែលមិនងាយរលួយបាន)
- ចាត់តាំងសិស្សក្លឹបធ្វើការត្រួតពិនិត្យ ដើម្បីណែនាំដល់សិស្សផ្សេងៗទៀត អោយបោះចោល សំរាមអោយបានត្រឹមត្រូវ
- សុំអោយមានការចូលរួមគាំទ្រ ពីអ្នកលក់នៅក្នុងសាលា។ សុំអោយគាត់លក់តែអាហារដែល

ងាយស្រួល

- **វត្តមានសមាជិកក្លឹប មានការថយចុះនៅរដូវធ្វើស្រែចំការ**

ចំពោះហេតុផលនេះមានសារៈសំខាន់ណាស់ ដើម្បីចូលរួម និងជំរាបដល់ពុកម្តាយសមាជិកក្រុម អោយបានឡើងនាត់ដែលអាចធ្វើទៅបាន។ បើចាំបាច់ត្រូវរៀបចំការប្រជុំ កំណត់ពេលវេលា និង កាលបរិច្ឆេទ ដើម្បីសំរួលដល់ការចោះចុះ និងការប្រមូលផលរបស់ពួកគាត់។

- **ក្នុងថ្ងៃឈប់សំរាក សកម្មភាពសមាជិកក្រុមមិនត្រូវបានរៀបចំឡើយ**

ចំពោះបញ្ហានេះ អាចត្រូវបានដោះស្រាយដោយមានការចូលរួមគ្រប់សមាជិកក្រុមទាំងអស់ក្នុង ពេលធ្វើផែនកាប្រចាំឆ្នាំ និងត្រូវបានានៅពេលចាប់ផ្តើមដំបូងអោយពួកគេព្រមព្រៀងចូលរួម ទោះបីជា ក្នុងពេលថ្ងៃឈប់សំរាកក៏ដោយ។ កត្តានេះជាហេតុផលមួយផ្សេងទៀតដែលតំរូវអោយគ្រូសំរបសំរួល គួរតែជាអ្នកដែលមានទីតាំងរស់នៅ ជិតសាលារៀន។

- ផលវិបាកនៃសកម្មភាពការបង្កើនមូលនិធិ

នេះជាបញ្ហាមួយដ៏សំខាន់ ជាពិសេសបើមានអង្គការក្រៅរដ្ឋាភិបាលកំពុងជួយគាំទ្រដល់ក្លឹបនោះ។ ទោះបីយ៉ាងណា វាជាកត្តាមួយចាំបាច់ត្រូវធ្វើកាត់បន្ថយបន្តិចម្តងៗទៅលើប្រាក់ឧបត្ថម្ភរបស់អ្នកសំរបសំរួលក្លឹប ដើម្បីគាំទ្រនិងពង្រឹងសមត្ថភាពសំរាប់សកម្មភាពការបង្កើនមូលនិធិ និងចំណូល។

## សេចក្តីសន្និដ្ឋាន

### ការពិនិត្យលទ្ធផល

បើសិនជាលោកអ្នកអនុវត្តតាមឯកសារណែនាំនេះ លោកអ្នកនឹងបានឃើញ ភាពជោគជ័យ នៃការខិតខំប្រឹងប្រែងរបស់អ្នក ដែលមានការរីកចំរើនយ៉ាងខ្លាំង នៅក្នុងការយល់ដឹងអំពីបរិស្ថាន ក៏ដូចជាការផ្លាស់ប្តូរនូវទំលាប់ និងអត្តចរិតរបស់គ្រូ និងសិស្សដើម្បីឆ្ពោះទៅរកការអភិវឌ្ឍន៍សហគមន៍ របស់ពួកគេ។ វាជាកត្តាមួយដ៏សំខាន់ ដើម្បីធ្វើការវាយតំលៃនូវលទ្ធផលដែលទទួលបានទាំងនេះ ទាំងបរិមាណ និងគុណភាពព្រមទាំងចងក្រងឯកសារអំពីបទពិសោធន៍របស់អ្នកក្នុង ការបង្កើត ការគាំទ្រ និងការដំណើរការក្លឹប។ នៅក្នុងបទពិសោធន៍របស់យើង ការ**វាយតំលៃនូវលទ្ធផលទាំងនោះ** ដោយផ្អែកទៅលើ ការពេញចិត្ត និងកិច្ចសហការណ៍របស់គ្រូសំរបសំរួល**និងនាយកសាលា។ វាជាការសំខាន់ណាស់ដើម្បីកំណត់នូវបុគ្គលណាមួយ** ដែលមានឆន្ទៈបំរើការ ដើម្បី**ជាប្រយោជន៍សំរាប់សាលារៀន និងសហគមន៍ និងអ្នកដែលបានលះបង់ពេលដ៏មានតំលៃ** ដើម្បីអនុវត្ត**សកម្មភាពទាំងនេះ។**

### ការចែករំលែកបទពិសោធន៍របស់អ្នក

វាជាកត្តាមួយសំខាន់ណាស់ ដើម្បីធ្វើការវាយតំលៃនូវ **ការជោគជ័យ និងការបរាជ័យ**របស់អ្នកហើយត្រូវចងក្រងជាឯកសារនូវគំនិតទាំងនោះដើម្បីធ្វើការកែលំអរទៅថ្ងៃមុខ ធ្វើដូចនេះក្លឹបអាចធ្វើការអភិវឌ្ឍន៍កែលំអរអោយមានប្រសិទ្ធិភាព។ អង្គការម្លប់បៃតង មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការសិក្សាយល់ដឹងអំពីបទពិសោធន៍របស់លោកអ្នក ក្នុងការ បង្កើត និងដំណើរការក្លឹបបរិស្ថាន។ យើងសូមស្វាគមន៍នូវរាល់ពត៌មានត្រឡប់ និងមតិយោបល់ របស់អ្នក អំពីឯកសារណែនាំនេះ ហើយយើងខ្ញុំរីករាយនឹងផ្តល់ជាយោបល់ ដោយផ្អែកលើបទ ពិសោធន៍របស់យើង។ នៅក្នុងមជ្ឈមណ្ឌលធនធានអប់រំបរិស្ថានរបស់យើង មានឯកសារជាច្រើន ព្រមទាំងឯកសារជំនួយការបង្រៀន ដែលអាចអោយលោកអ្នកខ្ចីបាន ហើយបច្ចុប្បន្នបុគ្គលិកមជ្ឈមណ្ឌលរបស់យើង កំពុងបន្តធ្វើការផលិតឯកសារសំខាន់ៗ ជាច្រើនថែមទៀត។ លោក អ្នក នឹងទទួលបានការស្វាគមន៍ ក្នុងការខ្ចីឯកសារទាំងនេះ ហើយយើងក៏សូម



អោយលោកអ្នកជួយ ផ្តល់ឯកសារនានា របស់លោកអ្នកវិញផងដែរ ។

## និរន្តភាព

ផ្តើមចេញពីការអនុវត្តន៍សកម្មភាពដំបូង វាជាកត្តាមួយ ដែលមានសារៈសំខាន់ណាស់ក្នុងការពិចារណាទៅលើនិរន្តភាពការងារ ។ ដោយយោងទៅលើស្ថានភាពជាក់ស្តែងនៃប្រព័ន្ធអប់រំបច្ចុប្បន្នក្នុងប្រទេសកម្ពុជា មានគ្រូបង្រៀនតិចតួចណាស់ ដែលទទួលយកនូវការគ្រប់គ្រងក្លឹបបរិស្ថានមួយនេះដោយស្ម័គ្រចិត្តពិតប្រាកដ បើគ្មានប្រាក់ឧបត្ថម្ភទេនោះ ។ ដូច្នេះ វាជាការចាំបាច់ត្រូវផ្តល់ជូននូវប្រាក់ឧបត្ថម្ភ ថវិកាខ្លះៗ ឬអ្វីៗផ្សេងទៀត ។ ជាងនេះទៅទៀត វាមានសារៈសំខាន់ណាស់ក្នុងការរក្សាផ្តល់ប្រាក់ឧបត្ថម្ភនេះដោយមានកំរិតតិចតួច ហើយដោយផ្អែកលើគោលបំណងជាក់លាក់របស់គាត់ ធ្វើដូចនេះដើម្បីកាត់បន្ថយទៅលើការពឹងផ្អែកការគាំទ្រពីខាងក្រៅ ។ កត្តានេះ និងអាចធ្វើការផ្លាស់ប្តូរ ការអនុវត្តន៍សកម្មភាពក្លឹប ដោយឯករាជ្យម្ចាស់ការ និងប្រកបដោយ ភាពរលូនទៀតផង ។ ជាមួយគ្នានោះដែរ វានិងជំរុញអោយអ្នកសំរបសំរួល និងសិស្សមានអារម្មណ៍ ថាជាម្ចាស់នៃសកម្មភាពដែលពួកគេបានធ្វើដោយខ្លួនឯង ។ហើយនៅពេលដែលពួកគេអាចចាប់ ផ្តើម អនុវត្តសកម្មភាពគាំទ្រដោយខ្លួនឯងបានយ៉ាងឆាប់រហ័សនោះ ពួកគេក៏និងអាចមានលទ្ធភាពបង្កើត នូវចំណូលថវិកា របស់ពួកគេបានយ៉ាងឆាប់រហ័សផងដែរ ។



សូមជូនពរអោយបានសំណាងល្អដល់អ្នក និងក្លឹបរបស់អ្នក...

## ឧបសម្ព័ន្ធ I: សំនួរគន្លឹះ ដើម្បីកំណត់ការរើសសាលារៀន នៅពេលអោនការក្លឹបតាក់តែង

សូមពិនិត្យមើលសំនួរគន្លឹះខាងក្រោមមួយចំនួន ដែលបន្តដោយការពិភាក្សានៃបញ្ហាខ្លះៗនៅពីក្រោយសំនួរទាំងនេះ ។ ការជ្រើសរើសសាលារៀនត្រូវពឹងផ្អែកទាំងស្រុង ទៅលើធនធាន និងអាទិភាពរបស់អ្នក ហើយរាល់ចំលើយទាំងឡាយដែលត្រូវបានផ្តល់គ្រាន់តែជាគោលការណ៍ណែនាំប៉ុណ្ណោះ ។

១- *តើសាលារៀនមានកំរិតថ្នាក់ទី ៤ ទី៥ និងទី៦ដែររឺទេ?*

បើសិនសាលារៀនណាដែលមានកំរិតសិស្សអាចអាន និងសរសេរបាននោះ ការអនុវត្តសកម្មភាពក្លឹបក៏មានលក្ខណៈងាយស្រួលប្រសើរផងដែរ ។

២- *តើនាយកសាលាពេញចិត្តនិងគាំទ្រកម្មវិធីនេះដែររឺទេ?*

ការគាំទ្រពីនាយកសាលា គឺជាគន្លឹះមួយយ៉ាងសំខាន់ ដែលអាចសំរេចបានការជោគជ័យនៅក្នុងក្រុមពីព្រោះការសហការរបស់គាត់ត្រូវការចាំបាច់ដើម្បីអនុវត្តសកម្មភាពការងារជាច្រើន ។ ជាបន្ថែមទៀតមានការគាំទ្រពីនាយកសាលា និងជួយដល់និរន្តភាពរបស់ក្លឹបបរិស្ថាន ដោយសារគាត់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចរចារជាមួយការិយាល័យស្រុក និងសហគមន៍ដើម្បីសុំថវិកា និងធនធានផ្សេងៗទៀត ។

៣- *តើសាលារៀនអាចអោយយើង ធ្វើដំណើរទៅបានរឺទេ?*

បើសិនជាលោកអ្នកពិចារណាទៅលើសាលារៀនណា ដែលមានទីតាំងស្ថិតនៅឆ្ងាយពីផ្លូវធំ (ហើយលោកអ្នកមិនមានទីតាំងការិយាល័យប្រចាំនៅទីនោះ) ដូចនេះអ្នកគួរពិចារណាលើពេលវេលា និងធនធានដែលអ្នកចាំបាច់ ត្រូវប្រើប្រាស់ដើម្បីធ្វើដំណើរ អោយទៅដល់សាលារៀននៅទីនោះ ។ នៅក្នុងរដូវខ្លះការធ្វើដំណើរពិតជាមិនអាចធ្វើទៅបានឡើយ ។ សាលារៀនតាម ជនបទ តែងតែត្រូវការជាចាំបាច់ តែអ្នកជនបទតែងតែត្រូវការជាចាំបាច់ តែអ្នកត្រូវរើសអទិភាពសាលារៀនណាដែលត្រូវការ

ជាង ។ទោះបីយ៉ាងណាក៏ដោយអាទិភាពនេះត្រូវពឹងផ្អែកទៅនិងបញ្ហាពេលវេលា និងធនធាន ។

*៤- តើមានបញ្ហាបរិស្ថានសំខាន់ៗអ្វីខ្លះដែលពាក់ព័ន្ធទៅនិងបរិយាកាសជុំវិញសាលារៀន?*

ប្រសិនបើអាទិភាពសកម្មភាពរបស់អ្នកផ្តោតទៅលើបញ្ហាបរិស្ថាន នោះវាជាការសំខាន់ណាស់ ដែលអ្នកត្រូវធ្វើការពិចារណាទៅលើបញ្ហាបរិស្ថានជុំវិញសាលារៀន និងនៅក្នុងសហគមន៍នោះ ។ ឧទាហរណ៍ តើសាលារៀននោះស្ថិតនៅជិតតំបន់ព្រៃឈើ រឺសត្វព្រៃ ដែលកំពុងទទួលរងការគំរាមកំហែងរឺទេ? តើកសិករនៅទីនេះ ប្រើប្រាស់ថ្នាំគីមីច្រើនសំរាប់សំលាប់សត្វល្អិតរឺទេ? តើតំបន់នេះ កំពុងទទួលរងនូវការច្រោះទឹក និងភាពរាំងស្ងួតបណ្តាលមកពីការកាប់ បំផ្លាញព្រៃឈើដែរឺទេ? បញ្ហាបរិស្ថានកើតមានគ្រប់ទីកន្លែងទាំងអស់ប៉ុន្តែសាលារៀនខ្លះអាចមានការរងគ្រោះ ច្រើនជាងសាលារៀនផ្សេងៗទៀត ។

*៥- តើសាលារៀនមាននូវសំភារៈដូចខាងក្រោមនេះរឺទេ?*

- ទឹក
- របង
- បង្គន់អនាម័យ
- ដីធំទូលាយសំរាប់ដាំកូនឈើ និងធ្វើសួន

កត្តាដូចបានរៀបរាប់ខាងលើ និងផ្តល់ភាពងាយស្រួល ក្នុងការអនុវត្តន៍សកម្មភាពក្លឹបបរិស្ថាន ហើយសំខាន់ជាងនេះទៅទៀត បើសិនជាធនធានសំរាប់ការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ នៅមានកំរិតទាបផងនោះ ។

*៦- តើមានការចាប់អារម្មណ៍ទូទៅអ្វីខ្លះទៅលើសាលារៀន និងទីធ្លាសាលា?*

មានសាលារៀនខ្លះ ធ្វើអោយមានការចាប់អារម្មណ៍ភ្លាមៗ ទៅនិងការមិនយកចិត្តទុកដាក់ នៅពេលដែលសាលារៀនផ្សេងៗទៀតបង្ហាញពីការព្យាយាមនិងមានការគាំទ្រខ្លះៗពីបុគ្គលិកសាលា ទៅលើបរិយាកាសសិក្សា ។ ប្រសិនបើ អ្នកបានឃើញនូវសញ្ញាខ្លះៗ ពីការចាប់អារម្មណ៍របស់បុគ្គលិក និង សិស្សពីការសំអាតសាលារៀន ( ឧ. ទីធ្លាសាលាមានសំរាមតិចតួច តាមជញ្ជាំងមានបិតរូបភាពនានា ។ល។ ) នេះជាសញ្ញាបញ្ជាក់ថា លោកគ្រូ អ្នកគ្រូមានចិត្តរីករាយ និង ឆន្ទៈគាំទ្រកម្មវិធីរបស់អ្នក ។

*៧- តើមានអង្គការដ៏ទៃទៀតកំពុងសហការជាមួយសាលារៀននេះរឺទេ? ប្រសិនបើមាន?*

ត្រូវធ្វើការពិនិត្យមើលថាតើ សាលារៀននេះធ្លាប់បានទទួលការឧបត្ថម្ភគាំទ្រ ពីអង្គការក្រៅរដ្ឋាភិបាលនានាកន្លងមក ។ការជោគជ័យ រឺការបរាជ័យនៃគំរោងកម្មវិធីកន្លងមក អាចជាការបង្ហាញនូវវិធីសាស្រ្តដ៏ល្អមួយ ដែលគំរោងក្លឹបបរិស្ថាន ត្រូវបានអនុវត្តទៅតាមលំនាំការងារ ។

*៨- តើសាលារៀននេះ មានទំនាក់ទំនងជាមួយសាលារៀនផ្សេងៗទៀតនៅក្នុងស្រុកយ៉ាងដូច ម្តេច?*

ប្រសិនបើសាលារៀននេះ មានការឧបត្ថម្ភគាំទ្រដោយអង្គការ UNICEF ឬមានទំនាក់ទំនងផ្ទាល់ជាមួយសាលារៀនផ្សេងៗទៀត នៅក្នុងស្រុកនោះ ដូច្នេះទីតាំងរបស់វាអាចជួយសំរួលដល់ការផ្សព្វផ្សាយ ដល់ការផ្សព្វផ្សាយ គំនិតផ្សេងៗអំពីសកម្មភាពក្លឹបបរិស្ថាន ទៅសាលារៀនផ្សេងទៀត ។

*៩- តើមន្រ្តីអប់រំស្រុកមានយោបល់អ្វីខ្លះ ពាក់ព័ន្ធទៅនិងសាលារៀននេះ?*

ការិយាល័យអប់រំស្រុក តែងតែមានបំណងចង់ធ្វើការផ្លាស់ប្តូរពត៌មាន អំពីកិត្តិយសមុខមាត់សាលាហើយនិងអាចប្រមើលមើលនូវភាពងាយស្រួលក្នុងការរួមធ្វើការសហការដើម្បីអនុវត្តគំរោង ។

**ឧបសម្ព័ន្ធ II: គំរូពាក្យស្នើសុំទៅក្រសួង អប់រំ យុវជន និងកីឡា**

ថ្ងៃ ខែ ឆ្នាំ:

ក្រសួង/នាយកដ្ឋានអប់រំ

អាស័យដ្ឋាន:

សូមគោរព លោក/លោកស្រី ........................

ខ្ញុំ/អង្គការក្រៅរដ្ឋាភិបាល សូមស្នើសុំនូវសេចក្តីសំរេច ដើម្បីបង្កើតក្លឹបបរិស្ថានមួយនៅ

សាលារៀន ............... មានទីតាំងស្ថិតនៅ ...............ឃុំ/ស្រុក/ខេត្ត........................។

ក្លឹបបរិស្ថាន គឺជាក្រុមសិស្សស្ម័គ្រចិត្ត ដែលចូលរួមទាំងអស់គ្នា **ដោយមានគោលបំណង** ដើម្បីសិក្សាអំពីបរិស្ថាន និងដើម្បីជួយពង្រឹងនូវវិស័យបរិស្ថាន។ **ក្លឹបបរិស្ថាននៅសាលារៀន** ........... និងត្រូវបានគ្រប់គ្រងដោយ .....................។ **គាត់នឹងជួយរៀបចំសិស្ស និងផ្តល់ការ**ណែនាំ អំពីដំណើរការក្រុម និងអនុវត្តសកម្មភាពការងារ។ **ការប្រជុំ (ប្រហែលមួយដង ក្នុងមួយ**សប្តាហ៍) នឹងត្រូវធ្វើឡើងក្រៅម៉ោងសិក្សា **ដូចនេះវាមិនមានផលប៉ះពាល់ដល់កម្មវិធីសិក្សា**ជាតិឡើយ។

កម្មវិធីក្លឹបបរិស្ថាន មានសក្តានុភាពក្នុងការរួមចំណែកយ៉ាងសំខាន់ដើម្បីពង្រឹងបរិយាកាសសិក្សាក្នុងសាលារៀន។ **ក្លឹបបរិស្ថានក៏គាំទ្រដល់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល តាមរយៈការដឹកនាំ**សិស្សក្នុងក្រុម និងមេរៀនក្រៅប្រព័ន្ធដូចជា "**សាលាកុមារមេត្រី តាមរយៈការកែលំអទីធ្លាសាលា** និងក្នុងថ្នាក់រៀនដូចជាការដាំដុះកូនឈើ **និងការធ្វើសួន។ ជាទីបញ្ចប់ ក្លឹបបរិស្ថានមានគោលបំណង** ដើម្បីបង្កើតនូវការទំនាក់ទំនងគាំទ្រទៅវិញទៅមក **រវាងសាលារៀន និងសហគមន៍ផងដែរ**។

បើសិនលោក លោកស្រី មានបំណងចង់ធ្វើ**ការពិភាក្សាលំអិតបន្ថែម សូមទាក់ទងយើង**ខ្ញុំ។ យើង សង្ឃឹមថាការបង្កើតក្លឹបបរិស្ថាន **នឹងចាប់ផ្តើមនៅថ្ងៃទី............**។

ខ្ញុំសូមថ្លែងអំណរគុណទុកជាមុន **ចំពោះការគាំទ្រនូវនិងការខិតខំប្រឹងប្រែង** របស់លោក លោកស្រី។

សូមលោក លោកស្រីទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

## ឧបសម្ព័ន្ធIII: ពិពណ៌នាការងាររបស់អ្នកសំរបសំរួលក្លឹបបរិស្ថាន

គោលបំណង: តួនាទីរបស់អ្នកសំរបសំរួលក្លឹបបរិស្ថាន គឺត្រូវផ្តល់ការណែនាំដល់ក្លឹប និងគាំទ្រដល់**ការដឹកនាំ**របស់សិស្សដើម្បីធ្វើការពង្រឹងកែលំអនូវបរិស្ថានសាលារៀន និងសហគមន៍។

**ការទទួលខុសត្រូវរួមមាន:**

- **បង្កើតក្លឹបបរិស្ថាន**
- **ជួយសំរួលដល់សិស្សដើម្បីរៀបចំ**ការប្រជុំក្លឹបជាទៀងទាត់ មួយដងក្នុងមួយសប្តាហ៍
- **ជួយសំរួលដល់សិស្សដើម្បីរៀបចំ**ធ្វើសកម្មភាពអំពីបរិស្ថាន
- **អនុវត្តផ្តល់មេរៀនបន្ថែមស្តីពី**ប្រធានបទបរិស្ថានដោយប្រើប្រាស់សំភារៈដែលមាន
- **ទំនាក់ទំនងអោយបានទៀងទាត់**ជាមួយការិយាល័យរដ្ឋបាលសាលា អាជាធរស្រុក ខេត្តស្តីពីសកម្មភាពរីកចំរើនរបស់ក្លឹបបរិស្ថាន

**គុណសម្បត្តិ:**

- អ្នកស្ម័គ្រចិត្ត និងមានឆន្ទៈធ្វើការរៀងរាល់ថ្ងៃព្រហស្បតិ៍ និងថ្ងៃឈប់សំរាក
- ផ្តល់នូវការដឹកនាំសិស្ស និង វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល
- មានការចាប់អារម្មណ៍ទៅលើបញ្ហាបរិស្ថាន
- មានផ្ទះជិតដែលងាយស្រួលទៅសាលារៀន (ពេញចិត្ត)
- មានទំនាក់ទំនងល្អជាមួយលោកគ្រូអ្នកគ្រូ និងសហគមន៍



### សំណួរសំភាសន៍

សំណួរសំភាសន៍មានដូចខាងក្រោម:

១- ហេតុអ្វីបានជាអ្នកចាប់អារម្មណ៍ចង់ធ្វើជាអ្នកសំរបសំរួលក្លឹបបរិស្ថាន?

២- តើ វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ៉ ជាអ្វី ? ហើយតើអ្នកយល់ឃើញយ៉ាងដូចម្តេច ?

៣- **តើអ្នកអាចប្រាប់ខ្ញុំអំពីបញ្ហាបរិស្ថានទាំងនៅតាមសាលារៀន និងសហគមន៍មានអ្វីខ្លះ?**

៤- **តើមានកត្តាអ្វីជំរុញអោយអ្នកស្ម័គ្រចំណាយពេលវេលានៅថ្ងៃឈប់សំរាកដើម្បីជួយសំរួលដល់ក្លឹប?**

៥- តើអ្នកយល់ឃើញយ៉ាងដូចម្តេច **អំពីសក្តានុពលរបស់ក្លឹបបរិស្ថាន ដើម្បីធ្វើការពង្រឹងកែលំអនូវបរិស្ថានសាលារៀន និងបង្កើនសមត្ថភាពរបស់សិស្ស?**

៦- តើអ្នកបានធ្វើអ្វីខ្លះកន្លងមកដើម្បីជួយដល់សាលារៀន **វឺបរិស្ថានក្នុងស្រុក ?**

៧- តើអ្នកយល់ថា សិស្សអាចរៀបចំកិច្ចប្រជុំដោយខ្លួនឯងបានរឺទេ? **ហេតុអ្វីបានជាអ្នកគិតថានេះជាជំនាញសំខាន់ ?**

៨- តើអ្នកពេញចិត្តចូលរួមនៅក្នុងការបណ្តុះបណ្តាល **របស់ក្លឹបបរិស្ថានដែររឺទេ?**

## ឧបសម្ព័ន្ធ IV: គំរូប្រកាសជ្រើសរើសសមាជិកក្លឹបបរិស្ថាន

**ក្លឹបបរិស្ថាន ឥឡូវនេះជ្រើសរើសសមាជិកថ្មី!**

តើអ្នកចាប់អារម្មណ៍អំពីបរិស្ថានដែររឺទេ?

តើអ្នកពេញចិត្តធ្វើជាអ្នកស្ម័គ្រចិត្តដើម្បីជួយដល់សាលារបស់អ្នករឺទេ?

តើអ្នកពេញចិត្តរៀនជំនាញថ្មីៗ និងចំណេះដឹងផ្សេងៗអំពីបរិស្ថានដែររឺទេ?

តើអ្នកអាចមកចូលរួមប្រជុំរៀងរាល់សប្តាហ៍នៅសាលារៀន និងនៅថ្ងៃឈប់សំរាកបានដែររឺទេ?

ប្រសិនបើអ្នកឆ្លើយយល់ព្រមទាំងអស់នូវសំណួរទាំងនេះ

ត្រូវដាក់ពាក្យជាសមាជិកថ្មីនៃក្លឹបបរិស្ថានថ្មី.....!!

សំរាប់ពត៌មានលំអិតសូម.... (ទាក់ទងលោកគ្រូអ្នកគ្រូ រឺមកចូលរួមប្រជុំ រឺ មកចុះឈ្មោះនៅទីនេះ)

អ្នកអាចធ្វើអ្វីមួយអោយមានភាពខុសប្លែកពីគេ ...!!

## ឧបសម្ព័ន្ធV: គំរូលិខិតផ្ញើទៅឪពុកម្តាយសិស្ស

ជូនចំពោះ ......................................

ខ្ញុំជាអ្នកសំរបសំរួលក្លឹបបរិស្ថាន នៃសាលារៀន.............................................។ ខ្ញុំសូមផ្ញើលិខិតជូនលោកស្រី: .........................ជាឪពុកម្តាយសិស្សឈ្មោះ ................................។ ដូចលោកអ្នកបានដឹងហើយថាបញ្ហាបរិស្ថានជាកត្តាមួយដ៏សំខាន់បំផុត ហើយយើងទាំងអស់គ្នាពាក់ព័ន្ធទៅ និងបញ្ហានេះដែលយើងកំពុងជួបប្រទះទាំង នៅក្នុងសហគមន៍ និងនៅក្នុងប្រទេសរបស់យើង ទាំងមូល ។ យើងពិនិត្យឃើញថាការថយចុះនូវបរិស្ថាននៅក្នុងតំបន់យើងដូចជា ...................................................... ហើយយើងទាំងអស់គ្នាដឹងហើយថា ការបាត់បង់ធនធានធម្មជាតិ ការបាត់បង់ធនធានធម្មជាតិ ធ្វើអោយមានផលប៉ះពាល់ដល់ ជីវិតរស់នៅ និងជាពិសេសសំរាប់កូនចៅ របស់យើង ។

ដើម្បីចូលរួមក្នុងការដោះស្រាយនូវបញ្ហាទាំងនេះ ក៏ដូចជាការការពារនូវបញ្ហាផ្សេងៗទៀតទៅអនាគត យើងត្រូវបង្កើនការយលដឹងអំពីបរិស្ថានដល់កុមាររបស់យើង ហើយនៅពេលជាមួយគ្នានោះដែរនឹងផ្តល់ឱកាសដល់ពួកគេដើម្បីចូលរួមដោះស្រាយបញ្ហាទាំងនេះ ។ ដើម្បីសំរេចបាននូវទិសដៅនេះសាលារៀនយើងដោយមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា បានបង្កើត នូវក្លឹបនេះឡើង ។ ក្លឹបបរិស្ថាន គឺជាក្រុមសិស្សស្ម័គ្រចិត្តដែលជួបជុំគ្នាជាក្រុមសិស្សស្ម័គ្រចិត្តដែលជួបជុំគ្នាដើម្បីធ្វើផែនការ និងអនុវត្តសកម្មភាពក្នុងការពង្រឹងកែលំអនូវបរិស្ថានទាំងនៅសាលារៀននិងនៅក្នុងសហគមន៍ ។

ដោយបានក្លាយជាសមាជិកនៃក្លឹបនេះ កូនរបស់លោកអ្នកនិងមានឱកាសសិក្សាអំពីបរិស្ថាន និងចូលរួមសកម្មភាពដើម្បីពង្រឹងវិស័យបរិស្ថានផងដែរ ។ បន្ថែមពីនេះទៀតសកម្មភាពសិស្សកំរងនិងផ្តល់ជំនាញសិក្សា ស្រាវជ្រាវជាមូលដ្ឋាន ពង្រឹងសមត្ថភាពការទំនាក់ទំនង និងផ្តល់ឱកាសជាច្រើនសំរាប់ក្រុមការងារ និងជំរុញការ បង្កើតគំនិតថ្មីៗ និងជំនាញដឹកនាំទៀតផង ។

កូនរបស់អ្នកបានសំដែងនូវការចាប់អារម្មណ៍ ចង់ក្លាយជាសមាជិកក្លឹបបរិស្ថានរបស់សាលា ហើយយើងពេញចិត្តយ៉ាងខ្លាំង ដើម្បីអោយគាត់ចូលរួម ។ ក្លឹបបរិស្ថាននិងជួបប្រជុំក្រៅម៉ោងសិក្សាយ៉ាងតិចមួយដងក្នុងមួយសប្តាហ៍ ។ យើងសង្ឃឹមថា លោកអ្នកនិងអនុញ្ញាតិអោយសិស្សនេះចូលរួម និងគាំទ្រដល់សកម្មភាពក្លឹបបរិស្ថាន ។

សូមលោក លោកស្រីទទួលនូវការគោរពរាប់អានពីខ្ញុំ ។

អ្នកសំរបសំរួលក្លឹបបរិស្ថាន

## គំរូបែបបទចុះបញ្ជីឈ្មោះអ្នកចូលរួម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .............................. ជាឪពុកម្តាយសិស្សឈ្មោះ ............................ ចង់អោយកូនរបស់ខ្ញុំក្លាយជាសមាជិកនៃក្លឹបបរិស្ថាន។ ខ្ញុំយល់ហើយថាសកម្មភាពនានារបស់ក្លឹបមានការពាក់ព័ន្ធខ្លះៗ ទៅនឹងការផ្តល់ពេលវេលា បន្ទាប់ពីម៉ោងសិក្សា និងនៅថ្ងៃឈប់សំរាក។ ជាមួយគ្នានោះដែរ វានឹងមានការធ្វើដំណើរជាមួយសមាជិកក្រុមចេញក្រៅសាលាដូចជា ធ្វើការនៅក្នុងសហគមន៍ និងការចុះធ្វើការទស្សនៈកិច្ចសិក្សា។ល។

ខ្ញុំពេញចិត្តគាំទ្រនូវសកម្មភាពក្លឹប ដូចខាងក្រោម:

- ○ ស្ម័គ្រចិត្តផ្តល់ជំនាញរបស់ខ្ញុំក្នុង ............................................
- ○ ផ្តល់សំភារៈខ្លះៗ
- ○ ធ្វើការបរិច្ចាក
- ○ សូមអភ័យទោស ខ្ញុំមិនអាចផ្តល់វិភាគទាននៅពេលនេះទេ

ហត្ថលេខា

ឈ្មោះ

ថ្ងៃខែឆ្នាំ

## ឧបសម្ព័ន្ធVI: កំនត់គំរូការកម្មវិធី

ការកំនត់គំរូវការដ៏ល្អមួយ គំរូវអោយមាននូវធនធានផ្សេងៗជាច្រើនពីអ្នកចូលរួមនានា។ ដើម្បីអនុវត្តការកំនត់គំរូវការកម្មវិធី អ្នកត្រូវពិចារណានូវជំហានដូចខាងក្រោម:

*ជំហានទី ១- ការវិភាគស្ថានភាព*

ស្រាវជ្រាវនូវអ្វីដែលអាចរកបានដូចខាងក្រោម :

- តើសំភារៈបរិស្ថានសំខាន់ៗមានអ្វីខ្លះ ?
- តើបញ្ហាបរិស្ថានសំខាន់ៗមានអ្វីខ្លះ ?
- តើបរិស្ថានមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់មនុស្សយ៉ាងដូចម្តេច ?
- តើមានសកម្មភាពអ្វីខ្លះដើម្បីដោះស្រាយបញ្ហាទាំងនេះ ?
- តើមានដំណោះស្រាយអ្វីផ្សេងទៀតដែររឺទេ ?

*ជំហានទី ២- ការវិភាគអ្នកចូលរួម*

- តើអ្នកណាជាអ្នកដែលមានតួនាទីដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាទាំងនេះ ?
- តើពួកគេមានចំណេះប់រការម្ភយ៉ើអ្វីខ្លះក្នុងការសហការជាមួយក្លឹបបរិស្ថាន? (ការិយាល័យគ្រប់គ្រងរដ្ឋបាលសាលា ប្រធានភូមិ និងគណៈកម្មការវត្ត ។ល។)

*ជំហានទី៣- ធនធាន*

- តើមានធនធានអ្វីខ្លះ (ហិរញ្ញវត្ថុ និងផ្សេងៗ) ដែលអាចមានសំរាប់ក្លឹបបរិស្ថាន ?
- តើអ្នកណាពេញចិត្តបរិច្ចាកនូវសំភារៈ រឺសេវាផ្សេងៗ?
- តើមានអ្វីខ្លះដែលជាអាទិភាពចាំបាច់?

*ជំហានទី៤- សេចក្តីសន្និដ្ឋាន*

- កំណត់នូវបញ្ហានានាដែលអ្នកសង្ឃឹមថាអាចដោះស្រាយបាន និងគោលបំណងនៃកម្មវិធី
- តើធនធានសំខាន់ៗអាចរកបានតាមគំរូវការដែររឺទេ?

**កំនត់គំរូការបរិស្ថានរបស់សិស្ស**

ការវាយតំលៃសាមញ្ញខាងក្រោម គឺសំរាប់សិស្សប្រើប្រាស់។ ពួកគេគួរត្រូវបានជំរុញអោយធ្វើការសំភាសន៍ជាមនុស្សជាច្រើនរួមមាន ប្រជជនក្នុងភូមិ និងសិស្សផ្សេង១ទៀត គ្រូបង្រៀន និងឪពុកម្ដាយ

ជំហានទី១- ស្ថានភាពបរិស្ថាន

- តើមានសម្បត្តិបរិស្ថានអ្វីខ្លះនៅក្នុងតំបន់រស់នៅរបស់អ្នក ?
- តើមានបញ្ហាបរិស្ថានអ្វីខ្លះនៅក្នុងសាលារៀនរបស់អ្នក ?
- តើមានបញ្ហាបរិស្ថានអ្វីខ្លះនៅក្នុងភូមិរបស់អ្នក ?

ជំហានទី២- មូលហេតុនៃបញ្ហា

- តើមានមានមូលហេតុអ្វីខ្លះ ដែលបង្កអោយមានបញ្ហាដូចដែលអ្នកបានសរសេរខាងលើ?

ជំហានទី៣- ដំណោះស្រាយ

- តើមានដំណោះស្រាយអ្វីខ្លះដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើង ?

ជំហានទី៤- គំរូវការ

- តើពួកគេត្រូវការសិក្សាអ្វីខ្លះ ?
- តើខ្វះខាតជំនាញ និង សំភារៈអ្វីខ្លះ ?

ជំហានទី៥- សេចក្ដីសន្និដ្ឋាន

- កំណត់នូវបញ្ហាអាទិភាពនានា ដែលពួកគេសង្ឃឹមថា អាចដោះស្រាយបាន និងកណត់**គោលបំណងនៃកម្មវិធី**
- **តើធនធានសំខាន់១ បំពេញតំរូវការគ្រប់គ្រាន់ដែរឺទេ** ?

**ឧបសម្ព័ន្ធ VII: គំរូទំរង់កំណត់ហេតុ**

| កំណត់ហេតុប្រជុំ |
|---|
| ឈ្មោះក្លឹប: .................................. សាលា: .................................. |
| ១-ប្រធានបទ: |
| ២-កាលបរិច្ឆេទ: |
| ៣-ទីកន្លែង: |
| ៤-ពេលវេលា: |
| ៥-អ្នកសំរបសំរួលប្រជុំ: |
| ៦-ចំនួនអ្នកចូលរួម: |
| ៧- ពន្យល់ពីដំណើរការ: |
| ៨- ចំណុចសកម្មភាព/សេចក្ដីសំរេច: |
| ៩-បញ្ហានានា និងគំនិតផ្សេង១: |
| ហត្ថលេខាអ្នកដឹកនាំក្លឹប |

**ឧបសម្ព័ន្ធ VIII: សាលាគំរូក្នុងផែនការអប់រំបរិស្ថាន**

គោលបំណង:

១- កំណត់នូវអត្ថន័យនៃពាក្យបរិស្ថាន

២- ពន្យល់ណែនាំនូវឥទ្ធិពលនៃបរិស្ថានទៅលើមនុស្ស

៣- ផ្ដល់ឱកាសដល់សិស្សដើម្បីធ្វើការផ្លាស់ប្ដូរទស្សនៈរបស់ខ្លួនអំពីសាលាគំរូ

| | |
|---|---|
| សេចក្តីណែនាំ | |
| ការបង្កើត: | **ក្នុង រឺក្រៅសាលា** |
| ចំនួនសមាជិកក្រុម: | **២៥-៣៥នាក់** |
| កំរិតថ្នាក់: | **ទី៥ និងទី៦** |
| រយៈពេលសកម្មភាព: | **២-៣ម៉ោង** |
| សំភារៈចាំបាច់: | **ក្រដាសទំហំ អា៣ ខ្មៅដៃ តំរបផ្លាស្ទិក** |

ចំណេះដឹង

បរិស្ថាន គឺជាអ្វីៗគ្រប់បែបយ៉ាង ដែលស្ថិតនៅជុំវិញខ្លួនយើង **រួមទាំងខ្លួនយើងផងដែរ** ដូចនេះ បើយើង **ជាផ្នែកមួយនៃបរិស្ថាន** ការប្រែប្រួលនូវក្នុងបរិស្ថានដាច់ខាតត្រូវជះឥទ្ធិពលមកលើខ្លួនយើង **មិនខាន។** វាហាក់ដូចជាផ្ទះមួយ បើយើងរស់នៅក្នុងផ្ទះដ៏ស្រស់ស្អាតមួយ **នោះយើងរស់នៅប្រកបដោយ** ភាពរីករាយ។ ម្យ៉ាងវិញ ទៀតបើសិនជញ្ជាំង រឺដំបូងផ្ទះបាក់បែក នោះជាការពិត យើងត្រូវបានទទួលរងនូវ ដំណក់ទឹកភ្លៀង និងពន្លឺថ្ងៃ ជាមិនខាន។ បរិស្ថានជះឥទ្ធិពលមកលើយើង យ៉ាងតិចបីប្រភេទ: ទីមួយមានផលប៉ះពាល់ទៅលើសុខភាពរបស់ យើង។ ឧទាហរណ៍បើសិននៅជុំវិញខ្លួនយើងមានអនាម័យ

ខ្លួនយើងមានអនាម័យល្អ យើងរស់នៅសុខភាពល្អ។ ទោះបីយ៉ាងណាក៏ដោយ **បើទឹកនិងខ្យល់មានភាព**

ក្រខ្វក់នោះជំងឺដង្កាត់នឹងកើតមានផងដែរ។

**ទីពីរបរិស្ថានមានឥទ្ធិពលទៅលើជីវិតរស់នៅរបស់យើង។**

ឧទាហរណ៍ **ភាពរាំងស្ងួតថ្មីៗនេះជះឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវិតរស់នៅរបស់កសិករយើង។** ជាចុងក្រោយ **បញ្ហាបរិស្ថានអាចបង្កើតនូវវិបត្តិសង្គមដ៏ធ្ងន់ធ្ងរផងដែរ។** ឧទាហរណ៍ ការខ្វះខាតធនធានធម្មជាតិបាន **បង្កើតអោយមានសង្គ្រាមផ្សេងៗ រវាងប្រទេសជាច្រើន។**

កុមារតូចៗ បរិយាកាសសាលារៀន សំរាមបានជះឥទ្ធិពលយ៉ាងខ្លាំងដូចជា ទៅលើសុខភាព **របស់ពួកគេ** ក៏ដូចជាការសិក្សាផងដែរ។ បរិយាកាសក្នុងសាលារៀនអាចនាំមកនូវការជោគជ័យ និង **បរាជ័យ** នៅក្នុងជីវិតរបស់សិស្សម្នាក់ៗ។ នេះគឺជាគំនិតខ្លះៗ សំរាប់សាលារៀនមួយដែលមានបរិយាកាសល្អ:

- ទីធ្លាសាលាមានអនាម័យ និងសុវត្ថភាពល្អ ក៏ដូចជាថ្នាក់រៀន និងអាគារផងដែរ
- មានធុងសំរាមដាច់ដោយឡែក
- មានគំនរជីកំប៉ុស រឺរណ្តៅកប់សំរាប់កែច្នៃសំរាម ដែលងាយរលួយ
- មានសំរាមដែលអាចយកមកប្រើប្រាស់វិញបាន
- មានកន្លែងបណ្តុះកូនឈើ
- មានសួនផ្កា បន្លែ និងរុក្ខជាតិធ្វើឱសថ
- មានបដាពតិមានដើម្បីណែនាំផ្សេងៗអំពីបញ្ហាបរិស្ថាន
- មានជើងម៉ា និងតុក្រោមដើមឈើសំរាប់ការសិក្សាខាងក្រៅថ្នាក់
- មានទីធ្លាសំរាប់លេងកីឡាផ្សេងៗ
- ទីជំរកសត្វ
- មានសញ្ញាសំគាល់ឈ្មោះដើមឈើ
- មានប្រអប់សំបុត្រ

**សកម្មភាព**

១- សួរសិស្សថា តើពួកគេយល់ថាបរិស្ថានមានន័យយ៉ាងម្តេច?

(សរសេរចំលើយរបស់ពួកគេនៅក្តាខៀន។ សូមកុំប្រាប់ពួកគេអំពី **ខុស រឺត្រូវ**)

២- ប្រាប់ពួកគេពីអត្ថន័យនៃបរិស្ថានដោយមានជាឧទាហរណ៍ផ្សេងៗ

៣- សួរសិស្សថា **បើយើងទាំងអស់គ្នាជាផ្នែកមួយនៃបរិស្ថាន តើការប្រែប្រួលនូវបរិស្ថានជះឥទ្ធិពលមកលើយើងរឺទេ?** (ពន្យល់ពីផលប៉ះពាល់ពីបរិស្ថានដោយប្រៀបធៀបទៅនិងការ

រស់នៅក្នុងផ្ទះ)

៤- សួរទៅសិស្សថា តើបរិស្ថានមាននៅកន្លែងណាខ្លះ ជារៀងរាល់ថ្ងៃ? (នៅសាលារៀន បន្ទាប់មក ប្រាប់គេថា បរិស្ថានក្នុងសាលាមានសារៈសំខាន់ណាស់សំរាប់ពួកគេ) ។

៥- ពន្យល់ដល់សិស្ស អំពីការជះឥទ្ធិពលនៃបរិស្ថានក្នុងសាលាទៅលើពួកគេដូចជា សុខភាព និង ការសិក្សា ។

៦- ប្រាប់ដល់សិស្សទាំងអស់ថា សូមអោយបិទភ្នែក ហើយធ្វើការស្រមើស្រមៃ ថាតើពួកគេចង់មានសាលារៀនយ៉ាងដូចម្តេចដើម្បីសិក្សា ។

៧- បែងចែកសិស្សជាក្រុមតូចៗដែលមានចំនួនពី ៤-៥នាក់គ្រប់ក្រុមនីមួយៗ

៨- ផ្តល់ក្រដាសទំហំ អា៣ (វិទំហំធំជាង) និងខ្មៅដៃ ដល់គ្រប់ក្រុមនីមួយៗ

៩- អោយពួកគេគូររូបភាពសាលារៀន ទៅតាមការស្រមើស្រមៃរបស់ពួកគេ ។ សោភ័ណភាពរូបភាពពុំសូវមានសារៈសំខាន់ទេ ។ គំនិតទើបមានសារៈសំខាន់ជាង ។

១០- ត្រឡប់មកក្នុងថ្នាក់រៀនវិញ ។ រួចហើយអោយពួកគេបង្ហាញអំពីគំនិតរបស់ពួកគេ ។

១១- ពិភាក្សាអំពីគំនិតយោបល់ រួចហើយធ្វើសេចក្តីសន្និដ្ឋានអំពីសាលារៀនគំរូដែលស្ថិតក្នុងបរិយាកាសមួយដ៏ល្អ

១២- ដាក់ពន្យូររូបភាពនៃសាលារៀនគំរូ និងធ្វើការផ្សព្វផ្សាយពត៌មានអំពីរូបភាពទាំងនោះ

ការវាយតំលៃ

១-តើបរិស្ថាន គឺជាអ្វី?

២-តើនៅក្នុងមធ្យោបាយណាខ្លះដែលបរិស្ថានមានឥទ្ធិពលមកលើយើង?

៣-តើសាលារៀនគំរូដែលមានបរិយាកាសល្អមានលក្ខណៈបែបណាខ្លះ?

សកម្មភាពបន្ត

អោយសិស្សទាំងអស់ធ្វើការស្រមើស្រមៃអំពីភូមិមួយដែលពួកគេចង់រស់នៅ រួចហើយគូររូបភាពអំពីភូមិនោះ ហើយយកមកសាលារៀននៅពេលម៉ោងសិក្សាលើកក្រោយ ។

## ឧបសម្ព័ន្ធ IX: ផែនការសកម្មភាព

| ខែ | សប្តាហ៍ | គោលបំណង | សកម្មភាព | អ្នកចូលរួម |
|---|---|---|---|---|
| តុលា | ១ , ២ | បង្កើតក្លឹប | ត្រូវចាប់ផ្តើម | សិស្សនិងគ្រូទាំងអស់ |
| | ៣ | ដើម្បីយល់ដឹងអំពីបរិស្ថាននៅក្នុងសាលារៀន | តើបរិស្ថានជាអ្វី? | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | បង្កើតទស្សនៈរបស់សមាជិកអំពីសាលារៀនគំរូដែលមានបរិស្ថានល្អ | គំរូសាលារៀននៅក្នុងបរិយាកាសល្អ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| វិច្ឆិកា | ១ | ធ្វើផែនការសកម្មភាពរបស់ក្លឹប | ផែនការសកម្មភាពបរិស្ថាន | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | បង្កើតការយល់ដឹងអំពីសំរាម | តើអ្វីជាកាកសំណល់? | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ និង ៤ | ដាក់កាកសំណល់ដាច់ដោយឡែកនៅក្នុងសាលារៀន | តើយើងត្រូវការធុងសំរាមប៉ុន្មាន? | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| ធ្នូ | ១ | កាត់បន្ថយសំរាមដែលមិនរលួយនៅក្នុងសាលារៀន | ការពិនិត្យកញ្ចប់សំរាម( ថង់ប្លាស្ទិក) | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | កែច្នៃសំរាមដែលងាយរលួយ | ធ្វើជីកំប៉ុស | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ និង ៤ | កែច្នៃក្រដាសចាស់ៗឡើងវិញ | ធ្វើជាក្រដាសប្រើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| មករា | ១ | ជំរុញដល់ដទៃទៀតកុំអោយបោះចោលសំរាមក្នុងសាលារៀន | គូររូបភាពប្រឆាំងការបោះចោលសំរាម | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ និង ៣ | ពង្រីកការយល់ដឹងអំពីបញ្ហាសំរាមដល់អ្នកដទៃទៀត | ធ្វើជាសំណាញ់សំរាប់ការយល់ដឹងពីសំរាម | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | ជំរុញដល់អ្នកដទៃទៀតអោយចូលរួមរក្សាអនាម័យសាលា | ចូលជួយពីអ្នកដទៃ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |

| | | | | |
|---|---|---|---|---|
| កុម្ភៈ | ១ | កំណត់តំរូវការគ្រាប់ពូជសំរាប់ដាំដុះ | បណ្តុះពីគ្រាប់ពូជទៅជាកូនឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | សិក្សាបន្ថែមពីការដាំកូនឈើ | ចុះមើលកន្លែងបណ្តុះកូនឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ និង ៤ | បង្កើតកន្លែងបណ្តុះកូនឈើ | ការដាំកូនឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| មិនា | ១ | ធ្វើផែនការសំរាប់ទិវាផ្សេងៗ | អនុវត្តផែនការ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | សរសេររឿងខ្លីស្តីពីប្រធានបទបរិស្ថាន | សំដែងសិល្បៈពីបរិស្ថាន | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ | សរសេរកំណាព្យស្តីពីប្រធានបទបរិស្ថាន | កំណាព្យស្តីពីបរិស្ថាន | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | សរសេរចំរៀងស្តីពីប្រធានបទបរិស្ថាន | ចំរៀងស្តីពីបរិស្ថាន | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| មេសា | ១ | ផ្សព្វផ្សាយការយល់ដឹងពីបរិស្ថានដល់អ្នកដទៃទៀត និងក្នុងសហគមន៍ | ពិធីពិសេសផ្សេងៗ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ និង ៣ | ប្រមូលគ្រាប់ពូជន៍សំរាប់បណ្តុះ | ប្រមូលគ្រាប់ពូជ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | បណ្តុះគ្រាប់ពូជន៍ | ការដាំដុះកូនពូជ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| ឧសភា | ១ | សិក្សាអំពីដើមឈើនៅក្នុងសាលារៀន | ការពិនិត្យដើមឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | គូរូបភាពពីស្លឹកឈើងាប់ | រូបភាពអំពីស្លឹក | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ | សិក្សាពីដើមឈើផ្តល់ឧសិហ្សែនអំពីជីវិតនៅលើផែនដី | ស្លឹកនិងពន្លឺថ្ងៃ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | សិក្សាពីដើមឈើការពារដីពីសំណឹក | គ្របដណ្តប់ធម្មជាតិ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |

| | | | | |
|---|---|---|---|---|
| | ១ | សិក្សាពីសារៈប្រយោជន៍នៃរុក្ខជាតិសំរាប់ជីវិតនៅលើផែនដី | ចុះសិក្សានៅឧទ្យានជាតិ ឬទីកន្លែងធម្មជាតិ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | សំរេចទីកន្លែងសំរាប់ដាំដុះកូនឈើ | ផែនទីដើមឈើនៅក្នុងសាលារៀន | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ | ដាំដើមឈើនៅក្នុងសាលារៀន | ការដាំដើមឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | សិក្សាពីការថែរក្សាដើមឈើ | ការថែរក្សាដើមឈើ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| កក្កដា | ១ | សិក្សាពីវិធីបាញ់ថ្នាំសំលាប់សត្វល្អិតធម្មជាតិ | ថ្នាំសំលាប់សត្វល្អិតធម្មជាតិ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | សិក្សាពីវិធីធ្វើអោយព្រៃឈើមាននិរន្តភាព | ការប្រើប្រាស់ព្រៃប្រកបដោយនិរន្តភាព | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ | សិក្សាពីផលិតផលព្រៃឈើ | តើផលិតផលព្រៃឈើមានអ្វីខ្លះ? | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | សិក្សាពីដើមឈើ ដែលធ្វើជាឱសថធម្មជាតិ | ធ្វើសួនដាំរុក្ខជាតិសំរាប់ធ្វើឱសថធម្មជាតិ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| សីហា | ១ | សិក្សាពីផែនដីដែលសំបូរដោយជីវៈចំរុះ | អង្កេតពីធម្មជាតិ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ២ | សិក្សាពីអ្វីៗនៅលើផែនដីមានទំនាក់ទំនងគ្នាទៅវិញទៅមក | ប្រព័ន្ធនៃជីវិត | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៣ | សិក្សាពីធម្មជាតិមានតុល្យភាព បើគ្មានការជះឥទ្ធិពលទៅលើជីវិតមនុស្ស | ការប្រែប្រួលបណ្តាលភាវៈ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| | ៤ | សិក្សាពីការគំរាមកំហែងទៅលើជីវចំរុះ | ការគំរាមកំហែងលើជីវចំរុះ និងសត្វ | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |
| កញ្ញា | ១ | ប្រែក្លាយទីធ្លាសាលារៀនជាទីជំរកសត្វដ៏ល្អ | ការបង្កើតទីជំរក | អ្នកសំរបសំរួលក្រុម និងសិស្សទាំងអស់ |
| | ២ | វាយតំលៃអាកប្បកិរិយាសមាជិកក្លឹបអំពីបរិស្ថាន | ការរស់នៅពោរពេញដោយពន្លឺសុភមង្គល | អ្នកសំរបសំរួលក្លឹប និងសិស្សទាំងអស់ |

## ឧបសម្ព័ន្ធ X: របាយការណ៍ប្រចាំត្រីមាសសំរាប់ការិយាល័យអប់រំស្រុក

១-ប្រវត្តិកម្មវិធី

ក- ទីកន្លែង

ខ- បញ្ហាបរិស្ថាននៅក្នុងសាលា

គ- ទិសដៅ និងគោលបំណងរបស់ក្លឹប

២-ការពិពណ៌នាអំពីសកម្មភាព

ក- គោលបំណងប្រចាំត្រីមាស

ខ- លទ្ធផលនានា

គ- តារាងសកម្មភាព

៣-បញ្ហានានាក្នុងការអនុវត្តន៍សកម្មភាព

ក- បញ្ហាផ្សេងៗដែលបានជួបប្រទះ

ខ- ដំណោះស្រាយ

៤-ការធ្វើផែនការសំរាប់ត្រីមាសបន្ទាប់

## ឧបសម្ព័ន្ធ XI: កម្មវិធីសំរាប់សិក្ខាសាលាបណ្ដុះបណ្ដាលគ្រូវគ្គ១

| ថ្ងៃ | ពេលម៉ោង | ប្រធានបទ |
|---|---|---|
| ១ | ៧:៣០ - ៧:៤៥ | ការចុះឈ្មោះ |
| | ៧:៤៥ - ៨:០០ | ការណែនាំ |
| | ៨:០០ - ៨:៣០ | បើកអង្គសិក្ខាសាលា |
| | ៨:៣០ - ៨:៤៥ | សំរាកញ៉ាំអាហារ |
| | ៨:៤៥ - ១០:១៥ | ចាប់ផ្ដើម |
| | ១០:១៥ - ១១:២០ | តើបរិស្ថានជាអ្វី? |
| | ១១:៣០ - ២:០០ | សំរាកអាហារថ្ងៃត្រង់ |
| | ២:០០ - ៣:១៥ | សាលារៀនគំរូមានបរិស្ថាន |
| | ៣:១៥ - ៣:៣០ | សំរាកញ៉ាំអាហារ |
| | ៣:៣០ - ៤:១៥ | តើកាកសំណល់សំរាមជាអ្វី? |
| | ៤:១៥ - ៤:៣០ | ការវាយតំលៃប្រចាំថ្ងៃ |
| ២ | ៧:៣០ - ៧:៤៥ | ការចុះឈ្មោះ |
| | ៧:៤៥ - ៩:០០ | តើយើងត្រូវការធុងសំរាមប៉ុន្មាន? |
| | ៩:០០ - ១០:១៥ | សំរាកញ៉ាំអាហារ |
| | ១០:១៥ - ១១:៣០ | ការធ្វើជីកំប៉ុស |
| | ១១:៣០ - ២:០០ | សំរាកអាហារថ្ងៃត្រង់ |
| | ២:០០ - ៣:១៥ | ការធ្វើក្រដាសមកប្រើឡើងវិញ |
| | ៣:១៥ - ៣:៣០ | សំរាកញ៉ាំអាហារ |
| | ៣:៣០ - ៤:១៥ | គូររូបប្រឆាំងនិងការបោះចោលសំរាម |
| | ៤:១៥ - ៤:៣០ | ការវាយតំលៃប្រចាំថ្ងៃ |
| ៣ | ៧:៣០ - ៧:៤៥ | ការចុះឈ្មោះ |
| | ៧:៤៥ - ៩:០០ | ធ្វើសំណាញ់ពីងពាងសំរាប់ការយល់ដឹងពីសំរាម |
| | ៩:០០ - ១០:១៥ | ការសុំជួយពីអ្នកដទៃទៀត |
| | ១០:១៥ - ១០:៣០ | សំរាកញ៉ាំអាហារ |
| | ១០:៣០ - ១១:៣០ | ការធ្វើផែនការសកម្មភាព |
| | ១១:៣០ - ២:០០ | សំរាកអាហារថ្ងៃត្រង់ |
| | ២:០០ - ៣:០០ | ការអនុវត្តសាកល្បង |
| | ៣:០០ - ៣:៣០ | សំរាកញ៉ាំអាហារ |
| | ៣:៣០ - ៤:៣០ | បិទអង្គសិក្ខាសាលា |

## ឧបសម្ព័ន្ធ XII: បញ្ជីសំភារៈជ្រើសរើសដើម្បីជួយដល់ការគាំទ្រដល់ការរៀបចំឯកសារមេរៀន

| ល.រ | ចំណងជើងសកម្មភាព | ភាសា | ការពិពណ៌នា | អ្នកនិពន្ធ |
|---|---|---|---|---|
| ១ | ឯកសារណែនាំអំពីអ្នកអប់រំបរិស្ថាន -៤២សកម្មភាពសំរាប់សិស្សសាលា | ខ្មែរ/អង់គ្លេស | ៤២ ផែនការសកម្មភាពមេរៀន ស្តីពីបរិស្ថាន | មួប់បៃតង ៗ.សៀមរាម [illegible] |
| ២ | សំរែកព្រៃឈើ | ខ្មែរ/អង់គ្លេស | ៤០ ឯកសារបណ្តុះបណ្តាលទាក់ទងនិងព្រះពុទ្ធសាសនា និង បរិស្ថាន | [illegible] |
| ៣ | ប្រធានបទបណ្តុះបណ្តាលស្តីពី ការអភិរក្សឧទ្យានជាតិគីរីរម្យ | ខ្មែរ/អង់គ្លេស | ១០ ឯកសារបណ្តុះបណ្តាល ស្តីពីការអភិរក្ស | មួប់បៃតង |
| ៤ | ឯកសារពង្រាងស្តីអំពីសកម្មភាពក្លឹបបរិស្ថាន - បរិស្ថាន ភាគ ១ | ខ្មែរ | ឯកសារនិងសភារៈសំរាប់បណ្តុះបណ្តាលគ្រូបង្គោល | មួប់បៃតង |
| ៥ | សារពង្រាងស្តីអំពីសកម្មភាពក្លឹប - បរិស្ថាន ភាគ ២ | ខ្មែរ | ឯកសារនិងសភារៈសំរាប់បណ្តុះបណ្តាលគ្រូបង្គោល | មួប់បៃតង |
| ៦ | អប់រំបរិស្ថាន | ខ្មែរ | | [illegible] |
| ៧ | វគ្គបណ្តុះបណ្តាលស្តីពីបរិស្ថានដល់មន្ត្រីកម្មវិធីអភិរក្សព្រៃឈើភ្នំក្រវាញ | ខ្មែរ | សៀវភៅបណ្តុះបណ្តាលសំរាប់ការអភិរក្ស (សំរាប់មនុស្សពេញវ័យ) | មួប់បៃតង |
| ៨ | Project Wild | អង់គ្លេស | ជាង៥០សកម្មភាពសំរាប់កុមារ (អង្គការអាមេរិក) | [illegible] |
| ៩ | ការផ្លាស់ប្តូរបទសោធន៍ធម្មជាតិជាមួយកុមារ | អង់គ្លេស | សៀវភៅអប់រំយល់ដឹងអំពីធម្មជាតិ | [illegible] |
| ១០ | សៀវភៅណែនាំសំរាប់អ្នកអប់រំបរិស្ថាន | អង់គ្លេស | ទ្រឹស្តីអំពីការអប់រំបរិស្ថាន | ៗ.សៀមរាប |

# ឧបសម្ព័ន្ធ XIII: តារាងវាយតំលៃសកម្មភាពក្លឹបបរិស្ថាន

តារាងវាយតំលៃខាងក្រោមអាចត្រូវបានប្រើប្រាស់វិអនុវត្តតាមសំរាប់ការវាយតំលៃសកម្មភាពប្រចាំខែរបស់ក្លឹបបរិស្ថាន។

សាលារៀន: ............................................. ក្រុម: ........................................

អ្នកសំរបសំរួលក្លឹបបរិស្ថាន: ........................................... ខែ: ..........................................

១- លទ្ធផលសកម្មភាព (៤០ពិន្ទុ)

| គោលបំណង | លទ្ធផល | ពិន្ទុ |
|---|---|---|
| ១ | 5 8 10 | |
| ២ | 5 8 10 | |
| ៣ | 5 8 10 | |
| ៤ | 5 8 10 | |

២- បរិស្ថានសាលារៀន (៣០ពិន្ទុ)

| កត្តាសំខាន់ៗ | ស្ថានភាព | ពិន្ទុ |
|---|---|---|
| ១- បញ្ហាសំរាម (០-១០) | | |
| ២- ប្រអប់សំបុត្រ (០-៥) | | |
| ៣- បដាពត៌មាន (០-៥) | | |
| ៤- សំភារៈក្លឹប (០-៥) | | |
| ៥- សញ្ញាសំគាល់ក្លឹប (០-៥) | | |

៣- ការយល់ដឹងរបស់សមាជិកក្លឹប (៣០ពិន្ទុ)

| កត្តាសំខាន់ៗ | លទ្ធផល | ពិន្ទុ |
|---|---|---|
| ១- ចំនួនសកម្មភាពដែលបានអនុវត្ត | | |
| ២- សិស្សឆ្លើយសំណួរ | | |

**សរុបពិន្ទុ** ចំណាត់ថ្នាក់ :

(ក : ៧៦ - ១០០)

(ខ : ៥១ - ៧៥)

(គ : ២៦ - ៥០)

(ឃ : ០- ២៥)

ការពិនិត្យបញ្ជីខាងក្រោម អាចត្រូវបានប្រើប្រាស់ដើម្បីបង្កើតជាបន្ទាត់មូលដ្ឋានមួយ និងការវាយតំលៃសំរាប់ រយៈពេលវែងដូចជា ការវាយតំលៃសកម្មភាពប្រចាំត្រីមាស។

ការពិនិត្យបញ្ជីផែទាំសាលា

| លក្ខណៈវិនិច្ឆ័យសំរាប់ពិនិត្យ | ការដាក់ពិន្ទុ | | | | |
|---|---|---|---|---|---|
| | ៥ | ៤ | ៣ | ២ | ១ |
| ១- គោលការណ៍និងការអនុវត្តន៍ផែនការដើម្បីគាំទ្របរិស្ថាន និង **ការអភិរក្ស** | | | | | |
| ១.១. មានគោលការណ៍អភិវឌ្ឍន៍កែលំអបរិស្ថាន | | | | | |
| ១.២. មានផែនការអភិវឌ្ឍន៍បរិស្ថានសាលារៀន | | | | | |
| ១.៣. បុគ្គលិកសាលាចូលរួមធ្វើផែនការអភិវឌ្ឍន៍បរិស្ថាន | | | | | |
| ១.៤. សហគមន៍ចូលរួមធ្វើផែនការអភិវឌ្ឍន៍បរិស្ថាន | | | | | |
| ២- ការបញ្ជ្រាបអប់រំបរិស្ថាននៅក្នុងសកម្មភាពបង្រៀន និងសិក្សា | | | | | |
| ២.១. មានបញ្ជ្រាបការអប់រំបរិស្ថានទៅក្នុងសកម្មភាពបង្រៀន និងសិក្សា | | | | | |
| ២.២. មានសំភារៈអប់រំបរិស្ថានគ្រប់គ្រាន់ | | | | | |
| ២.៣. សិស្សមានបទពិសោធន៍ចំពោះការអប់រំបរិស្ថាន | | | | | |
| ២.៤. បុគ្គលិកសាលាដើរតួបង្ហាញយ៉ាងល្អពីការអប់រំបរិស្ថាន | | | | | |
| ៣- ការគ្រប់គ្រងអាគារ ទីធ្លាសាលា និងថ្នាក់រៀនដែលគាំទ្រដល់ការ**អប់រំបរិស្ថាន** | | | | | |
| ៣.១. ថ្នាក់រៀន អាគារ ទីធ្លាសាលាមានអនាម័យល្អ និងមានសោភ័ណភាព និងសុវត្ថិភាព | | | | | |
| ៣.២. មានគំរោងផែនការត្រឹមត្រូវអំពីថ្នាក់រៀន អាគារ និងទីធ្លាសាលារៀន | | | | | |
| ៣.៣. មានដើមឈើ ផ្កា និងសួននៅក្នុងបរិវេណសាលារៀន | | | | | |
| ៣.៤. មានការគ្រប់គ្រងត្រឹមត្រូវលើប្រព័ន្ធបរិស្ថានសាលា | | | | | |
| ៣.៥. មានកៅអី និងតុនៅក្រោមដើមឈើ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤- បរិយាកាសសាលា និងអារម្មណ៍របស់បុគ្គលិក | | | | | |
| ៤.១. លោកគ្រូអ្នកគ្រូយកចិត្តទុកដាក់ដល់សិស្ស | | | | | |
| ៤.២. មានការផ្លាស់ប្តូរយោបល់ ការគោរពគំនិតរបស់អ្នកដទៃក្នុងសកម្មភាពបង្រៀន និងការសិក្សា | | | | | |
| ៤.៣. មានកិច្ចសហការល្អក្នុងចំណោមបុគ្គលិកសាលា | | | | | |
| ៤.៤. បុគ្គលិកសាលាពេញចិត្តចូលរួមសកម្មភាពអប់រំបរិស្ថាន | | | | | |
| ៤.៥. បុគ្គលិកសាលាមានអត្តចរិតល្អក្នុងបង្រៀន | | | | | |
| ៥- ការគ្រប់គ្រងសំរាម និងការបំផ្លាញចោល | | | | | |
| ៥.១. មានបែងចែកប្រភេទសំរាម | | | | | |
| ៥.២. ការកាត់បន្ថយសំរាម | | | | | |
| ៥.៣. ការប្រើប្រាស់សំរាមឡើងវិញ | | | | | |
| ៥.៤. ការកែច្នៃសំរាមឡើងវិញ | | | | | |
| ៥.៥. បោះចោលសំរាមបានត្រឹមត្រូវ | | | | | |
| ៦- ការសហការរបស់បុគ្គលិកសាលា | | | | | |
| ៦.១. មានការចាត់បុគ្គលិកអោយទទួលខុសត្រូវ | | | | | |
| ៦.២. នាយកសាលា និងគ្រូបង្រៀនចូលរួមសកម្មភាពអប់រំបរិស្ថាន | | | | | |
| ៦.៣. សិស្សចូលរួមសកម្មភាពអប់រំបរិស្ថាន | | | | | |
| ៦.៤. តើអ្នកបោសសំអាតចូលរួមសកម្មភាពអប់រំបរិស្ថាន | | | | | |
| ៦.៥. អ្នកដាំស្ល និងបុគ្គលិកសាលាផ្សេងទៀតចូលរួមសកម្មភាពអប់រំបរិស្ថាន | | | | | |
| ៧- ការសហការរបស់ប្រជាពលរដ្ឋ | | | | | |
| ៧.១. មានប្រជាពលរដ្ឋចូលរួមក្នុងគណៈកម្មការសាលា | | | | | |
| ៧.២. មានការសហការល្អជាមួយឪពុកម្តាយសិស្ស | | | | | |
| ៧.៣. មានការសហការល្អជាមួយសហគមន៍ និងប្រជាជន | | | | | |
| ៧.៤. មានការសហការល្អជាមួយរដ្ឋាភិបាល រឺផ្នែកឯកជនផ្សេងៗទៀត ដែលធ្វើការជាមួយសាលា | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៨- ការថែរក្សាទឹក | | | | | |
| ៨.១. មានគោលការណ៍ថែរក្សាទឹក | | | | | |
| ៨.២. ពិនិត្យសំភារៈដាក់ទឹកទៀងទាត់ | | | | | |
| ៨.៣. មានប្រព័ន្ធបង្ហូរទឹកចោល | | | | | |
| ៨.៤. ការប្រើប្រាស់ទឹកឡើងវិញ | | | | | |
| ៩- សកម្មភាពសាលាគាំទ្រដល់ការអប់រំបរិស្ថាន | | | | | |
| ៩.១. មានការបង្ហាញព័ត៌មានអំពីការអប់រំបរិស្ថាន | | | | | |
| ៩.២. បង្កើតក្រុមអភិរក្សធម្មជាតិ | | | | | |
| ៩.៣. មានសញ្ញាសំគាល់ដើមឈើ | | | | | |
| ៩.៤. មានការប្រលងប្រណាំងស្នាដៃអំពីការអប់រំបរិស្ថាន | | | | | |
| ១០- ការវាយតំលៃលើការអនុវត្តន៍អប់រំបរិស្ថាន | | | | | |
| ១០.១. មានរបាយការណ៍អំពីការអប់រំបរិស្ថាន | | | | | |
| ១០.២. មានក្រុមអភិរក្សធម្មជាតិ | | | | | |
| ១០.៣. សហគមន៍ចូលរួមក្នុងការវាយតំលៃ | | | | | |
| ១០.៤. ប្រើលទ្ធផលការវាយតំលៃដើម្បីកែលំអបន្ថែម | | | | | |

**គន្លឹះ: ដាក់ពិន្ទុ**

១= ខ្សោយ

២= គ្រាន់បើ

៣= ល្អ

៤= ល្អបង្គួរ

៥= ល្អណាស់